ទស្សនៈយុវវ័យចំពោះទស្សនវិស័យសកល
គឺមានសារៈសំខាន់នាយុគសម័យកូវីដ-១៩ <ទំព័រ៖៩

អ្នកសារព័ត៌មានដើរតួនាទីសំខាន់ ក្នុងការផ្សព្វផ្សាយទោះបីស្ថិតនៅក្នុង
កាលៈទេសៈដ៏លំបាកនិងប្រឈមក្នុងសម័យកូវីដ-១៩ក្តី <ទំព័រ៖១២-១៣

កាសែតចេញផ្សាយ
ប្រចាំខែ ឆ្នាំទី១២

# អ្នកនាំសារ
# the messenger

ខែ មេសា | ឆ្នាំ ២០២១ | លេខទី ១៣៨

www.catholiccambodia.org/km/ www.facebook.com/RVAKHMER/ https://khmer.rvasia.org/

April, 2021 | #138

## *យើងជាគ្រួសារតែមួយ!*



យើងជាគ្រួសារតែមួយ!

ក្នុងរយៈពេលនៃការបិទខ្ទប់ ដើម្បីប្រយុទ្ធប្រឆាំង នឹងវីរុសកូវីដ១៩ អង្គការការីតាសកម្ពុជា និងព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញ តែងតែបានខិតខំយកចិត្តទុកដាក់ផ្តល់នូវស្បៀងអាហារដល់ប្រជាជនជាច្រើនកន្លែងក្នុងរាជធានីភ្នំពេញ ប្រមាណជា១ម៉ឺនគ្រួសារ។ ជាមួយគ្នានេះ ក៏បានចែកម៉ាសចំនួនប្រមាណ ៤លានម៉ាស ជាអំណោយបីព្រះសហគមន៍ ក្រុងហូជីមិញ ជូនដល់ក្រសួង មន្ទីរស្ថាប័នរដ្ឋ ពន្ធនាគារ ប្រជាពលរដ្ឋ ព្រះសង្ឃ ឥស្លាមបរិស័ទ អាជ្ញាធរមូលដ្ឋាន និង ព្រះសហគមន៍កាតូលិកគ្រប់កន្លែងក្នុងប្រទេសកម្ពុជា។ លោកអភិបាលអូលីវីយេ៎មានប្រសាសន៍បញ្ជាក់ថា ៖ «កិច្ចការទាំងនេះ ជាសញ្ញាបង្ហាញ ពីការសហការគ្នា និងយកចិត្តទុកដាក់ ចូលរួមគោរពវិធានតាមអនុសាសន៍របស់សម្តេចតេជោ ហ៊ុន សែន គឺ៣កុំ ៣ការពារ ដើម្បីយើងអាចយកឈ្នះមេរោគឆ្លងកូវីដ១៩ក្នុងពេលឆាប់ៗនេះ»។

# របត់រស់នៅថ្មីក្នុងបរិបទកូវីដ-១៩



មេរោគឆ្លងកូវីដ១៩បាននាំឱ្យពិភពទាំងមូលមានការព្រួយបារម្ភ និងរងទុក្ខយ៉ាងខ្លាំង។ មនុស្សជារាប់លាននាក់បានបាត់បង់ជីវិត ប្រទេសជាច្រើនបានបិទមិនឱ្យធ្វើដំណើរទៅមក សាលារៀនបិទទ្វារ កីឡា និងការកំសាន្តនានាត្រូវបានផ្អាក សេដ្ឋកិច្ច ប្រទេសនីមួយៗបានធ្លាក់ចុះ មនុស្សរស់នៅក្នុងការភ័យខ្លាច។

បរិបទថ្មី ដែលបង្ខំឱ្យមនុស្សត្រូវតែផ្លាស់ប្តូរ ទាំងរបៀបរស់នៅ ទំនាក់ទំនាក់ និងការរក្សាអនាម័យជាដើម។ ក្នុងពេលជាមួយគ្នា ព័ត៌មានផ្សេងៗត្រូវបានជ្រៀតចូលក្នុងជីវិតរបស់ប្រជាជន កាន់តែបង្កការភ័យខ្លាចជាពិសេសព័ត៌មានក្លែងក្លាយ ជំងឺផ្លូវចិត្តក៏កើតមាន គ្រួសារបាត់បង់ចំណូលជាដើម។

មនុស្សបង្ខំចិត្តរស់នៅ តាមរបៀបថ្មី ក្នុងរបៀបទំនាក់ទនងថ្មី ដោយការរក្សាគម្លាត ពាក់ម៉ាស រក្សាអនាម័យជានិច្ច ការជួបជុំមនុស្សច្រើនមិនបាន ទំនាក់ទំនងគ្រួសារមួយទៅគ្រួសារប្រកបដោយការសង្ស័យ និងប្រុងប្រយ័ត្នចំពោះគ្នាទៅវិញទៅមក។ ប្រព័ន្ធបច្ចេកវិទ្យា ក៏បានដើរតួនាទីសំខាន់ សម្រួលក្នុងការរស់នៅរបស់ប្រជាជននាពេលនេះ។

យុវសិស្សត្រូវសិក្សាពីចម្ងាយ ដែលមានសិស្សតិចតួចបំផុតក្នុងប្រទេសកម្ពុជា ដែលបានចូលរួម តាមប្រព័ន្ធសិក្សាពីចម្ងាយ ឬតាមអនឡាញ (Online)។ ទាំងគ្រូ ទាំងសិស្ស ត្រូវរៀនទាំងអស់គ្នា ក្នុងពេលតែមួយ គឺគ្រូរៀនប្រើបច្ចេកវិទ្យាថ្មី សិស្សរៀនទាំងការប្រើបច្ចេកវិទ្យាថ្មី និង រៀនមេរៀនក្នុងថ្នាក់ជាមួយគ្រូតាមប្រព័ន្ធonline។

អ្វីៗទាំងអស់ខាងលើនេះ គឺម្នាក់ៗត្រូវតែរៀនសម្របខ្លួនតាមបរិបថថ្មី ពាក់ម៉ាសឱ្យបានត្រឹមត្រូវ រក្សាគម្លាតសុវត្ថិភាពពិតប្រាកដ លាងដៃនឹងអាល់កុល ឬសាប៊ូឱ្យបានញឹកញាប់ និយាយរួមអនុវត្តតាមវិធានរបស់ក្រសួងសុខភិបាលជានិច្ច ៣ការពារ និង៣កុំ។ ចំពោះសិស្សានុសិស្ស និស្សិត ត្រូវផ្លាស់ប្តូរទម្លាប់ចាស់ និងអភិវឌ្ឍន៍ខ្លួនក្នុងជីវិតថ្មី នៃយុគសម័យ ឌីជីថល ប្រើពេលវេលាត្រឹមត្រូវ ដូចក្នុងថ្នាក់រៀនពិតប្រាកដ ស្រាវជ្រាវឱ្យបានច្រើន តាមបណ្ណាល័យអេឡិចត្រូនិច។

ពលរដ្ឋត្រូវគោរពតាមតួនាទីភារកិច្ចរបស់ខ្លួន ចូលរួមប្រយុទ្ធប្រឆាំងជាមួយអាជ្ញាធរ ប្រយុទ្ធប្រឆាំងការឆ្លងរបស់មេរោគកូវីដ-១៩។ ច្បាស់ណាស់ក្នុងពេលវេលាលំបាកនេះ ម្នាក់ៗត្រូវដោះស្រាយដោយខ្លួនឯង ចំពោះជីវភាពប្រចាំថ្ងៃ តាមគ្រួសារនីមួយ! ពេលខ្លះល្មើសបម្រាម ច្រើនលើកច្រើនសារ! រហូតមានពាក្យនិយាយថា មិនបារម្ភពីស្លូត តែគិតពីក្រពះ។ ឃ្លានេះមានន័យថា លែងគិតពីការឆ្លងមេរោគកូវីដ-១៩ ដែលស៊ីស្លូតទៀតហើយ តែខ្លាចគ្មានម្ហូបអាហារ និងប្រាក់កាស ចំពោះការចំណាយប្រចាំថ្ងៃទៅវិញទេ។

ពិតណាស់! ក្នុងរយៈពេលបិទខ្ទប់ រាជរដ្ឋាភិបាលបានចេញសម្ភារៈ ថវិការជាច្រើនសម្រាប់ជួយពលរដ្ឋក្នុងតំបន់ហានិភ័យខ្ពស់ ដែលមានការបិទខ្ទប់។ ប៉ុន្តែយន្តការជាក់ស្តែងនៅមូលដ្ឋានការអនុវត្ត មានការខ្វះចន្លោះច្រើន មូលដ្ឋានខ្លះអំណោយសម្រាប់ជនរងគ្រោះ ត្រូវបានចែកជូនយឺតយ៉ាវជាទីបំផុត ដែលទាមទាឱ្យមានយន្តការច្បាស់លាស់ជាងនេះ នាពេលអនាគត។

ជាមួយគ្នានេះ រាជរដ្ឋាភិបាលបានជំរុញយ៉ាងខ្លាំងដើម្បីឱ្យពលរដ្ឋបានចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជាពិសេសពលរដ្ឋក្នុងតំបន់ក្រហមក្នុងរាជធានីភ្នំពេញ។

ពិតណាស់ តួនាទីរបស់យើងជាពលរដ្ឋ ជាពិសេសគ្រីស្តបរិស័ទកាតូលិក ត្រូវយកចិត្តទុកដាក់ខ្លាំងបំផុត ក្នុងការគោរពឱ្យបានខ្ជាប់ខ្ជួន ចំពោះវិធាននានារបស់ក្រសួងសុខាភិបាល និងការប្រៀនប្រដៅរបស់ព្រះសហគមន៍ ក្នុងសេចក្តីស្រលាញ់របស់ព្រះអម្ចាស់យេស៊ូគ្រីស្ត។

លោកអភិបាលអូលីវីយេ អភិបាលភូមិភាគភ្នំពេញ បានដាស់តឿន និងអប់រំគ្រីស្តបរិស័ទឱ្យអនុវត្តជាក់ស្តែងវិធានការតាមអនុសាសន៍របស់សម្តេចតេជោ ហ៊ុន សែន ៣កុំ និង ៣ការពារ។ លោកថា លោកបានថែម៣ថែរក្សា គឺ ទី១ ទទួលខុសត្រូវ៖ ទទួលខុសត្រូវខ្ពស់ ក្នុងតួនាទីរបស់ខ្លួន ជាសិស្ស ជាគ្រូ ជាមាតាបិតា និងយើងជាប្រជារាស្ត្រម្នាក់យកចិត្តទុកដាក់សុខភាពផ្ទាល់ខ្លួន និងសុខភាពបងប្អូនដែរ។ ទី២ សាមគ្គីភាព គឺឱ្យយើងយកចិត្តទុកដាក់ចែករំលែក ធម៌មេត្តាករុណា សេចក្តីស្រលាញ់ដល់បងប្អូន។ សព្វថ្ងៃព្រះសហគមន៍កាតូលិកធ្វើច្រើនមែនណាស់ ចែកម្ហូបអាហារ និងអំណោយផ្សេងៗ ដល់បងប្អូនរងគ្រោះនិងខ្វះខាត។ ទី៣ គឺអធិដ្ឋានឱ្យបងប្អូនភ្ជាប់ជាមួយព្រះ ដើម្បីជួយឱ្យយើងយកចិត្តទុកដាក់ចូលក្នុងរួមជាមួយរាជរដ្ឋាភិបាលប្រឆាំងកូវីដ១។ ព្រះជាម្ចាស់ជាសេចក្តីស្រលាញ់ គ្រីស្តបរិស័ទត្រូវស្រលាញ់ សុខភាពខ្លួន ដោយថែរក្សាជានិច្ច និងស្រលាញ់សុខភាពបងប្អូនឯទៀតៗផងដែរ៕

CSC
Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ចាងហ្វាង : លោក លី សុវណ្ណា
សេចក្តីប្រកាសលេខ៖ ០៦០/១៩ ព.ម.រ.ល.អ/ ១៥-មករា-២០១៩
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Tel/Fax : (855) 23 224 120
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh

# ទំនាក់ទំនងការទូតកម្ពុជា-រុស្ស៊ីរយៈពេល៦៥ឆ្នាំកម្ពុជាបានទទួលផលប្រយោជន៍ជាច្រើនពីប្រទេសរុស្ស៊ី

*អត្ថបទ៖ ផល សុផានិត*





ឯកអគ្គរដ្ឋទូតសហព័ន្ធរុស្ស៊ីប្រចាំនៅកម្ពុជាបានអះអាងថា ទំនាក់ទំនងការទូតរវាងប្រទេសកម្ពុជា និងប្រទេសរុស្ស៊ីរយៈពេល៦៥ឆ្នាំមកនេះ ប្រជាជន និងប្រទេសកម្ពុជាបានទទួលផលប្រយោជន៍ជាច្រើនពីប្រទេសមហាអំណាចមួយនេះ ជាពិសេសជំនាញផ្នែកវិស័យអប់រំ សុខាភិបាល ផ្នែកកសិកម្ម និងវិស័យសន្តិសុខជាដើម។

ថ្លែងក្នុងសារពិសេសមួយតាមរយៈធ្វីតធើ ស្តីពីខួប៦៥ឆ្នាំនៃទំនាក់ទំងទ្វេភាគីរវាងកម្ពុជា-រុស្ស៊ី (១៣ឧសភា១៩៦៥ - ១៣ឧសភា ២០២១) លោកអាណាតូលី បូរ៉ូវីក(Anatoly Borovik) បានលើកឡើងថា ព្រឹត្តិការណ៍សំខាន់ៗរវាងកម្ពុជា និងប្រទេសរុស្ស៊ី ដែលបានបន្សល់ទុកជាបណ្ណសារ ហើយមានលក្ខណៈពិសេសផ្សេងៗទៀត ដែលប្រទេសរុស្ស៊ីបានជួយដល់កម្ពុជា ក្រោយរបបប្រល័យពូជសាសន៍ប៉ុល ពត ដូចជាផ្នែកមនុស្សធម៌ ក្នុងអំឡុងពេលទស្សវត្តន៍ឆ្នាំ១៩៦០ ដោយរុស្ស៊ីបានជួយកសាងមន្ទីរពេទ្យ ខ្មែរ-សូវៀត និងសាលាបច្ចេកទេសខ្ពស់ផ្សេងទៀតនៅក្នុងរាជធានីភ្នំពេញនោះ។

ជាមួយគ្នានោះដែរ លោក អាណាតូលី បូរ៉ូវីក ក៏បានថ្លែងផងដែរថា នៅក្នុងមន្ទីរពេទ្យ និងសាលាបច្ចេកទេសដែលរដ្ឋាភិបាលរុស្ស៊ីបានសាងសង់ជូនដល់កម្ពុជានោះ ក៏មាន វេជ្ជបណ្ឌិត និងគ្រូបង្រៀនសូវៀតជាច្រើនបានធ្វើការប្រកបដោយជោគជ័យអស់រយៈពេលជាច្រើនឆ្នាំ ហើយដំណាក់កាលថ្មីនៃទំនាក់ទំនងបានចាប់ផ្តើមបន្ទាប់ពីការដួលរំលំនៃរបបប៉ុល ពត ពេលប្រទេសរុស្ស៊ីបានផ្តល់ជំនួយគ្រប់បែបយ៉ាងដល់សាធារណៈរដ្ឋប្រជាមានិតកម្ពុជាដែលកំពុងជួបការលំបាកក្នុងការស្តារខ្លួនឯងឡើងវិញនោះ។

បើតាមការលើកឡើងរបស់អនុរដ្ឋមន្ត្រីនៃសហព័ន្ធរុស្ស៊ីលោក Igor_Morgulov បានថ្លែងថា នៅក្នុងខួបអនុស្សាវរីយ៍រយៈពេល៦៥ឆ្នាំ នៃទំនាក់ទំនងកម្ពុជា-រុស្ស៊ីនេះដែរ ប្រមុខការទូតកម្ពុជា និងរុស្ស៊ី ក៏បានផ្ញើរអប់អរសាទរគ្នាទៅវិញទៅមកផងដែរ ដោយក្នុងសារទាំងនោះភាគីទាំងពីរបានសន្យាបន្តពង្រឹងកិច្ចសហប្រតិបត្តិការណ៍ទ្វេភាគីនៃប្រទេសទាំងពីរឲ្យកាន់តែល្អប្រសើបន្ថែមទៀតទាំងពាណិជ្ជកម្ម និងវិនិយោគ។

លោក Igor_Morgulov បានបញ្ជាក់ទៀតថាប្រទេសទាំងពីរ(កម្ពុជា-រុស្ស៊ី)ក៏បានធ្វើការតាំងពិពណ៌តាមរយៈប្រព័ន្ធអនឡាញ ដោយមានឯកសារ និងរូបថតជាច្រើន ដែលក្នុងការតាំងពិពណ៌នោះភាគច្រើននិយាយ អំពីការផ្តល់ជំនួយសេដ្ឋកិច្ច និងបច្ចេកទេសជាអាទិភាពដល់កម្ពុជា ជាពិសេសការលើកឡើងអំពីមន្ទីរពេទ្យ និងសាលារៀន វិទ្យាស្ថានកសិកម្ម ផ្លូវថ្នល់ ស្ពាន និងកំពង់ផែកំពង់សោម (បច្ចុប្បន្នព្រះសីហនុ)។ ដោយមានជំនួយរបស់រុស្ស៊ី ការផ្គត់ផ្គង់ថាមពលអគ្គិសនីនៃទីក្រុងធំបំផុតត្រូវបានបង្កើតឡើងវិញ ក្រៅពីនោះមានការសាងនូវស្ថានីយ៍ទូរស័ព្ទ ប្រព័ន្ធធារាសាស្ត្រ និងអគារជាច្រើនទៀត។

លោកអនុរដ្ឋមន្ត្រីបានបន្ថែមទៀតដែរថា នៅដំណាក់កាលបច្ចុប្បន្ន ចំណងមិត្តភាពរុស្ស៊ី-កម្ពុជា មានប្រកបដោយការជឿទុកចិត្តគ្នា និងកិច្ចសហប្រតិបត្តិការជាស្ថាបនា។ ព្រោះវាឈរលើគ្រឹះនៃការចុះហត្ថលេខាលើសេចក្តីប្រកាសរួមនៅក្នុងឆ្នាំ១៩៩៥ ស្តីពីមូលដ្ឋានគ្រឹះនៃទំនាក់ទំនងមិត្តភាព។ ការសន្ទនានយោបាយកំពុងអភិវឌ្ឍយ៉ាងសកម្មរួមទាំងលើកម្រិតខ្ពស់និង ខ្ពស់បំផុត។ អន្តរកម្មដ៏ជិតស្និតត្រូវបានបង្កើតឡើងរវាងក្រសួងការបរទេស ហើយមាន ការអន្តរកម្មយ៉ាងសកម្មតាមរយៈសភា គណបក្សនយោបាយ យុវជន អង្គការសាសនា និងស្ថាប័នសន្តិសុខជាដើម។

យ៉ាងណាក៏ដោយរុស្ស៊ីបានសន្យាថា ខ្លួនកំពុងខិតខំប្រឹងប្រែងជំរុញកិច្ចសហប្រតិបត្តិការក្នុងវិស័យពាណិជ្ជកម្ម និងការវិនិយោគ វិទ្យាសាស្ត្របច្ចេកទេស វប្បធម៌ និងមនុស្សធម៌។ ខ្ញុំជឿជាក់ថា បទពិសោធន៍ប្រវត្តិសាស្ត្រដ៏សំបូរបែប ដែលប្រមូលបានក្នុងរយៈពេលជាង៦ទស្សវត៌កន្លះ និងជួយស្វែងរកឱកាសថ្មីៗដើម្បីពង្រឹងមិត្តភាពជាប្រពៃណី បង្កើនកិច្ចសហប្រតិបត្តិការជាក់ស្តែង និងការផ្លាស់ប្តូរគ្នាមានប្រយោជន៍ទៅវិញទៅមក ដើម្បីជាផលប្រយោជន៍ដល់ប្រជាជនប្រទេសទាំងពីរ ក្នុងផលប្រយោជន៍ធានា ស្ថេរភាព សន្តិសុខ និងការអភិវឌ្ឍ ប្រកបដោយចីរភាព នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក និងពិភពលោកទាំងមូលផងដែរនេះបើតាមការលើកឡើងបន្ថែមរបស់លោក Igor_Morgulov៕

# កម្ពុជានឹងចូលរួមការប្រកួតកីឡាប្រ្វង់កូហ្វូនីលើកទី៩ ជាមួយបណ្តាប្រទេស៩០ដែលនិយាយភាសាបារាំង

*អត្ថបទ៖ ផល សុផានិត*

ព្រះរាជាណាចក្រកម្ពុជា ក្នុងចំណោមប្រទេសជាង៥០ជុំវិញពិភពលោក ដែលនិយាយភាសាបារាំង នឹងចូលរួមប្រកួតកីឡាហ្វ្រង់កូហ្វូនីលើកទី៩ នៅសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោនាឆ្នាំ២០២២ខាងមុខនេះ។

លោក ឈឹម សុធី បន្តថា គណៈកម្មការរៀបចំចូលរួមការប្រកួតកីឡាហ្វ្រង់កូហ្វូនីលើកទី៩ សូមជូនដំណឹងដល់សិល្បករ វិចិត្រករ និងសាធារណជនទូទៅថា គណៈកម្មាធិការអន្តរជាតិរៀបចំការប្រកួតកីឡាហ្វ្រង់កូហ្វូនី (ហៅកាត់ CIJF) នឹងប្រារព្ធការប្រកួតកីឡាហ្វ្រង់កូហ្វូនីលើកទី៩ លើវិញ្ញាសារវប្បធម៌ និងវិញ្ញាសាកីឡា ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៩ ដល់ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២២ នៅទីក្រុង Kinshasa(គឺសាសា)នៃសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ។

គណៈកម្មការរៀបចំចូលរួមការប្រកួតកីឡាហ្វ្រង់កូហ្វូនីលើកទី៩ នឹងរៀបចំកម្មវិធីប្រកួតប្រជែងជ្រើសរើសស្នាដៃ និងបេក្ខភាពលើវិញ្ញាសាសិល្បៈ ដើម្បីបញ្ជូនទៅចូលរួមប្រកួតប្រជែងក្នុងគោលបំណងដណ្តើមយកមេដាយ មាស ប្រាក់ និងសំរិទ្ធ លំដាប់អន្តរជាតិ នៃការប្រកួតនេះ។

លោក ឈឹម សុធី អនុប្រធានគណៈកម្មការរៀបចំការប្រកួតកីឡាហ្វ្រង់កូហ្វូនីលើកទី៩...ជូនកាលរយៈពេល២ឆ្នាំម្តង ៣ឆ្នាំម្តង ៤ឆ្នាំម្តងទៅតាមប្រទេសដែលជាម្ចាស់នៃការរៀបចំកម្មវិធីកីឡា ហើយនឹងសិល្បៈហ្វ្រង់កូហ្វូ ជាប្រទេសដែលនិយាយភាសាបារាំង។ ក្នុងនោះមានជាង៥០ប្រទេស មកពីជុំវិញពិភពលោក។ ក្នុងនោះមានការប្រកួតកីឡាគ្រប់ប្រភេទ ហើយផ្នែកសិល្បៈ មានតន្ត្រី មានរបាំ មានចម្រៀង មានគំនូរ មានចម្លាក់គ្រប់ប្រភេទ និងរូបថតជាដើម។

បារាំង ជួយលើកស្ទួយវិស័យសិល្បៈវប្បធម៌ និងកីឡា ហើយក៏ជាការលើកស្ទួយនៃភាសាបារាំងរបស់ខ្លួន ដើម្បីកុំឲ្យភាសាបារាំងបាត់បង់ ព្រោះអីភាសាបារាំង មានការប្រើច្រើន។ ដូច្នេះ បារាំង ដែលជាប្រទេសផ្ទាល់នោះ ក៏គេមិនចង់ឲ្យបាត់ភាសារបស់គេដែរ គឺគេចង់ឲ្យផ្សព្វផ្សាយភាសា និងអារ្យធម៌ និងភាសានៅលើពិភពលោកឲ្យបានវែង ដោយសារបារាំង ក៏ធ្លាប់ជាប្រទេសដែលមានអំណាច និងជាប្រទេសអាណានិគមនៅក្នុងពិភពលោកមួយផងដែរ។ ដូច្នេះឲ្យមានការសហការគ្នា ឯកភាពគ្នាជាមិត្តភាពជាភាតរភាព ដើម្បីឲ្យមានកិច្ចការរៀបចំព្រឹត្តិការណ៍វែងរហូតតទៅ។

លោក បានបញ្ជាក់ទៀតថា នីតិវិធីក្នុងការចូលរួម សិល្បករ សិល្បការិនី ត្រូវមានអាយុចាប់ពី១៨ឆ្នាំ ដល់៣៥ឆ្នាំ គិតត្រឹមថ្ងៃប្រកួត និងរាល់ស្នាដៃសិល្បៈទាំងអស់ជាស្នាដៃបង្កើតថ្មី ហើយពុំធ្លាប់បានដាក់តាំងបង្ហាញពីមុន។ សិល្បករ វិចិត្រករ និងបេក្ខភាពត្រូវបានកំណត់ចំនួនទៅតាមប្រភេទវិញ្ញាសា (មានចំណេះដឹងភាសាបារាំង ត្រូវបានលើកទឹកចិត្ត)។ វិញ្ញាសាចូលរួមប្រកួតដូចជា៖ ផ្នែកគំនូរវិចិត្រកម្ម (១នាក់), ផ្នែកចម្លាក់ (១នាក់), ផ្នែករូបថត (១នាក់), សិល្បៈវីដេអូ (១នាក់), របាំសហសម័យ (មិនលើសពី១០នាក់ ក្នុង១ក្រុម) និងចម្រៀងជាភាសាបារាំង (មិនលើសពី៨នាក់ ក្នុង១ក្រុម)៕

# អាជ្ញាធរជាតិអប្សរារកឃើញទបង្ហូរទឹកបុរាណ នៅព្រះលានជល់ដំរី

*អត្ថបទ៖ អមរិទ្ធ ដានុត*

ក្រុមបុរាណវិទូបានប្រទះឃើញនូវរចនាសម្ព័ន្ធបុរាណជាច្រើនដូចជាប្រព័ន្ធផ្លូវ ប្រព័ន្ធចង្ហូរទឹកនៅអមផ្លូវពីមុខព្រះបរមរាជវាំងទៅខ្លោងទ្វារជ័យ ព្រមទាំងរចនាសម្ពន្ធសំណង់ផ្សេងៗជាច្រើនទៀត។

ការអនុវត្តគម្រោងកែលម្អផ្លូវដើរ ដាំស្មៅ និងប្រព័ន្ធរំដោះទឹកនៅបរិវេណព្រះលានជល់ដំរីក្នុងក្រុងអង្គរធំ ការសិក្សាអំពីផលប៉ះពាល់បុរាណវិទ្យាគឺជាផ្នែកមួយយ៉ាងសំខាន់ដើម្បីស្វែងយល់ពីរចនាសម្ព័ន្ធ និងដំណាក់កាលនៃការរៀបចំទីធ្លាដែលប្រើប្រាស់នៅមុខព្រះបរមរាជវាំង និងការវិវឌ្ឍរបស់រចនាសម្ព័ន្ធបុរាណផ្សេងៗ ដែលនៅក្រោមដីទៅតាមយុគសម័យនីមួយ។






យោងតាមអាជ្ញាធរជាតិអប្សរា បានឱ្យដឹងថា ក្រុមបុរាណវិទូបានរកឃើញទបង្ហូរ (លូបង្ហូរទឹក) បុរាណមួយបន្ថែមទៀត នៅខាងជើងផ្លូវចុះកណ្តាលនៃខឿនព្រះលានជល់ដំរីបន្តិច ដែលបុព្វបុរសស្ថាបនាឆ្លងកាត់ផ្លូវទទឹងថ្ងៃ (ផ្លូវចេញពីប្រាសាទបាយ័ន្តទៅខ្លោងទ្វារដីឆ្នាំង) នៃក្រុងអង្គរធំ។ ព្រមទាំងមានស្នាមដានជើងសសរឈើ ដែលបញ្ជាក់ថាមានសំណង់អំពីឈើឬហៅថារោងទោងអំពីឈើប្រក់ក្បឿងនៅតាមបណ្តោយផ្លូវប្រវែងជិត៨០ម៉ែត្រ។

លោក ខៀវ ច័ន្ទ បុរាណវិទូនិងជាអ្នកទទួលខុសត្រូវការដ្ឋានកំណាយបានសន្និដ្ឋានថា នេះជាដំណាក់កាលដំបូងនៃព្រះបរមរាជវាំង ប្រហែលជារាជព្រះបាទយសោវរ្ម័ន (ទី១) ពេលដែលផ្លាស់រាជធានីពីរលួសមកអង្គរដែលយកភ្នំបាខែងជាចំណុចកណ្តាលនៃក្រុងយសោធរបុរី។



ចំពោះទបង្ហូរទឹក (លូបង្ហូរទឹក) បុរាណដែលទើបរកឃើញថ្មីនេះ លោក ខៀវ ច័ន្ទ បញ្ជាក់ថា បានស្ថាបនាឡើងដោយយកថ្មបាយក្រៀមធ្វើជាជញ្ជាំងសងខាង និងថ្មភក់ធ្វើជាគម្របពីលើ មានកម្ពស់ជិតកន្លះម៉ែត្រនិងទទឹងមុខសម្រាប់ទឹកហូរ០,២ម៉ែត្រនិងមានបណ្តោយ៦ម៉ែត្រ ដើម្បីរំដោះទឹកចេញពីមុខព្រះបរមរាជវាំង ចូលទៅក្នុងប្រព័ន្ធប្រឡាយធំខាងកើតដែលនៅរបផ្លូវទៅខ្លោងទ្វារជ័យ ហើយហូចូលទៅបឹងធំដែលស្ថិតនៅទិសនិរតី និងធ្លាក់ទៅក្នុងសិន្ធុអង្គរធំតាមរន្ធត្រដេវ។

លោកបញ្ជាក់ទៀតថា៖ «បើផ្អែកលើសមុច្ច័យដែលបានរកឃើញនៅក្នុងស្រទាប់ដីនីមួយៗ គេអាចសន្និដ្ឋានជាបឋមបានថា ទបង្ហូរទឹកបុរាណនេះអាចស្ថាបនាឡើងនៅក្នុងរាជព្រះបាទជ័យវរ្ម័នទី៧ ក្នុងពេលដែលព្រះអង្គបានរៀបចំក្រុងអង្គរធំឱ្យមានប្រព័ន្ធផ្លូវនិងប្រព័ន្ធប្រឡាយទឹកខ្វាត់ខ្វែងជាក្រឡាចត្រង្គពាសពេញក្រុង ដោយមានរន្ធត្រដេវនៅទិសឦសានសម្រាប់បញ្ចូលទឹកមកក្នុងក្រុង និងរន្ធត្រដេវនៅទិសនិរតីសម្រាប់បង្ហូរទឹកចេញពីក្រុងទៅសិន្ធុខាងក្រៅធ្លាក់ទៅបឹងទន្លេសាប»។

ក្រៅពីនេះព្រះអង្គក៏បានស្ថាបនាកំពែងថ្មបាយក្រៀមព័ទ្ធជុំវិញក្រុងដែលមានទំហំ៣គីឡូម៉ែត្របួនជ្រុងផងដែរ។ ព្រះលាននេះ ត្រូវបានសាងឡើងនៅចុងសតវត្សទី១២ដោយព្រះបាទជ័យវរ្ម័នទី៧ ក្នុងរចនាបទបាយ័ន្ត។ នៅទីនេះ បុព្វបុរសខ្មែរបានសាងខឿនខ្ពស់ផុតពីដីមួយជួរវែង លាតសន្ធឹងតាមបណ្តោយកំពែងរាជវាំងខាងកើត លយហួសទៅជើង និងហួសទៅត្បូង ដែលមានរានហាលចំនួនបីនិងមានពីរជាន់។ នៅលើខឿននេះដើមឡើយមានអគារសាងពីឈើប្រក់ក្បឿង តែសព្វថ្ងៃយើងមើលមិនឃើញទេ ឃើញតែស្លាកស្នាមថ្មនៅខាងក្រោមប៉ុណ្ណោះ។

គួរបញ្ជាក់ដែរថា នៅក្នុងក្រុងអង្គរធំមានអាងស្តុកទឹកចំនួន៣គឺ បឹងតាតួតនៅទិសឦសាន្ត បឹងដូនមានៅខាងលិចព្រះបរមរាជវាំង និងបឹងធំនៅទិសនិរតី៕

# លោកញឹក ប៊ុនឆៃ គាំទ្រវិធានការរបស់រាជរដ្ឋាភិបាលដើម្បីទប់ស្កាត់ការឆ្លងរីករាលដាល នៃជំងឺកូវីដ-១៩



*អត្ថបទ៖ ព្រះសហគមន៍កាតូលិក*

លោកញឹក ប៊ុនឆៃ ប្រធានគណបក្សខ្មែររួបរួមជាតិ នារសៀលថ្ងៃទី ១៧ ខែឧសភានេះ បានប្រាប់ អ្នកនាំសារ ថា លោកគាំទ្រចំពោះការចាត់វិធានការរបស់រាជរដ្ឋាភិបាលក្នុងការបិទខ្ទប់រាជធានីភ្នំពេញ និងតាមបណ្តាខេត្តមួយចំនួន ដើម្បីទប់ស្កាត់កុំឲ្យមានការឆ្លងរីករាលដាលនៃជំងឺកូវីដ១៩ ។

លោកថា បើបណ្តែតបណ្តោយឲ្យអ្នកដែលមានជំងឺកូវីដ១៩ ធ្វើដំណើរពីតំបន់មួយទៅតំបន់មួយ គឺវានឹងធ្វើឲ្យមានការឆ្លងរីករាលដាលកាន់តែច្រើនឡើងៗ ហេតុនេះអ្វីដែលរាជរដ្ឋាភិបាលធ្វើនេះ គឺជាការត្រឹមត្រូវបើទោះបីមានការខ្វះចន្លោះខ្លះ ដែលធ្វើឲ្យពលរដ្ឋមួយចំនួនមិនសប្បាយចិត្ត។

លោកញឹក ប៊ុនឆៃ បានលើកឡើងទៀតថា លោកគាំទ្រក្នុងការចាត់វិធានការរបស់រាជរដ្ឋាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩ ហើយបើបណ្តែតបណ្តោយឲ្យអ្នកដែលនៅតំបន់ក្រហមដែលមានជំងឺកូវីដ១៩ ចេញដើរពីកន្លែងមួយទៅកន្លែងមួយ ធ្វើឲ្យការឆ្លងរីករាលដាលកាន់តែច្រើនឡើងៗ សូម្បីតែមានការបិទខ្ទប់ក៏ការឆ្លងរាលដាលនៅតែមានច្រើន។

លោកញឹក ប៊ុនឆៃ មានប្រសាសន៍ថា ៖ «ដោយសាររាជរដ្ឋាភិបាលមានវិធានការទាន់ពេលវេលា បានធ្វើឲ្យការឆ្លងរាលដាលជំងឺកូវីដ១៩ ក៏វាមានកម្រិតមួយ មិនមានការឆ្លងរាលដាលខ្លាំង ដោយសារតែមានវិធានការក្នុងការទប់ស្កាត់ ហើយរាជរដ្ឋាភិបាលអនុវត្តគោលការណ៍នេះ គឺបានល្អក្នុងការទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ១៩»។

លោកបានបន្តថា នៅក្នុងដំណាក់កាលនៃការឆ្លងរាលត្បាតជំងឺកូវីដ១៩ គណបក្សខ្មែររួបរួមជាតិ ក៏បានចូលរួមចំណែកជាមួយរដ្ឋាភិបាលក្នុងការចែកស្បៀងដល់ប្រជាពលរដ្ឋដែលជួយការលំបាកទៅតាមលទ្ធភាពដែលមាន។ ដោយក្នុងនោះលោកបានចុះចែកស្បៀងដល់បុគ្គលិកមន្ទីរពេទ្យបង្អែក និងប្រជាពលរដ្ឋនៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ ស្បៀងទាំងនោះមាន អង្ករចំនួន១០តោន ទឹកស៊ីអ៊ីវចំនួន១៥០០ដប ទឹកត្រីចំនួន១៥០០ដប និងត្រីខចំនួន ១៥០០កំប៉ុង ព្រមទាំងថវិការសម្រាប់បុគ្គលិកពេទ្យ ចំនួនជិត២០០នាក់ ក្នុងម្នាក់ទទួលបានថវិកា ៤០០០០រៀល និងសម្រាប់ប្រជាពលរដ្ឋចំនួន ២០០០០ រៀល។

សម្រាប់មន្ទីរពេទ្យទីពីរ គឺមន្ទីរពេទ្យយោធភូមិភាគ៤ មាននូវ អង្ករចំនួន ៨តោន ទឹកស៊ីអ៊ីវចំនួន ១២០០ដប ទឹកត្រី ១២០០ដប ត្រីខចំនួន ២០០០កំប៉ុង និងមីចំនួន២០០០កញ្ចប់ ចែកជូនបុគ្គលិកមន្ទីរពេទ្យ និងប្រជាពលរដ្ឋដែលកំពុងសម្រាកនៅមន្ទីរពេទ្យ សរុបជាថវិការចំនួន ៨លានរៀល។

ជាមួយគ្នានេះដែរលោក ញឹកប៊ុនឆៃ ក៏មានការចែកស្បៀងដល់ប្រជាពលរដ្ឋខ្វះខាតចំនួន១៧០គ្រួសារ នៅភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញផងដែរ ដែលក្នុងមួយគ្រួសារទទួលបានអង្ករចំនួន ២៥គីឡូក្រាម និងមានទឹកត្រី ទឹកស៊ីអ៊ីវ ត្រីខ និងមីរួមទាំងថវិកាផងដែរ។

ការចែកស្បៀងរបស់ប្រធានគណបក្សរូបនេះ ក៏បានផ្តល់ជូនដល់កម្មករចំនួន ២០គ្រួសារ នៅឃុំត្រពាំងល្វា ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ ក្នុងមួយគ្រួសារទទួលបានអង្ករចំនួន ២៥គីឡូក្រាម ទឹកត្រី ទឹកស៊ីអ៊ីវ ត្រីខ និងមី រួមទាំងថវិកា ៣០០០០រៀល។

លោក ញឹក ប៊ុនឆៃ មានប្រសាសន៍ថា ៖ «ចំពោះកិច្ចការនយោបាយទាក់ទិននឹងដំណើរការបង្រួបបង្រួមគ្នា រវាងគណបក្សខ្មែររួបរួមជាតិ និងគណបក្សហ្វ៊ុនស៊ិនប៉ិច របស់សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ គឺកំពុងតែមានដំណើរការទៅមុខយ៉ាងរលូន ក្រោយពីមានការអាក់ខានមួយរយៈ»។

លោក ញឹក ប៊ុនឆៃ មានសុទិដ្ឋិនិយមថានឹងមានលទ្ធផលឆាប់ៗ មុនការរៀបចំបោះឆ្នោត ឆ្នាំ២០២។ លោកបញ្ជាក់ថា ៖ «យើងនៅសល់រយៈពេលខ្លីណាស់មានការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ យើងត្រូវញាប់ដៃញាប់ជើងជំរុញធ្វើយ៉ាងណាឲ្យដំណើរបង្រួបបង្រួមបានចេញឆាប់រហ័សបំផុត»។

លោកថា ការសម្របសម្រួលលើក្បាលម៉ាស៊ីនដឹកនាំ ជាចំនុចសំខាន់ដែលលោកកំពុងរៀបចំ ហើយការជជែកគ្នាមានដំណើរការល្អគ្មានឧបសគ្គអ្វីនោះទេ។ លោកថា ៖ «មិនយូរទេនឹងចេញជារូបរាងក្នុងការបង្រួបបង្រួមគ្នានេះ ដើម្បីឲ្យយើងបានចូលរួមបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០២២ និងឈានទៅចូលរួមការបោះឆ្នោតសាកលតែម្តង ឆ្នាំ២០២៣»។

ជាមួយគ្នានេះដែរលោក ប្រធានគណបក្សខ្មែររួបរួមជាតិរូបនេះ ក៏បានបង្ហើបឲ្យដឹងដែរថា មានគណបក្សមួយចំនួនទៀតក៏នឹងចូលរួមក្នុងការរួបរួមគ្នានេះដែរ ហើយអតីតសមាជិកគណបក្សសង្គ្រោះជាតិមួយចំនួន ដែលជាសមាជិកគណបក្សហ្វ៊ុនស៊ិនប៉ិចពីមុនក៏នឹងចូលរួមជាមួយលោកដែរ៕

# អង្គការអុកស្វាម បើកយុទ្ធនាការ២ខែស្តីពី «កិច្ចគាំពារមាតុភាព» ក្នុងទិវាពលកម្មអន្តរជាតិ ឆ្នាំ២០២១

*អត្ថបទ៖ អមរិន្ទ ដានុត*

ដើម្បីបង្កើនការយកចិត្តទុកដាក់ទៅដល់កម្មការិនីនៅតាមវិស័យនានា ជាពិសេសនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលជារឿយៗពុំទាន់ត្រូវបានគេគិតគូរពេញលេញនៅឡើយ ទាំងនៅប្រទេសកម្ពុជា និងតំបន់អាស៊ាន។

នៅក្នុងឱកាសទិវាពលកម្មអន្តរជាតិលើកទី១៣៥នាឆ្នាំនេះ អង្គការអុកស្វាម និងដៃគូនៅកម្ពុជា ឡាវ និងវៀតណាម បានរួមគ្នារៀបចំយុទ្ធនាការមួយស្តីពី «កិច្ចគាំពារមាតុភាព» មួយក្នុងគោលបំណងលើកកម្ពស់ការយកចិត្តទុកដាក់ និងដោះស្រាយលើរាល់បញ្ហាប្រឈមរបស់កម្មការិនីនៅក្នុងវិស័យនេះ ដើម្បីទទួលបានកិច្ចគាំពារមាតុភាពពេញលេញ និងសមស្រប។

យុទ្ធនាការនេះមានរយៈពេល២ខែ ធ្វើឡើងតាមប្រព័ន្ធអនឡាញ ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹង អំពីបញ្ហាប្រឈម និងតម្រូវការរបស់កម្មការនី ក្នុងការទទួលបានអត្ថប្រយោជន៍កិច្ចគាំពារមាតុភាព។

នៅក្នុងប្រទេសកម្ពុជា ស្ត្រីប្រមាណជាង៩០% ក្នុងវិស័យការងារមិនទាន់បានទទួល កិច្ចគាំពារមាតុភាពនៅឡើយទេ ដោយសារស្ថានភាពការងារក្រៅប្រព័ន្ធរបស់ពួកគេ។ តាមរយៈយុទ្ធនាការនេះ អង្គការអុកស្វាម និងដៃគូមានគោលបំណងជាក់លាក់ដើម្បីលើកកម្ពស់ការយល់ដឹង ជាពិសេសក្នុង កម្រិតអ្នកបង្កើតគោលនយោបាយថ្នាក់ជាតិ អំពីតម្រូវការបន្ទាន់ដែលមាននៅក្នុងបទប្បញ្ញត្តិស្តីពី កិច្ច គាំពារមាតុភាពសម្រាប់កម្មការនី និងស្ត្រីជានយោជិកទាំងអស់ ហើយជាពិសេសនោះគឺស្ត្រីកម្មករ ក្រៅប្រព័ន្ធ។

លោកស្រី លឹម សូលីន នាយិកាអង្គការអុកស្វាមមានប្រសាសន៍ថា៖ «កិច្ចគាំពារមាតុភាព គឺជាសិទ្ធិមូលដ្ឋាន និងសិទ្ធិនៅក្នុងរដ្ឋធម្មនុញ្ញ ហើយកិច្ចគាំពារនេះ គឺជាការចាំបាច់ណាស់ ក្នុងការសម្រេច បាននូវសមភាពយេនឌ័រ សុខុមាលភាព និងសុខភាពរបស់ម្តាយ និងកូន ក៏ដូចជាក្នុងការទទួលបានឱកាស និងភាពស្មើគ្នាក្នុងវិស័យការងាររវាងស្ត្រី និងបុរស ក៏ដូចជាពលរដ្ឋក្នុងក្រុមផ្សេងៗផងដែរ»។

របាយការណ៍របស់ធនាគារពិភពលោកឆ្នាំ២០២០ បានឱ្យដឹងថា ស្ត្រីដែលស្ថិតនៅក្នុងវ័យសកម្មក្នុងការពរពោះនៅចន្លោះពីអាយុ ២៥ឆ្នាំដល់៣៤ឆ្នាំ ហាក់មានចំនួនច្រើនលើសលប់នៅក្នុង ចំណោមអ្នកមានជីវភាពខ្វះខាត។ សម្រាប់ប្រទេសកម្ពុជា ស្ត្រីចំណាយពេលជាមធ្យម ៣.៥ ម៉ោង ច្រើនជាងបុរសទៅលើការមើលថែកូនដោយមិនទទួលបានប្រាក់ចំណូល និងការងារផ្ទះ សូម្បីតែអំឡុងមានផ្ទៃពោះ និងមាតុភាពក៏ដោយ ហើយជាពិសេសក្នុងអំឡុងពេលនៃជំងឺរាតត្បាតកូវីដ១៩តែម្តង។

អគ្គលេខាធិការនៃក្រុមប្រឹក្សាជាតិគាំពារសង្គម (GS-NSPC) លោក ចន ណារិទ្ធ បានលើកឡើងថា ក្រុមប្រឹក្សាជាតិគាំពារសង្គម ទទួលស្គាល់នូវសារៈសំខាន់នៃកិច្ចគាំពារមាតុភាព ដែល ជាកត្តាដ៏សំខាន់ក្នុងការដោះស្រាយវិសមភាពយេនឌ័រ និងកាត់បន្ថយភាពងាយរងគ្រោះរបស់ស្ត្រី និងគ្រួសារ។

លោកមានប្រសាសន៍ថា ៖ «កិច្ចគាំពារមាតុភាព ជាពិសេសសម្រាប់គ្រួសារក្រីក្រ និងងាយរងគ្រោះ ដែលពេលបច្ចុប្បន្ននេះ ស្ថិតនៅក្នុងរបៀបវារៈដ៏ចម្បងនៃកិច្ចគាំពារសង្គមរបស់រាជរដ្ឋាភិបាលកម្ពុជាផងដែរ ដែលមានដូចជា *កម្មវិធីផ្ទេរ ប្រាក់សម្រាប់ស្ត្រីមានផ្ទៃពោះ និងកុមារតូច»។ លោក ចន ណារិទ្ធ បានបញ្ជាក់ថា ក្រុមប្រឹក្សាជាតិគាំពារសង្គមកំពុងធ្វើការពង្រឹងបន្ថែមទៀត ក្នុងការសម្របសម្រួល និងធ្វើឱ្យមានភាព សុខដុមនីយកម្មនៃគោលនយោបាយ និងបទប្បញ្ញត្តិនានា ដើម្បីធានាថា ស្ត្រីទាំងអស់ ទាំងនៅក្នុង វិស័យការងារក្នុងប្រព័ន្ធក្តី និងក្រៅប្រព័ន្ធក្តី សុទ្ធតែអាចទទួលបាននូវកិច្ចគាំពារសង្គម។

លោកបន្ថែមថា ៖ «យើងទទួលស្គាល់ នូវតួនាទីសំខាន់របស់ភាគីពាក់ព័ន្ធទាំងអស់ រួមទាំងសង្គមស៊ីវិលផងក្នុងកិច្ចបន្តសហការដើម្បីធានាថា ម្តាយគ្រប់ៗរូបទទួលបាននូវអត្ថប្រយោជន៍ពេញលេញ ពីកម្មវិធីកិច្ចគាំពារសង្គម ដែលនឹងផ្តល់ឱ្យស្ត្រីមាន ឱកាសបន្តចូលរួមចំណែកក្នុងការអភិវឌ្ឍប្រទេសកម្ពុជាផងដែរ»។

ជាមួយគ្នានេះដែរ លោក ថៃ ឈុនហាក់ អគ្គនាយកសមភាពយេនឌ័រ និងអភិវឌ្ឍសេដ្ឋកិច្ចនៃក្រសួងកិច្ចការនារី មានប្រសាសន៍ថា៖ «កិច្ចគាំពារមាតុភាព គឺជាតម្លៃរបស់មនុស្សទូទៅ និងជាមូលដ្ឋាន នៃសមភាពយេនឌ័រ និងសេដ្ឋកិច្ចដែលគិតគូរលើការគាំពារនិងថែទាំ។ នៅក្នុងប្រទេសកម្ពុជា ការចូលរួមនៃ កម្លាំងពលកម្មស្ត្រីកំពុងតែមានការកើនឡើងជាលំដាប់ ហើយតម្រូវការកិច្ចគាំពារមាតុភាពកាន់តែមាន សារៈសំខាន់ និងត្រូវយកចិត្តទុកដាក់សម្រាប់គ្រប់ៗគ្នា»។

ក្រសួងកិច្ចការនារី តាមរយៈផែនការយុទ្ធសាស្ត្រ នារីរតនទី៥ ឆ្នាំ២០១៩ -២០២៣ បានប្តេជ្ញាចិត្តក្នុងការលើកកម្ពស់ការយកចិត្តទុកដាក់ និងការទទួលខុស ត្រូវពីគ្រប់មជ្ឈដ្ឋានលើរបៀបវារៈនេះ។ យើងបន្តធ្វើការជាមួយដៃគូពាក់ព័ន្ធ អង្គការសង្គមស៊ីវិល និងវិស័យឯកជនដើម្បីប្រែក្លាយគុណតម្លៃរបស់យើងទៅជាសកម្មភាព ប្រែក្លាយគោលនយោបាយកាន់តែប្រកបដោយបរិយាបន្ន និងបង្កើតបរិយាកាសឲ្យស្ត្រីបានអនុវត្តនូវសិទ្ធិ និងជម្រើសរបស់ខ្លួនឲ្យបាន កាន់តែពេញលេញ។

អង្គការអុកស្វាមបានធ្វើការអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជា ធ្វើការពិចារណា លើសង្គតិភាពច្បាប់ និងគោលនយោបាយឱ្យបានប្រសើរ និងពេញលេញដោយស្របទៅតាមអនុសញ្ញា ការពារមាតុភាពលេខ១៨៣ (២០០០) ដែលចងក្រងជាគោលការណ៍គំរូចំនួន៥ផ្នែកធំៗ រួមមាន ការសម្រាកមាតុភាព អត្ថប្រយោជន៍ផ្នែកប្រាក់គាំពារ និងវេជ្ជសាស្ត្រ ការការពារសុខភាពនៅកន្លែងធ្វើការសម្រាប់ម្តាយ និងទារក អំឡុងពេលមានផ្ទៃពោះ និងអំឡុងពេលបំបៅដោះ ការការពារ និងការមិនរើសអើង ចំពោះការងារ និងការបំបៅកូន៕

OXFAM

**សេចក្តីប្រកាសព័ត៌មាន**

*Embargoed until Friday 30, 2021, 00.01am*

**អង្គការអុកស្វាម បើកយុទ្ធនាការស្តីពី កិច្ចគាំពារមាតុភាព ក្នុងទិវាពលកម្មអន្តរជាតិ**

ភ្នំពេញថ្ងៃទី៣០ ខែមេសា ឆ្នាំ ២០២១៖ ដើម្បីបង្កើនការយកចិត្តទុកដាក់ទៅដល់កម្មការនីនៅតាមវិស័យនានា ជាពិសេសនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធដែលជារឿយៗពុំទាន់ត្រូវបានគេគិតគូរពេញលេញនៅឡើយទាំងនៅប្រទេសកម្ពុជា និងតំបន់អាស៊ាន នៅក្នុងឱកាសទិវាពលកម្មអន្តរជាតិ**លើកទី១៣៥**នាឆ្នាំនេះ អង្គការអុកស្វាម និងដៃគូនៅកម្ពុជា ឡាវ និងវៀតណាម បានរួមគ្នារៀបចំយុទ្ធនាការ "**កិច្ចគាំពារមាតុភាព**" មួយក្នុងគោលបំណងលើកកម្ពស់ការយកចិត្តទុកដាក់ និងដោះស្រាយលើរាល់បញ្ហាប្រឈមរបស់កម្មការនីនៅក្នុងវិស័យខាងលើនេះ ដើម្បីទទួលបានកិច្ចគាំពារមាតុភាពពេញលេញ និងសមស្រប។ យុទ្ធនាការនេះមានរយៈពេល២ខែ ធ្វើឡើងតាមប្រព័ន្ធអនឡាញ ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងអំពីបញ្ហាប្រឈម និងតម្រូវការរបស់កម្មការនី ក្នុងការទទួលបានអត្ថប្រយោជន៍កិច្ចគាំពារមាតុភាព។

នៅក្នុងប្រទេសកម្ពុជា ស្ត្រីប្រមាណជាង៩០% ក្នុងវិស័យការងារមិនទាន់បានទទួលកិច្ចគាំពារមាតុភាពនៅឡើយទេ ដោយសារស្ថានភាពការងារក្រៅប្រព័ន្ធរបស់ពួកគេ។ តាមរយៈយុទ្ធនាការនេះ អង្គការអុកស្វាម និងដៃគូមានគោលបំណងជាក់លាក់ដើម្បីលើកកម្ពស់ការយល់ដឹង ជាពិសេសក្នុងកម្រិតអ្នកបង្កើតគោលនយោបាយថ្នាក់ជាតិ អំពីតម្រូវការបន្ទាន់ដែលមាននៅក្នុងបទប្បញ្ញត្តិស្តីពី កិច្ចគាំពារមាតុភាពសម្រាប់កម្មការនី និងស្ត្រីជានយោជិកទាំងអស់ ហើយជាពិសេសនោះគឺស្ត្រីកម្មករក្រៅប្រព័ន្ធ។

**លោកស្រី លឹម សូលីន** នាយិកាអង្គការអុកស្វាមមានប្រសាសន៍ថា៖ "កិច្ចគាំពារមាតុភាពគឺជាសិទ្ធិមូលដ្ឋាន និងសិទ្ធិនៅក្នុងរដ្ឋធម្មនុញ្ញ ហើយកិច្ចគាំពារនេះ គឺជាការចាំបាច់ណាស់ ក្នុងការសម្រេចបាននូវសមភាពយេនឌ័រ សុខុមាលភាព និងសុខភាពរបស់ម្តាយ និងកូន ក៏ដូចជាក្នុងការទទួលបានឱកាសនិងភាពស្មើគ្នាក្នុងវិស័យការងាររវាងស្ត្រី និងបុរស ក៏ដូចជាពលរដ្ឋក្នុងក្រុមផ្សេងៗផងដែរ។"

# អគ្គលេខាធិការរងអង្គការសហប្រជាជាតិ និងជាប្រធាន UNESCAP បានផ្ញើលិខិតថ្លែងអំណរគុណជូនសម្តេចនាយករដ្ឋមន្ត្រីហ៊ុន សែន

*អត្ថបទ៖ អមរិន្ទ ដានុត*

លោកស្រី អាមីដា សាលស៊ីអាហ៍ អាលីសចាបាណា អគ្គលេខាធិការរងអង្គការសហប្រជាជាតិ និងជាប្រធាន UNESCAP បានផ្ញើលិខិតថ្លែងអំណរគុណជូនសម្តេចនាយករដ្ឋមន្ត្រីហ៊ុន សែន កាលពីថ្ងៃទី៣០ ខែមេសា ចំពោះការចូលរួមថ្លែងសុន្ទរកថាពិសេស ក្នុងសន្និបាតប្រចាំ ឆ្នាំលើកទី៧៧ របស់គណៈកម្មការសេដ្ឋកិច្ចនិងសង្គមកិច្ចសម្រាប់អាស៊ី និងប៉ាស៊ីហ្វិក នៃអង្គការសហប្រជាជាតិ។

លោកស្រី បានលើកឡើងតាមរយៈលិខិតនេះថា៖ «នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងកោតសរសើរប្រកបដោយការវាយតម្លៃខ្ពស់ចំពោះ សម្តេចតេជោនាយករដ្ឋមន្ត្រី ដែលបានចូលរួមថ្លែងសុន្ទរកថាពិសេស ក្នុងសន្និបាតប្រចាំឆ្នាំលើកទី៧៧ របស់គណៈកម្មការសេដ្ឋកិច្ចនិងសង្គមកិច្ចសម្រាប់អាស៊ី និងប៉ាស៊ីហ្វិក នៃអង្គការសហ ប្រជាជាតិ (UN ESCAP)»។

លោកស្រីអាមីដា សាលស៊ីអាហ៍ អាលីសចាបាណា បានបញ្ជាក់ថា សុន្ទរកថាពិសេស តាមរយៈសារជាវីដេអូរបស់ សម្តេចតេជោ នាយករដ្ឋមន្ត្រី នៅក្នុងកម្មវិធីបើកសន្និបាត ពិតជាបានកំណត់នូវត្រីវិស័យដល់ការពិភាក្សា និងចូលរួមចំណែកកិច្ចប្រជុំលើកទី៧៧ របស់ UN ESCAP ទទួលបានលទ្ធផលជោគជ័យ ។ លោកស្រីបានបន្ថែមទោះបីជាស្ថានការណ៍នៃការរីករាលដាលនៃជំងឺឆ្លងកូវីដ១៩ កាន់តែធ្ងន់ធ្ងរ ដែលតម្រូវឲ្យធ្វើការប្រជុំតាមរយៈប្រព័ន្ធវីដេអូក៏ដោយ អង្គសន្និបាតបានដំណើរការទៅយ៉ាងល្អ និងបានអនុម័តលើសេចក្តីសម្រេចមួយស្តីពី «ការស្តារឡើងវិញក្រោយវិបត្តិតាមរយៈកិច្ចសហប្រតិបត្តិការតំបន់នៅក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក» ដែលបានផ្តល់នូវមូលដ្ឋានគ្រឹះ សម្រាប់ការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងតំបន់ និងលើកកម្ពស់ភាពធន់និងរឹងមាំរបស់បណ្តាប្រទេសអាស៊ី និងប៉ាស៊ីហ្វិក ក្នុងការឆ្លើយតបទៅនឹងវិបត្តិនាពេលអនាគត។

លោកស្រីថា ការសម្រេចចិត្តរបស់អង្គសន្និបាតទាំងមូល ក៏ជាមូលដ្ឋានដ៏រឹងមាំមួយទៀត ក្នុងការឆ្ពោះទៅរក ការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ននៅក្នុងតំបន់ ។

លោកស្រីអាមីដា សាលស៊ីអាហ៍ អាលីសចាបាណា បានថ្លែងថា ៖ «នាងខ្ញុំរង់ចាំស្វាគមន៍ដោយក្តីរីករាយ ចំពោះការចូលរួមដ៏ឧត្តុងឧត្តមរបស់សម្តេចតេជោ នាយករដ្ឋមន្ត្រី នៅក្នុងសន្និបាតនាពេលអនាគត ហើយនិងបន្តធ្វើការងារយ៉ាងជិតស្និតជាមួយ សម្តេចតេជោ នាយករដ្ឋមន្ត្រី និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីពង្រឹងបន្ថែមទៀតនូវកិច្ចសហ ប្រតិបត្តិការក្នុងតំបន់សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនៅអាស៊ី និងប៉ាស៊ីហ្វិក»៕

# អាមេរិកផ្តល់១១លានដុល្លារ ដើម្បីប្រយុទ្ធប្រឆាំងនឹងកូវីដ១៩ នៅកម្ពុជា



*អត្ថបទ៖ ផល សុផានិត*

សហរដ្ឋអាមេរិក បានបញ្ជាក់ពីការផ្តល់ជំនួយ ១១លានដុល្លារ ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩ នៅកម្ពុជា។ នេះបើយោងតាមសេចក្តីប្រកាសព័ត៌មាន របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១ ។

ជំនួយខាងលើ បានបញ្ជាក់ឡើងក្នុងឱកាស ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអនុញ្ញាតឱ្យលោក Patrick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបដើម្បីពិភាក្សាការងារអំពីបញ្ហាកិច្ចសហប្រតិបត្តិការទ្វេភាគី និងបញ្ហាតំបន់ នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ ២០២១ នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

លោក Patrick Murphy បានពាំនាំនូវសមានចិត្តសាមគ្គីភាពជាមួយប្រជាជនកម្ពុជា ក្នុងគ្រាដ៏លំបាកនៃជំងឺរាតត្បាតកូវីដ-១៩ ។

«លោកឯកអគ្គរដ្ឋទូតបានបញ្ជាក់អំពីជំនួយរបស់សហរដ្ឋអាមេរិកក្នុងទឹកប្រាក់ ១១លានដុល្លារអាមេរិក សម្រាប់ការប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតកូវីដ-១៩ នៅកម្ពុជា ព្រមទាំងការប្តេជ្ញារបស់សហរដ្ឋអាមេរិកក្នុងការផ្តល់ទឹកប្រាក់បួនពាន់លានដុល្លារអាមេរិក ក្នុងក្របខណ្ឌវ៉ាក់សាំង COVAX របស់អង្គការសុខភាពពិភពលោក»។

ជាការឆ្លើយតប លោកឧបនាយករដ្ឋមន្ត្រី បានថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះជំនួយរបស់សហរដ្ឋអាមេរិកទាំងក្របខណ្ឌទ្វេភាគីចំពោះកម្ពុជា និងក្របខណ្ឌអន្តរជាតិ។

លោកឧបនាយករដ្ឋមន្ត្រី ក៏បានគូសបញ្ជាក់អំពីកិច្ចសហប្រតិបត្តិការជិតស្និទ្ធរវាងមជ្ឈមណ្ឌលប្រយុទ្ធប្រឆាំងជំងឺឆ្លងសហរដ្ឋអាមេរិក (USCDC) និងក្រសួងសុខាភិបាលកម្ពុជា នារយៈពេលកន្លងមក។

លោកឧបនាយករដ្ឋមន្ត្រី និងលោកឯកអគ្គរដ្ឋទូត បានកត់សម្គាល់រួម លើចំណុចវិជ្ជមាននៃកិច្ចសហប្រតិបត្តិការរបស់ប្រទេសទាំងពីរ ដូចជាវិស័យពាណិជ្ជកម្ម និងការវិនិយោគ ដែលនៅតែមានការកើនខ្លាំងឡើងនៅឆ្នាំ ២០២០ បើទោះបីជាមានបញ្ហាកូវីដ-១៩ យ៉ាងណាក៏ដោយ។

ក្រៅពីនេះ ទោះបីជាមានការខ្វែងគំនិតគ្នាលើបញ្ហាមួយចំនួនក្តី ភាគីទាំងពីរនៅតែបញ្ជាក់ពីការប្តេជ្ញាចិត្តខិតខំដោះស្រាយរួមគ្នា និងមិនធ្វើ ឱ្យបញ្ហាទាំងនោះក្លាយជាឧបសគ្គនៃកិច្ចសហប្រតិបត្តិការដ៏ល្អប្រសើររវាងប្រទេសទាំងពីរនោះទេ។

លោកឧបនាយករដ្ឋមន្ត្រី បានជំរាបជូនលោកឯកអគ្គរដ្ឋទូត ថានៅក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំអាស៊ាន កាលពីថ្ងៃទី២៤ មេសា ២០២១ នៅទីក្រុងហ្សាកាតា ពាក់ពន្ធ័និងបញ្ហាមីយ៉ាន់ម៉ា សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បានចែករំលែកនូវបទពិសោធន៍ជាក់លាក់ដ៏សំខាន់ក្នុងការដោះស្រាយជំលោះដោយបានសង្កត់ធ្ងន់ថា ដើម្បីរកដំណោះស្រាយបានលុះត្រាតែ៖ តម្រូវឲ្យឈប់មានការប្រើអំពើហឹង្សា, គ្រប់ភាគីត្រូវជួបពិភាក្សាគ្នាដោយមានការជួយជ្រោមជ្រែងពី អាស៊ាន ហើយនិងអនុញ្ញាត្តឲ្យការផ្តល់ជំនួយមនុស្សធម៌អាចប្រព្រឹត្តបាន។

ជារួម កម្ពុជាចង់ឃើញមីយ៉ាន់ម៉ា វិលទៅរកស្ថានភាពប្រក្រតីឡើងវិញ (normalcy)។ លោកឧបនាយករដ្ឋមន្ត្រី ក៏បានបញ្ជាក់ផងដែរថា បទពិសោធន៍របស់ សម្តេចតេជោ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុង គោលការណ៍ «ការឯកភាពគ្នាជាឯកឆន្ទប្រាំចំណុច» ដែលជាលទ្ធផលនៃកិច្ចប្រជុំរបស់មេដឹកនាំអាស៊ានកន្លងទៅ។

បន្ថែមលើនេះ លោកឧបនាយករដ្ឋមន្ត្រី បានបញ្ជាក់ពីការត្រៀមខ្លួនរបស់កម្ពុជា ជាប្រធានប្តូរវេនអាស៊ាននៅឆ្នាំ ២០២២ និងបានថ្លែងអំណរគុណសហរដ្ឋអាមេរិក ដែលបានបង្ហាញសមានចិត្តគាំទ្រជួយទ្រទ្រង់កម្ពុជា ក្នុងការបំពេញតួនាទីជាប្រធានអាស៊ានទទួល បានជោគជ័យនៅឆ្នាំក្រោយ៕

## ក្រុមការងារអន្តរក្រសួង សិក្សា រៀបចំលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការគ្រប់គ្រងឧកញ៉ា ការផ្តល់គោរមងារឧកញ៉ា និងការដកហូតគោរមងារឧកញ៉ាត្រូវបានបង្កើតឡើង



*អត្ថបទ៖ អមរិន្ទ ដានុត*

រាជរដ្ឋាភិបាល បានសម្រេចបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីសិក្សា រៀបចំលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការគ្រប់គ្រងឧកញ៉ា ការផ្តល់គោរមងារឧកញ៉ា និងការដកហូតគោរមងារឧកញ៉ា។ នេះបើយោងតាមលិខិតសម្រេចដែលចុះហត្ថលេខាដោយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែនកាលពីថ្ងៃទី០៩ ខែមេសា ដែលត្រូវបានចេញនៅល្ងាចថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១នេះ។

សេចក្តីសម្រេចនេះបានលើកឡើងថា ក្រុមការងារអន្តរក្រសួងនេះមានសមាសភាពចំនួន១២រូប មកពីក្រសួងស្ថាប័នផ្សេងៗគ្នា ដូចជា ក្រសួងមហាផ្ទៃ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងស្ថាប័នមួយចំនួនទៀត។

ក្រុមការងារអន្តរក្រសួងនេះ មានភារកិច្ចសិក្សាស្រាវជ្រាវ ផ្តួចផ្តើមក្នុងការបង្កើតលិខិតបទដ្ឋានគតិយុត្តសម្រាប់ការគ្រប់គ្រងឧកញ៉ា ការផ្តល់គោរមងារឧកញ៉ា និងការដកហូតគោរមងារឧកញ៉ា, សិក្សាស្រាវជ្រាវច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា ដើម្បីជាធាតុចូលសម្រាប់រៀបចំការគ្រប់គ្រងឧកញ៉ា ការផ្តល់គោរមងារឧកញ៉ា និងការដកហូតគោរមងារឧកញ៉ា, សិក្សាអំពីសិទ្ធិ និងកាតព្វកិច្ចរបស់ឧកញ៉ាក្នុងការចូលរួមកិច្ចការសង្គម ធ្វើការពិគ្រោះយោបល់ជាមួយបណ្តាក្រសួង ស្ថាប័ន អាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជនពាក់ព័ន្ធ ដើម្បីប្រមូលព័ត៌មានបម្រើឱ្យការរៀបចំ។

សេចក្តីសម្រេចបានបន្តទៀតថា៖ «ក្រុមការងារអន្តរក្រសួងនេះ ក៏មានភារកិច្ចក្នុងការរៀបចំបែបបទ និងនីតិវិធីនៃការគ្រប់គ្រងឧកញ៉ា ការស្នើសុំផ្តល់គោរមងារឧកញ៉ា អ្នកឧកញ៉ា និងការដកហូតគោរមងារឧកញ៉ា, ធ្វើរបាយការណ៍អំពីវឌ្ឍនភាពនៃការងារជូន សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ សម្រេច និងផ្តល់យោបល់ដឹកនាំ, រៀបចំឯកសារពាក់ព័ន្ធជូនរាជរដ្ឋាភិបាលដើម្បីពិនិត្យ សម្រេច និងបំពេញភារកិច្ចផ្សេងៗទៀតតាមការចាំបាច់»។

សម្តេចនាយករដ្ឋមន្ត្រីហ៊ុន សែន បានលើកឡើងក្នុងសេចក្តីសម្រេចនេះថា អនុប្រធាន និងសមាជិកក្រុមការងារអន្តរក្រសួងនេះ ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញ និងទទួលភារកិច្ចតាមការចាត់ចែង របស់ប្រធានក្រុមការងារ។

សម្តេចបានបន្តថា ៖ «ក្រុមការងារនេះមានសិទ្ធិ ប្រើប្រាស់មន្ត្រីក្រោមឱវាទរបស់ខ្លួនដើម្បីជួយការងារតាមតម្រូវការចាំបាច់ និងប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃដើម្បីចាត់ចែងការងាររបស់ខ្លួនផងដែរ»៕

# អាល្លឺម៉ង់បន្តផ្ដល់ជំនួយដល់កម្ពុជា ដើម្បីកាត់បន្ថយភាពក្រីក្រ



*អត្ថបទ៖ ផល សុផានិត*

កិច្ចចរចាស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍឆ្នាំ២០២១ រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ត្រូវបានរៀបចំឡើងជាផ្លូវការរយៈពេល២ថ្ងៃ ចាប់ពីថ្ងៃទី៥-៦ ខែឧសភា ឆ្នាំ២០២។ក្នុងកិច្ចចរចាឆ្នាំនេះ ភាគីអាល្លឺម៉ង់ បានសន្យាផ្ដល់ហិរញ្ញប្បទានឥតសំណងប្រមាណ ៥៣ លានអឺរ៉ូ សមមូលនឹង ៦៣ លានដុល្លារអាមេរិក ដើម្បីរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា សម្រាប់ឆ្នាំ២០២១- ២០២២ ។

យោងតាមសេចក្ដីប្រកាសព័ត៌មានរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានគូសបញ្ជាក់ថា កិច្ចចរចារយៈពេល២ថ្ងៃនៅឆ្នាំនេះ បានប្រព្រឹត្តទៅប្រកបដោយជោគជ័យក្នុងស្មារតីស្ថាបនា និងភាពជាដៃគូស្មើភាពគ្នា ក្នុងកិច្ច សហប្រតិបត្តិការ ។ ជាលទ្ធផល ភាគីទាំងពីរ បានឯកភាពក្នុងការបន្តកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍លើអាទិភាពចំនួន ៣ គឺ ១) សន្តិភាព និងសង្គមប្រកបដោយបរិយាប័ន្ន, ២) ការបណ្ដុះបណ្ដាលជំនាញ និងការអភិវឌ្ឍ ប្រកបដោយចីរភាព សម្រាប់ការងារសមរម្យ និង ៣) ទំនួលខុសត្រូវចំពោះភពផែនដី(វិស័យថាមពល និង អាកាសធាតុ) ដែលមានសង្គតិភាពយ៉ាងល្អប្រសើរទៅនឹងអាទិភាពជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា និងរបៀបវារៈ ឆ្នាំ២០៣០ របស់អាល្លឺម៉ង់ ។



បើតាមសេចក្ដីប្រកាសដដែល ក្នុងកិច្ចចរចាឆ្នាំនេះ ភាគីអាល្លឺម៉ង់បានសន្យាផ្ដល់ហិរញ្ញប្បទានឥតសំណងប្រមាណ ៥៣ លានអឺរ៉ូ សមមូលនឹង ៦៣ លានដុល្លារអាមេរិក ដើម្បីរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា សម្រាប់ឆ្នាំ២០២១-២០២២ ។ ទំហំហិរញ្ញប្បទានឥតសំណងនេះរួមមាន ២៦ លានអឺរ៉ូ សម្រាប់កិច្ចសហប្រតិបត្តិការផ្នែកហិរញ្ញវត្ថុ និង ២៧ លានអឺរ៉ូ សម្រាប់កិច្ចសហប្រតិបត្តិការផ្នែកបច្ចេកទេស ។

បន្ថែមលើនេះ នាខែមីនា ឆ្នាំ២០២១ ភាគីអាល្លឺម៉ង់ បានផ្ដល់ហិរប្បទានឥត សំណង ចំនួន ៤,៨ លានអឺរ៉ូ សម្រាប់កិច្ចសហប្រតិបត្តិការផ្នែកបច្ចេកទេស ។ បើបូកបញ្ចូលទាំងហិរញ្ញប្បទាន ដែលបានសន្យាផ្ដល់ក្នុងកិច្ចចរចានេះ ទំហំហិរញ្ញប្បទានសរុបបានកើនដល់ ៥៧,៨ លានអឺរ៉ូ សមមូលនឹង ៦៩ លានដុល្លារអាមេរិក ។

ដើម្បីឆ្លើយតបទៅនឹងវិបត្តិសុខភាពសកល, គិតត្រឹមខែមីនា ឆ្នាំ២០២១ ភាគីអាល្លឺម៉ង់ បានផ្ដល់ហិរញ្ញប្បទានឥតសំណងប្រមាណ ១៣,៨ លានអឺរ៉ូ សមមូលនឹង ១៧ លានដុល្លារអាមេរិក ដើម្បីគាំទ្រ ដល់វិធានការឆ្លើយតបបន្ទាន់ទៅនឹងការឆ្លងរាលដាលនៃជំងឺកូវី-១៩ នៅកម្ពុជា ។ ហិរញ្ញប្បទាននេះ ត្រូវបានប្រើប្រាស់ដើម្បីរួមចំណែកគាំទ្រដល់វិធានការឆ្លើយតបបន្ទាន់ទៅនឹងផលប៉ះពាល់នៃជំងឺកូវី៥-១៩ និងវិធានការស្ដារសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា ។ ក្រៅពីកិច្ចសហប្រតិបត្តិការទ្វេភាគី ភាគីអាល្លឺម៉ង់ក៏បានផ្ដល់ហិរញ្ញប្បទានសហប្រតិបត្តិការដល់កម្ពុជា តាមរយៈគម្រោងថ្នាក់តំបន់ និងសាកលព្រមទាំងតាមរយៈស្ថាប័នហិរញ្ញវត្ថុ អន្តរជាតិ អង្គការសហប្រជាជាតិ និងសហភាពអឺរ៉ុប៕

# ក្រសួងប្រៃសណីយ៍ផ្សព្វផ្សាយលេខទូរស័ព្ទដើម្បីជួយកុមារពីការរំលោភបំពាន

*អត្ថបទ៖ អរិយបុត្រ*

ដើម្បីជួយការពារកុមារពីការប្រើអំពើហិង្សា និងការរំលោភបំពានគ្រប់ប្រភេទតាមប្រព័ន្ធអនឡាញចំពេលនៃការរីករាលដាលនៃមេរោគកូវីដ-១៩ នៅក្នុងសហគមន៍ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍កាលពីពេលថ្មីៗកន្លងទៅនេះ បានផ្សព្វផ្សាយបណ្ដាញទូរស័ព្ទជំនួយកុមារមួយខ្សែរដែលកុមារ និងអាណាព្យា បាលព្រមទាំងអ្នកដែលពាក់ព័ន្ធអាចទំនាក់ទំនងបានតាមលេខ ១២៨០ ។

យោងតាមសេចក្ដីជូនដំណឹងរបស់ក្រសួងបានឲ្យដឹងថា ឪពុកម្ដាយ អាណាព្យាបាល ឬកុមារអាចទូរស័ព្ទទៅលេខ ១២៨០ ដើម្បីពិភាក្សានិងពិគ្រោះបញ្ហាផ្សេងៗទាក់ទងនឹងកុមារដោយមិនគិតថ្លៃ និងសម្ងាត់។

បណ្ដាញទូរស័ព្ទជំនួយកុមារកម្ពុជាលេខ ១២៨០ អាចជាលេខទូរស័ព្ទដែលអាចទទួលការហៅចូលបានគ្រប់ប្រព័ន្ធ ដោយ ឥតគិតថ្លៃពីបណ្ដាញទូរស័ព្ទទាំងអស់ដើម្បីទទួលបានព័ត៌មាន ការអប់រំ ពិគ្រោះយោ បល់ សេវាបញ្ជូនបន្តដោយសម្ងាត់ ។

ប្រភពដដែលបានបញ្ជាក់ថា ៖ «ឪពុកម្ដាយ អាណាព្យាបាល ឬកុមារ អាចទូរសព្ទទៅកាន់លេខ ១២៨០ ដើម្បីពិភាក្សាអំពីបញ្ហាផ្សេងៗទាក់ទងនឹងកុមារ ពិគ្រោះយោបល់ ទទួលព័ត៌មានអប់រំ និងស្វែងរកសេវាបញ្ជូនបន្ត។ ការប្រើប្រាស់សេវានេះ គឺសម្ងាត់ និងឥតគិតថ្លៃ»។

ពាក់ព័ន្ធនឹងបណ្ដាញទូរស័ព្ទនេះ លោក ស៊ាន សុខផៃ នាយកប្រតិបត្តិនៃបណ្ដាញទូរស័ព្ទជំនួយកុមារកម្ពុជាមានប្រសាសន៍ថានេះមិនមែនជាសេវាកម្មថ្មីទេ។

លោកបានថ្លែងប្រាប់អ្នកសារព័ត៌មានកាលពីពេលថ្មីៗកន្លងទៅនេះថា យើងបានសហការជាមួយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ចាប់តាំងពីខែសីហាឆ្នាំ ២០១០ ហើយនៅក្នុងរយៈពេលមួយឆ្នាំៗ មានការហៅទូរស័ព្ទប្រមាណជា ពី៤០.០០០ ទៅ ៥០០០០ តាមលេខ ១២៨០ នេះ ។

លោកបានបន្តថា ការហៅភាគច្រើនផ្ដោតសំខាន់ទៅលើវិបត្តិផ្លូវចិត្ត ទំនាក់ទំនងកុមារ និងសេវាកម្ម ពាក់ព័ន្ធផ្សេងៗ ។

លោកបន្ថែមថា ១២៨០ ជាបណ្ដាញទូរស័ព្ទជំនួយកុមារមានសេវាកម្មផ្ដល់ប្រឹក្សាដើម្បីនិយាយអំពីកុមារគ្រប់ពេលដោយឥតគិតថ្លៃពីគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា។

ធន ស្រីពៅ ប្រធានផ្នែកប្រឹក្សាយោបល់នៃបណ្ដាញទូរស័ព្ទជំនួយកុមារកម្ពុជាបានសម្ដែងនូវការស្វាគមន៍ចំពោះក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ដែលផ្សព្វផ្សាយ ១២៨០ សម្រាប់យុទ្ធនាការការពារកុមារតាមអិនធឺណែតរបស់ខ្លួនចំពេលដែលមានការរីករាលដាលនៃជំងឺកូវីដ ១៩ នៅក្នុងប្រទេស ។

ស្រីពៅ បានបន្ថែមថា រាល់ការទំនាក់ទំនងមកលេខ១២៨០ គឺមានសារៈសំខាន់ដូច្នេះកុមារឪពុកម្ដាយនិងក្រុមគោលដៅរបស់យើងមានឱកាសទទួលការប្រឹក្សាលើបញ្ហាដែលពួកគេបានជួបព័ត៌មាន ឬសេវាកម្មណាមួយដែលពួកគេត្រូវការ។

ស្រីពៅបានគូសបញ្ជាក់ថា ៖ «វាគឺជាការឆ្លុះបញ្ចាំងពីការយកចិត្តទុកដាក់លើកុមារ និងកិច្ចខិតខំប្រឹងប្រែងការពារកុមារក្នុងពេលមានការរីករាលដាលនៃជំងឺកូវីដ-១៩»។

ក្នុងអំឡុងពេលនៃការបិទខ្ទប់រាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្ដាលក្នុងខែមេសាមានការទំនាក់ទំនងទូរស័ព្ទច្រើនជាង ២០០០ដង ទៅលេខ ១២៨០ ខណៈដែលអ្នកទូរស័ព្ទចូលភាគច្រើន គឺ អាណាព្យាបាលនិងឪពុកម្ដាយកុមារ ក្មេងជំទង់ ដើម្បីពិភាក្សាអំពីបញ្ហានៃការព្រួយបារម្ភក្នុងកំឡុងពេលផ្ទុះនៃការរីករាលដាលមេរោគកូវីដ-១៩ ការភ័យខ្លាចនៃការឆ្លងមេរោគ៕



*រូបភាព៖ UNICEF Cambodia/Todd Brown*

# កម្ពុជាទទួលចំណូលជាង ១៦១ លានដុល្លារពីការនាំអង្ករចេញក្នុងរយៈពេល៤ខែដំបូងដើមឆ្នាំ២០២១នេះ

*អត្ថបទ៖ ផល សុផានិត*

រយៈពេល៤ខែដំបូងឆ្នាំ២០២១ នេះ កម្ពុជាបាននាំចេញអង្ករក្នុងបរិមាណ ១៩២ ៤៩៥តោន មានការថយចុះចំនួន១០៧ ៧៥៧តោន ស្មើនឹង ៣៥.៨៩% បើធៀបនឹងបរិមាណនាំចេញក្នុងរយៈពេល៤ខែ ឆ្នាំ២០២០ ដែលមានចំនួន ៣០០ ២៥២តោន។ នេះបើតាមរបាយការណ៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចេញផ្សាយនៅល្ងាចថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០២១ ។




របាយការណ៍បានបញ្ជាក់ឲ្យដឹងទៀតថា ការនាំចេញអង្ករ ក្នុងខែមេសា ឆ្នាំ២០២១ មានចំនួន ៣៨ ៨០៧តោន ថយចុះចំនួន ៣០ ៤៩៧តោន (៤៤%) បើធៀបនឹងខែមេសា ឆ្នាំ២០២០ ដែលមានចំនួន ៦៩ ៣០៤តោន។

ក្នុងនោះ អង្ករក្រអូបគ្រប់ប្រភេទ មានចំនួន ១៣០ ១២០តោន ស្មើនឹង ៦៧.៦% អង្ករសគ្រប់ប្រភេទមានចំនួន ៥៩ ០២៦តោន ស្មើនឹង ៣០.៦៦% និងអង្ករចំហុយ មានចំនួន ៣ ៣៤៩តោន ស្មើនឹង១.៧៤% ។

អង្ករបាននាំចេញទៅកាន់ទិសដៅ សហភាពអឺរ៉ុបចំនួន២០ប្រទេស មានបរិមាណសរុបចំនួន៤២ ៨៥០តោន (២២.២៦%) ទិសដៅប្រទេសចិន មានបរិមាណសរុប ចំនួន ១០៤ ៧៥៦តោន (៥៤.៤២%) ទិសដៅអាស៊ានចំនួន៤ប្រទេស មានបរិមាណសរុបចំនួន ១៧ ៤៨៣តោន (៩.០៨%) និងទិសដៅដទៃទៀតចំនួន១៨ប្រទេស មានបរិមាណសរុប ២៧ ៤០៦តោន (១៤.២៤%) ។

ក្រុមហ៊ុនដែលបាននាំចេញអង្ករ មានចំនួន ៥១ ហើយបរិមាណអង្ករ ដែលបាននាំចេញដោយក្រុមហ៊ុនធំៗ ចំនួន១០ មានរហូតដល់១៣៥ ៩៨០តោន (៧០.៦៤%) និងក្រុមហ៊ុន៤១ដទៃទៀត បាននាំចេញត្រឹមតែ ៥៦ ៥១៥តោន (២៩.៣៦%) ។

ដោយឡែកការនាំចេញស្រូវមានចំនួន ១ ៥២៩ ២៨០តោន ទៅកាន់ប្រទេសវៀតណាមក្នុងរយៈពេល៤ខែ ដើមឆ្នាំ២០២១ មានការកើនឡើងចំនួន ៦៤៦ ០៤៨តោន (៧៣.១៥%) បើធៀបនឹងរយៈដូចគ្នា ក្នុងឆ្នាំ២០២០ ដែលមានចំនួនតែ ៨៨៣ ២៣២តោន តែប៉ុណ្ណោះ។

បើតាមរបាយការណ៍រយៈពេល៤ខែ ឆ្នាំ២០២១នេះ ការនាំចេញអង្ករ រកចំណូលបានជាង១៦១លានដុល្លារ ដុល្លារអាមេរិក និងការនាំចេញស្រូវ រកចំណូលបានចំនួនជាង ២២១ដុល្លារអាមេរិក៕

# ផលិតផលកសិកម្មជាង ២លានតោន បាននាំចេញទៅកាន់ទីផ្សារអន្តរជាតិ ក្នុងរយៈពេល៤ខែដំបូង



*អត្ថបទ ៖ ផល សុផានិត*

ប្រទេសកម្ពុជាបាននាំចេញ ផលិតផលកសិកម្មចំនួន ២ ៨១៧ ៤៨៥,៣៥ តោន កើនឡើង ៦៤,៤៥ ភាគរយ ប្រសិនបើប្រៀបធៀបនឹងរយៈពេល៤ខែដំបូង ឆ្នាំ២០២០ បើទោះបីជាប្រទេសកម្ពុជាកំពុងស្ថិតនៅក្នុងការរាតត្បាតនៃមេរោគកូវីដ-១៩យ៉ាងណាក្តី។ នេះបើតាមរយបាយការណ៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចេញផ្សាយនៅល្ងាចថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០២១ ។

របាយការណ៍ដដែលបន្តថា ផលិតផលកសិកម្មសំខាន់ៗដែលនាំចេញរួមមាន ដំឡូងមី គ្រាប់ស្វាយចន្ទី ពោត ផ្លែចេកស្រស់ ក្រូចថ្លុង ផ្លែស្វាយស្រស់ ម្ទេស និងម្រេច។

របាយការណ៍បន្ថែមថា ផលិតផលកសិកម្មដែលនាំចេញរួមមាន ដំឡូងមីជា ១,១លានតោន កើនឡើង២៥,៦៤ ភាគរយ។ ផ្លែចេកស្រស់បានចំនួន ១៦៦ ២៩៩ តោន កើនឡើង ៦៨,០៣ ភាគរយ។ គ្រាប់ស្វាយចន្ទីចំនួន ៦៩៦ ៣៥៨ តោន កើនឡើង ២៧៣,៩៧ ភាគរយ។ ពោតចំនួន ១៣២ ៤៧៩ តោន កើនឡើង ២៩៧,៨៦ ភាគរយ។ ផ្លែស្វាយស្រស់បានចំនួន ១៤២ ៥៥៦ តោន កើនឡើង ២៣៩,១៣ ភាគរយ។

ក្នុងរយៈពេល ៤ខែដំបូងនេះ កម្ពុជានាំចេញសរុបផលិតផលកសិកម្ម ជាង២០មុខ និងទៅកាន់ទីផ្សារអន្តរជាតិចំនួន ២៦ប្រទេសនៅជុំវិញពិភពលោក។

ទីផ្សារអន្តរជាតិសំខាន់របស់កម្ពុជា រួមមាន ប្រទេសចិន សហភាពអឺរ៉ុប ប្រទេសក្នុងតំបន់អាស៊ាន ប្រទេសឥណ្ឌា ជប៉ុន កូរ៉េខាងត្បូង ប្រទេសរ៉ុស៊ី អូស្ត្រាលី និងប្រទេសជាច្រើនផ្សេងទៀត៕

## រមណីដ្ឋានអង្គរទទួលស្វាគមន៍ ភ្ញៀវទេសចរបរទេសចំនួន ជាង ៤៥០០នាក់ ក្នុងរយៈពេល៤ខែដំបូង

*អត្ថបទ ៖ ផល សុផានិត*

រមណីដ្ឋានអង្គរ ស្ថិតក្នុងខេត្តសៀមរាប បានទទួលស្វាគមន៍ភ្ញៀវទេសចរណ៍អន្តរជាតិ ចំនួន ៤ ៥២៨នាក់ និងទទួលបានចំនូល ១៨៧ ២១៦ ដុល្លាអាមេរិក ក្នុងរយៈពេល៤ខែដំបូងឆ្នាំនេះ។ នេះបើតាមរបាយការណ៍ចេញផ្សាយដោយគ្រឹះស្ថានអង្គរ កាលពីម្សិលមិញ។

របាយការណ៍បញ្ជាក់ថា ចំនួនភ្ញៀវទេសចរណ៍បរទេសបានធ្លាក់ចុះចុះនួន ៩៨,៨២ ភាគរយ ប្រសិនបើប្រៀបធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

ជាមួយនឹងចំនូលខាងលើពីការលក់សំបុត្រ បានធ្វើការបរិច្ចាគជូនមន្ទីរពេទ្យគន្ធបុប្ផាចំនួន ៩ ០៥៦ ដុល្លាអាមេរិក ក្នុងន័យចូលរួមសកម្មភាពមនុស្សធម៌។

កាលពីខែមេសាកន្លងទៅ រមណីដ្ឋានអង្គរបានលក់សំបុត្រជូនភ្ញៀវទេសចរណ៍បរទេសចំនួន ៤៦នាក់ និងទទួលបានចំនូល ២ ១៣៧ដុល្លាអាមេរិក ធ្លាក់ចុះ ៩២,៧២ភាគរយ។

រយៈពេល៤ខែដំបូងនេះ ភ្ញៀវទេសចរណ៍បរទេសបានទិញសំបុត្រចូលទស្សនាប្រាសាទកោះកេរ្តិ៍ចំនួន ១៥៦នាក់ និងទទួលបានចំណូល ២ ៣៨៥ដុល្លាអាមេរិក។

កាលពីពេលថ្មីៗនេះ គ្រឹះស្ថានអង្គរបានប្រកាសពីការកែប្រែគោលការណ៍ នៃការចូលទស្សនារមណីដ្ឋានអង្គរដើម្បីទាក់ទាញ ភ្ញៀវទេសចរណ៍អន្តរជាតិ ក្នុងពេលវិបិត្តកូវីដ១៩នេះ។

យោងតាមការកែប្រគោលការណ៍នេះ ភ្ញៀវទេសចរណ៍ដែលបានទិញប័ណ្ណចូលទស្សនាអង្គរចំនួន១ថ្ងៃ អាចចូលទស្សនាបានចំនួន ២ថ្ងៃ។ ការទិញប័ណ្ណចំនួន៣ថ្ងៃ ភ្ញៀវទេសរណ៍អាចទស្សនា បានចំនួន៥ថ្ងៃ និងទិញប័ណ្ណចូលទស្សនា៧ថ្ងៃ អាចចូលទស្សនាបានចំនួន ១០ថ្ងៃ។

បន្ថែមពីលើនេះ ការទិញប័ណ្ណទស្សនារមណីដ្ឋានអង្គរចំនួន ១ខែ ភ្ញៀវទេសចរណ៍អាចចូលទស្សនាបានចំនួន ២ខែ។ ការទិញប័ណ្ណទស្សនា៣ខែ ភ្ញៀវទេសចរណ៍អាចទស្សនាបាន ៦ខែ ខណៈពេលទិញចំនួន៦ខែ ភ្ញៀវទេសចរណ៍អាចចូលទស្សនាបានចំនួន ពេញមួយឆ្នាំ។

គោលការណ៍ថ្មីនេះចាប់ផ្តើមអនុវត្តពីថ្ងៃទី ១១ ខែមីនា រហូតដល់ដំណាច់ឆ្នាំ២០២១នេះ៕

# ទស្សនៈយុវវ័យចំពោះទស្សនវិស័យសកល គឺមានសារៈសំខាន់នាយុគសម័យកូវីដ-១៩

*អត្ថបទ៖ អរិយបុត្រ*

លោក អាលវិន តាន (Alvin Tan) រដ្ឋមន្ត្រីទទួលបន្ទុក វប្បធម៌ សហគមន៍ និងយុវជនសិង្ហបុរី បានថ្លែងកត់សំគាល់ជាពិសេសអំពីទស្សនៈរបស់យុវវ័យនាយុគសម័យនៃការរីករាលដាល នៃមេរោគកូវីដ-១៩ នាពេលបច្ចុប្បន្ននេះ ។



តាមទស្សនៈដែលលោក រដ្ឋមន្ត្រី វ័យក្មេងនេះបានចែករំលែក វាជាបទពិសោធន៍មួយ នៃការឲ្យតម្លៃទៅលើតួនាទីយុវវ័យនៅសិង្ហបុរី ប៉ុន្តែវាក៏ជាបទពិសោធន៍មួយសម្រាប់បណ្តាប្រទេសនានា នៅក្នុងការលើកកំពស់និងជំរុញតួនាទីយុវវ័យ។

លោក អាលវិន តាន បាននិយាយថា មេរោគកូវីដ-១៩ ប្រហែលជាបាននាំឲ្យការធ្វើដំណើរទៅក្រៅប្រទេសត្រូវកាត់បន្ថយ ប៉ុន្តែវានៅតែមានសារៈសំខាន់សម្រាប់យុវជននិងយុវនារីសិង្ហបុរី នៅក្នុងការបន្តការធ្វើដំណើរដើម្បីឱ្យពួកគេយល់ពីតំបន់របស់ពួកគេឱ្យកាន់តែប្រសើរនិងទទួលបាននូវទស្សនវិស័យសកលលើបញ្ហានានាមិនថាជាបញ្ហាពាក់ព័ន្ធនឹងអ្វីនោះទេ រួមទាំង ពាណិជ្ជកម្ម និងឧស្សាហកម្ម។

លោកបានអះអាងថា អាស៊ានគឺជាតំបន់ដែលមានភាពរស់រវើក។ នៅពេលដែលការធ្វើដំណើរបើកចំហម្តងទៀតខ្ញុំលើកទឹកចិត្តឱ្យយុវជនធ្វើដំណើរទៅអាស៊ាន ឲ្យពួកគេឆ្លងកាត់ព្រលានយន្តហោះ ធ្វើដំណើរនៅលើផ្លូវថ្នល់នានានៅគ្រប់តំបន់ ដើម្បីឲ្យពួកគេបានមើលឃើញនូវភាពរស់រវើក នៃទីផ្សារទាំងនេះ ហើយក៏ដើម្បីឲ្យពួកគេស្វែងយល់ពីបរិបទវប្បធម៌និងបង្កើតភាពជាដៃគូជាមួយសហគ្រិនវ័យក្មេងៗ ដែលកំពុងតែព្យាយាមបង្កើតផលិតផលគួរឱ្យចាប់អារម្មណ៍នានារួចហើយ។

> ... វានៅតែមានសារៈសំខាន់សម្រាប់យុវជននិងយុវនារីសិង្ហបុរីនៅក្នុងការបន្តការធ្វើដំណើរដើម្បីឱ្យពួកគេយល់ពីតំបន់របស់ពួកគេឱ្យកាន់តែប្រសើរ និងទទួលបាននូវទស្សនវិស័យសកលលើបញ្ហានានាមិនថាជាបញ្ហាពាក់ព័ន្ធនឹងអ្វីនោះទេ រួមទាំង ពាណិជ្ជកម្មនិងឧស្សាហកម្ម

លោកអាលវិន តាន បាននិយាយថា ទោះបីជាមានការរឹតត្បិតនៅក្នុងការធ្វើដំណើរដោយសារតែការរីករាលដាលនៃមេរោគកូវីដ-១៩ ក៏ដោយក៏មានឱកាសសម្រាប់យុវវ័យសិង្ហបុរីដើម្បីទទួលបានការផ្សព្វផ្សាយជាសកលនៅតាមផ្ទះពីកម្មវិធីដំណើរចរនៅប្រទេសនានា ដូចជាតាមរយៈកម្មវិធីផ្សព្វផ្សាយនានា។

លោកបន្ថែមថា ក្រៅពីកម្មវិធីដែលពួកគេអាចទទួលព័ត៌មាននៅតាមផ្ទះហើយនោះ យុវវ័យក៏អាចទាញយកកម្មវិធីផ្សព្វផ្សាយក្រៅប្រទេសជាច្រើនទៀត។ កម្មវិធីទាំងនេះរួមមានគម្រោងជម្រុញយុវជនទៅតាមអ៊ិនធឺណិត ដែលយុវវ័យអាចស្ម័គ្រចិត្តជាមួយសហគមន៍ក្រៅប្រទេសដោយមិនចាំបាច់ធ្វើដំណើរ។

លោក អាលវិន តាន បាននិយាយនៅក្នុងសិក្ខាសាលាមួយសម្រាប់អ្នកចូលរួមជាយុវជននិងយុវនារីប្រហែល ១២០០ នាក់ កាលពីពេលថ្មីៗកន្លងទៅនេះថា បទពិសោធន៍និងចំណេះដឹង ទាំងនេះ គឺពិតជាមានសារៈសំខាន់ និងជាកម្លាំងបណ្តាលចិត្តដ៏រឹងមាំសម្រាប់យុវជននិងយុវនារី នានា ។

គួររំលឹកថា សិក្ខាសាលានេះគឺសហការរៀបចំឡើងរវាង ក្រុមប្រឹក្សាយុវជនជាតិសិង្ហបុរី និងវិទ្យាស្ថានកិច្ចការអន្តរជាតិសាំងហ្គាពួរតាមប្រព័ន្ធអនឡាញ។ សិក្ខាសាលានេះ គឺជាផ្នែកមួយនៃកម្មវិធីដែលបានចាប់ផ្តើមតាំងពីខែតុលា ឆ្នាំ២០២០ ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីលើកទឹកចិត្តយុវជនឱ្យយល់កាន់តែច្បាស់អំពីបញ្ហា និងការអភិវឌ្ឍន៍ក្នុងតំបន់។

នៅក្នុងកម្មវិធីនោះ ដែរ លោក រ៉េម៉ន យី (Raymond Yee) អនុប្រធានរបស់ក្រុមហ៊ុនឌីហេចអែល (DHL) អ៊ិចប្រេស ក៏បានណែនាំដល់ប្រជាជនវ័យក្មេងសិង្ហបុរីឱ្យគិតពីយុទ្ធសាស្ត្រអាជីវកម្មប្រកបដោយភាពច្នៃប្រឌិតនៅក្នុងទីផ្សារផ្លាស់ប្តូរមួយ។

លោកបានអះអាងថា យុវជនអាចស្វែងរកទីផ្សារពិសេសរបស់ពួកគេយ៉ាងឆាប់រហ័ស។ វាមានសារៈសំខាន់ណាស់ក្នុងការស្វែងរកភាពរឹងមាំពិសេសរបស់អ្នកនិងស្រេកឃ្លានឱកាសនៅក្នុងតំបន់។

លោកបានជំរុញឲ្យយុវវ័យសិង្ហាបុរីរិះគិតអំពីយុទ្ធសាស្ត្រអាជីវកម្មប្រកបដោយភាពច្នៃប្រឌិតនៅក្នុងទីផ្សារដែលមានការផ្លាស់ប្តូរ និងស្ថិតនៅក្នុងបរិបទថ្មី ។

លោកបានបន្តថា សារៈសំខាន់នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTA) ចំពោះប្រទេសសិង្ហបូរី និងធុរកិច្ចក៏ផ្តោតសំខាន់លើគំនិតរបស់អ្នកធ្វើអាជីវកម្មផ្ទៃក្នុងទាំងពីរផងដែរ។

លោកបានអះអាងថា នៅពេលត្រូវបានគេស្នើសុំឱ្យប្រមើលមើលពិភពលោកដោយគ្មានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTA) លោក អាលវិន តាន បាននិយាយថា ប្រទេសសិង្ហបូរីនឹងក្លាយជាដែនដីដែលគេមិនអាចទទួលយកបានទេ។

លោកបានបន្តថា ប្រសិនបើប្រទេសសិង្ហបូរីគ្មានពាណិជ្ជកម្ម គ្មានកិច្ចព្រមព្រៀងដែលពាក់ព័ន្ធនឹងពាណិជ្ជកម្ម នោះគឺជាស្ថានការណ៍មួយដ៏អាក្រក់សម្រាប់សិង្ហបុរី។ លោកបានបន្តថា ប្រសិនបើសិង្ហបុរីមិនបើកចំហរពាណិជ្ជកម្ម ការបណ្តាក់ទុននឹងទទួលស្គាល់ការអភិវឌ្ឍន៍ជំនាញនានាទេនោះ ប្រហែលជា ប្រជាពលរដ្ឋ ការងារ និង អ្នកដែលមានទេពកោសល្យនានា នឹងចាកចេញពីសិង្ហបុរី។

លោកបានសង្កត់ធ្ងន់លើភាពចាំបាច់សម្រាប់យុវជនសិង្ហបុរីនៅក្នុងការសម្លឹងទៅមើលអ្នកដទៃនៅខាងក្រៅ ដើម្បីប្រយុទ្ធប្រឆាំងនឹងសភាវគតិដែលមើលទៅខាងក្នុង ដើម្បីជាការទទួលយក «អ្នកដទៃនិងបើកចិត្តគំនិតខ្លួនឯង»។

ស្រដៀងគ្នានេះដែរលោក យី ក៏បាន កត់សម្គាល់ថាកំណើនសេដ្ឋកិច្ចរបស់ប្រទេសសិង្ហបូរីនឹងត្រូវកាត់បន្ថយដោយសារតែសិង្ហបុរីជាដែនដីដែលមានធនធានធម្មជាតិតិចតួចតែសិង្ហបុរីបានបង្ហាញពី តម្រូវការ សម្រាប់កិច្ចសហប្រតិបត្តិការពិភពលោកក្រោមប្រព័ន្ធពាណិជ្ជកម្មពហុភាគី។

លោកបានបន្តថា វាជាការគួរឱ្យស្តាយក្នុងការគិតថាប្រទេសមួយនឹងកាន់តែប្រសើរប្រសិនបើពួកគេត្រូវបិទព្រំដែនរបស់ពួកគេ ហើយសម្លឹងមើលតែផ្នែកខាងក្នុងខ្លួនឯងនោះ ។




ទាំងនេះគឺជាទស្សនៈវិស័យមួយរបស់អ្នកជំនាញការទាំងពីរ ទាក់ទងនឹងបរិបទសម្រាប់ទ្រទ្រង់ភាពរីកចម្រើនរបស់សង្គមសិង្ហបុរី ប៉ុន្តែទស្សនៈទាំងនេះ ក៏វាមានប្រយោជន៍សម្រាប់តំបន់ និងពិភពលោកផងដែរ សម្រាប់យកមករិះគិត និងអភិវឌ្ឍគំនិតសម្រាប់យើងទាំងអស់គ្នា៕

# ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបំភ្លឺរឿងគយហុងកុងរឹបអូសឈើប្រភេទរងការគំរាមកំហែងពីកម្ពុជា




*អត្ថបទ៖ ស្រី និច*

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានចេញសេចក្តីប្រកាសព័ត៌មានមួយបំភ្លឺ អំពីការចុះផ្សាយព័ត៌មាននៅលើសារព័ត៌មាននៅក្នុងស្រុកមួយចំនួនថា គយហុងកុង បានរឹបអូសប្រភេទឈើរងការគំរាមកំហែង ដែលមានប្រភពពីកម្ពុជា។

ប្រភពដដែលបានបន្តថា គយហុងកុង បានរឹបអូសឈើដែលគេសង្ស័យមានចំនួន ៧កុងតឺន័រ មានទម្ងន់សរុបប្រមាណ ២១១តោន ដែលមានតម្លៃទីផ្សារប្រមាណ ១,១លានដុល្លាហុងកុង ឬប្រហាក់ប្រហែលនឹង១៤០.០០០ដុល្លារសហរដ្ឋអាមេរិក។

ប្រភពដដែលបានបន្តថា ការរឹបអូសនេះបានធ្វើឡើងនៅកន្លែងត្រួតពិនិត្យទំនិញគយក្នុងកំពង់ផែខ្វៃជុង (Kwai Chung) និង កំពង់ផែ ស៊ីងយី (Tsing Yi )នៅចន្លោះថ្ងៃទី ២៩ ខែមេសា ដល់ថ្ងៃទី ០៥ ឧសភា ឆ្នាំ២០២១ ។

ឆ្លើយតបនឹងព័ត៌មាននេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបំភ្លឺថា ឈើទាំងនេះជាប្រភេទឈើគ្មានការអនុញ្ញាតឱ្យធ្វើការនាំចេញពីកម្ពុជាឡើយ ហើយវត្តមានឈើទាំងនេះ អាចជាឈើរត់ពន្ធខុសច្បាប់។

ប្រភពដដែលបានបញ្ជាក់ឱ្យដឹងផងដែរថា ពាក់ព័ន្ធនិងការចុះផ្សាយព័ត៌មាននេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពុំដែលបានរៀបចំបំពេញបែបបទនាំចេញប្រភេទឈើរងការគំរាមកំហែងជូនដល់ បណ្តាក្រុមហ៊ុនណាមួយឡើយ សម្រាប់ធ្វើការនាំចេញទៅក្រៅប្រទេស ឬហុងកុងនោះទេ ក្នុងរយៈពេល ប្រមាណជា៥ឆ្នាំមកហើយ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានប្រកាសថា ជុំវិញព័ត៌មាននេះ ក្រសួងកំពុងយកចិត្តទុកដាក់ ធ្វើការអង្កេតស្រាវជ្រាវលើករណីនេះ ដោយមានការសហការជាមួយក្រសួងនិងស្ថាប័នពាក់ព័ន្ធ ដើម្បីស្វែងរកការពិតព្រមទាំងវែកមុខអ្នកប្រព្រឹត្ត និងអ្នកពាក់ព័ន្ធមកទទួលទោសតាមច្បាប់ជាធរមាន៕

# ការនាំចេញផលនេសាទរបស់កម្ពុជាមានការថយចុះ តែផលវារីវប្បកម្ម គឺនៅតែប្រសើរ

*អត្ថបទ៖ ស្រី និច*

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានអះអាងថា ការនាំចេញផលនេសាទស្រស់របស់កម្ពុជាទៅកាន់ទីផ្សារក្រៅប្រទេសកំពុងតែមានការថយចុះ ប៉ុន្តែផល និងការកែច្នៃវារីវប្បកម្មនៅក្នុងប្រទេសនៅតែប្រសើរ។ នេះ បើយោងទៅតាមរបាយការណ៍ស្តីពីសភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំខែមេសា ឆ្នាំ២០២១ និងទិសដៅបន្ត ដែលបានចេញកាលទីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ ។



ប្រភពបានឱ្យដឹងថា ផលនេសាទស្រស់នាំចេញនៅខែមេសា គឺមានចំនួន ២៧១ តោន ហើយសរុបរយៈពេល៤ ខែ មានបរិមាណសរុប១.០៩៧ តោន ស្មើនឹង ១៣,៧១ភាគរយ នៃផែនការនាំចេញដែលមានចំនួនសរុប ៨.០០០ តោន។

របាយការណ៍បានបន្តថា សម្រាប់ផលនេសាទកែច្នៃនាំចេញវិញ គឺបានប្រមាណជា ១៤៧ តោន ស្មើនឹង៧,៣៥ភាគរយ នៃផែនការនាំចេញ ២០០០ តោន ។

ដោយឡែកទាក់ទងនឹងការធ្វើវារីវប្បកម្មជាពិសេស គឺទាក់ទងនឹងការចិញ្ចឹមត្រី និងបង្គាវិញ កម្ពុជាអនុវត្តបានបរិមាណសរុបរយៈពេល ៤ ខែចំនួន ៩៧.១៤៨ តោន ស្មើនឹង ២០,២០ ភាគរយនៃផែនការចំនួន ៤៨១.០០០ តោន។ ដោយឡែកទាក់ទងនឹងការចិញ្ចឹមក្រពើវិញនោះ គឺអនុវត្តបានចំនួន ៣៥.០០០ ក្បាលនៅក្នុងរយៈពេលពីខែមករាដល់ ខែមេសា ស្មើនឹង ១០,៦១ភាគរយ នៃផែនការចំនួន ៣៣០.០០០ ក្បាល។

ប្រភពដដែលបានបន្តថា ការភ្ញាស់ត្រីពូជគឺអនុវត្តន៍បានចំនួន ប្រមាណជា ៥២ លានកូននៅក្នុងរយៈពេល៤ខែ ស្មើនឹង ១៩,២៦ ភាគរយនៃផែនការ២៧០ លានក្បាល។

របាយការណ៍បានបន្តថា ផលនេសាទទឹកសាបសរុបរយៈពេល ៤ខែ គឺអនុវត្តបាន ១៧.០១០តោន ស្មើនឹង ២១,២៦ភាគរយ នៃផែនការ ៨០.០០០ តោន រីឯផលនេសាទសមុទ្រវិញ នៅក្នុងរយៈពេល ៤ ខែ ដូចគ្នា គឺមានចំនួន ៤.១២០ តោន ស្មើនឹង ៣៤,៣៣ភាគរយនៃផែនការ១២.០០០ តោន ។

ប្រភពដដែលបានបន្តថា ចំណូលពីសេវាជលផលនៅក្នុងរយៈពេល ៤ ខែ នេះគឺបានចំនួនប្រមាណជា ៣៤៣,៨១ លានរៀល ស្មើនឹង ៩៥,៨៨ ភាគរយនៃផែនការ៕

# សេដ្ឋកិច្ចកម្ពុជានឹងងើប៨% ក្នុងឆ្នាំនេះ

*អត្ថបទ៖ អរិយបុត្រ*

សេដ្ឋកិច្ចប្រទេសកម្ពុជា ត្រូវបានព្យាករថានឹងកើនឡើង ៤,០% នៅឆ្នាំនេះ និង ៥,៥% ក្នុងឆ្នាំ២០២២ ដោយសារការ ងើបឡើង វិញនៃសេដ្ឋកិច្ចប្រទេសដៃគូពាណិជ្ជកម្មសំខាន់ៗ ដែលជួយជំរុញតម្រូវការ សម្រាប់ការនាំចេញរបស់ប្រទេសកម្ពុជា នេះបើយោងតាមរបាយការណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ីចេញផ្សាយនៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១កន្លងមកនេះ។




នាយិកាប្រចាំប្រទេសកម្ពុជារបស់ធនាគារអភិវឌ្ឍន៍អាស៊ី លោកស្រី Sunniya Durrani-Jamal បានមានប្រសាសន៍ថា «សេដ្ឋកិច្ចកម្ពុជាបានធ្លាក់ចុះ ៣,១% ក្នុងឆ្នាំ ២០២០ ដោយសារការរាតត្បាតជាសកលនៃជំងឺកូវីដ១៩។ រាជរដ្ឋាភិបាលបានឆ្លើយតបយ៉ាងឆាប់រហ័សចំពោះករណីថ្មីៗដែលបានកើតឡើង ហើយយើងរំពឹងថាសេដ្ឋកិច្ចនឹងវិលត្រឡប់មករកកំណើនវិញក្នុងឆ្នាំ ២០២១។ កំណើននេះ នឹងជួយបង្កើនប្រាក់ចំណូលគ្រួសារ ប៉ុន្តែមិនមែនគ្រប់វិស័យនិងតំបន់ទាំងអស់នឹងទទួលបានប្រយោជន៍នេះស្មើគ្នានោះទេ ដូច្នេះវាចាំបាច់ណាស់ ក្នុងការតាមដានមើលជីវភាពគ្រួសារទាំងឡាយ ក៏ដូចជាតម្រូវការគាំទ្របន្ថែម ឱ្យបានដិតដល់»

យោងតាមរបាយការណ៍ទស្សនវិស័យអភិវឌ្ឍន៍អាស៊ី (ADO) ២០២១ ផលិតកម្មឧស្សាហកម្មត្រូវបានគេរំពឹងថានឹងកើនឡើង ៧,១% ក្នុងឆ្នាំ២០២១ និង៧,០% នៅឆ្នាំ ២០២២ ដោយសារការងើបឡើងវិញនៃវិស័យកាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងទំនិញសម្រាប់ការធ្វើដំណើរ ក៏ដូចជាកំណើននៃឧស្សាហកម្មធនស្រាលផ្សេងទៀត ដូចជាផលិតផលអេឡិចត្រូនិច និងកង់។ វិស័យកសិកម្មត្រូវបានរំពឹងថានឹងកើនឡើង ១,៣% ក្នុងឆ្នាំ ២០២១ និង ១,២% ក្នុងឆ្នាំ ២០២២ ដោយមានការកើនឡើងនៃ ផលិតកម្មកសិផល បន្ទាប់ពីរងការខូចខាត ដោយទឹកជំនន់កាលពីឆ្នាំមុន ការបន្តមានកំណើននៃ វារីវប្បកម្ម និងការហក់ឡើងនៃការនាំចេញផលិតផលកសិកម្ម ទៅកាន់សាធារណរដ្ឋប្រជាមានិតចិន។

វិស័យសេវាកម្មនឹងស្ទុះងើបឡើងវិញក្នុងល្បឿនយឺតៗ ពោលគឺប្រមាណ ៣,៣% ក្នុងឆ្នាំ ២០២១ ទៅ ៦,២% ក្នុងឆ្នាំ ២០២២ ។ កិច្ចប្រឹងប្រែងក្នុងការគ្រប់គ្រងការផ្ទុះឡើងនៃជំងឺកូវីដ១៩ នៅក្នុងស្រុក ដែលបានចាប់ផ្តើមក្នុងខែកុម្ភៈឆ្នាំ២០២១ កំពុងធ្វើអោយសកម្មភាពវិស័យសេវាកម្មធ្លាក់ចុះ។ ការរឹតបន្តឹងការធ្វើដំណើរត្រូវបានរំពឹងថានឹងនៅបន្តស្ទើរតែពេញមួយឆ្នាំក្នុងឆ្នាំ ២០២១ ដែលមានន័យថា វិស័យទេសចរណ៍មិនត្រូវបានរំពឹងថាអាចជួយជំរុញកំណើនផ្នែកសេវាកម្មនៅឆ្នាំនេះទេ។ វិស័យអចលនទ្រព្យត្រូវបានព្យាករថា នឹងងើបឡើងវិញ ពីការធ្លាក់ចុះកាលពីឆ្នាំមុន ដោយមាននិន្នាការស្រដៀងគ្នាទៅនឹងឧស្សាហកម្មសំណង់។

«ល្បឿនមិនស្មើគ្នានៃការងើបឡើងវិញនៃវិស័យនានា នឹងបន្តជាសម្ពាធលើគ្រួសារ និងក្រុមហ៊ុនមួយចំនួននៅឆ្នាំនេះ ដែលនឹងធ្វើឱ្យការងើបឡើងវិញនៃសេដ្ឋកិច្ចជារួម មានការយឺតយ៉ាវ។ ហានិភ័យចម្បងៗសម្រាប់ចក្ខុវិស័យសេដ្ឋកិច្ចនេះរួមមាន ការរីករាលដាលនៃការផ្ទុះឡើងនៃកូវីដ១៩ នៅតាមសហគមន៍ កំណើនសេដ្ឋកិច្ចយឺតជាងការរំពឹងទុក នៃដៃគូធុរកិច្ចសំខាន់ៗរបស់កម្ពុជា ដូចជាអាមេរិក និងអឺរ៉ុប ការបន្តនៃភាពទន់ខ្សោយនៃតម្រូវការក្នុងស្រុក និងបញ្ហាប្រឈមរបស់សេវាកម្មហិរញ្ញវត្ថុ និងធនាគារ» លោកស្រី Sunniya Durrani បន្តមានប្រសាសន៍ ដោយបន្ថែមថា រាជរដ្ឋាភិបាលចាំបាច់ត្រូវរក្សាជំហរគោលនយោបាយសារពើពន្ធដែលគាំទ្រកំណើនសេដ្ឋកិច្ចនៅឆ្នាំនេះ និងឆ្នាំក្រោយ ។



> "រាជរដ្ឋាភិបាលបានឆ្លើយតបយ៉ាងឆាប់រហ័ស ចំពោះករណីថ្មីៗដែលបានកើតឡើង ហើយយើងរំពឹងថាសេដ្ឋកិច្ចនឹងវិលត្រឡប់មករកកំណើនវិញក្នុងឆ្នាំ ២០២១។ កំណើននេះ នឹងជួយបង្កើនប្រាក់ចំណូលគ្រួសារ ប៉ុន្តែមិនមែនគ្រប់វិស័យនិងតំបន់ទាំងអស់នឹងទទួលបានប្រយោជន៍នេះស្មើគ្នានោះទេ ដូច្នេះវាចាំបាច់ណាស់ ក្នុងការតាមដានមើលជីវភាពគ្រួសារទាំងឡាយ ក៏ដូចជាតម្រូវការគាំទ្របន្ថែម ឱ្យបានដិតដល់"

ធនាគារអភិវឌ្ឍន៍អាស៊ី កំពុងអនុវត្តគម្រោងវិនិយោគ ដែលមានតម្លៃជាង ២,១ ពាន់ លានដុល្លារនៅកម្ពុជា។ នៅឆ្នាំ ២០២០ ធនាគារអភិវឌ្ឍន៍អាស៊ី បានអនុម័តផ្តល់ប្រាក់កម្ចី និងជំនួយឥតសំណងចំនួន ៤៧៧ លានដុល្លារ ហើយបានកៀគរថវិកាបន្ថែមចំនួន ២៨១,៣ លានដុល្លារ តាមរយៈសហហិរញ្ញប្បទាន សម្រាប់ប្រទេសកម្ពុជា។ ថវិការបស់ ADB ដែលត្រៀមសម្រាប់កម្ពុជាក្នុងឆ្នាំ ២០២១-២០២៣ រួមមានកម្ចីសម្បទានចំនួន ១,៣៥ ពាន់លានដុល្លារ និងជំនួយឥតសំណងចំនួន ៣២,៤ លាន ដុល្លារ ដើម្បី គាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងការស្តារសេដ្ឋកិច្ចជាតិ ពីការរីករាលដាលនៃជំងឺរាតត្បាតកូវីដ-១៩ ៕



# អ្នកសារព័ត៌មាននៅតែដើរតួនាទីសំខា ទោះបីស្ថិតនៅក្នុងកាលៈទេសៈដ៏លំប

*អត្ថបទ៖ អមរិន្ទ ដានុត*

រយៈពេលជិតពីរឆ្នាំកន្លងទៅនេះ ពិភពលោកទាំងមូលបាននិងកំពុងជួបប្រទះនូវមហន្តរាយយ៉ាងធំធេងដែលបង្កឡើងដោយជំងឺឆ្លងជាសកលកូវីដ-១៩ ។

ស្ថិតនៅក្នុងស្ថានភាពដ៏គ្រោះថ្នាក់នេះ ប្រទេសជាច្រើនបានរឹតត្បិតសេរីភាពនៃការប្រមូលផ្តុំ និងដាក់ប្រទេសឱ្យស្ថិតនៅក្នុងគ្រាអាសន្ន ដើម្បីកាត់ផ្តាច់ការឆ្លងរាលដាលជាសកលនៃជំងឺកូវីដ-១៩ និងការពារអាយុជីវិតប្រជាជនឱ្យរួចផុតពីសេចក្តីស្លាប់។

ស្ថានការណ៍ដ៏អាក្រក់នេះបានកាត់ផ្តាច់ខ្សែចង្វាក់ផលិតកម្ម ពាណិជ្ជកម្ម ព្រមទាំងកាត់ផ្តាច់ស្ទើរទាំងស្រុងនៃប្រព័ន្ធសកលភាវូបនីយកម្មធ្វើឱ្យបាត់បង់ការងារ បង្កការរើសអើង ជាតិសាសន៍ គំរាមកំហែងដល់សុខភាពសាធារណៈ ហើយប្រជាជនស្ទើរទូទាំងសកលលោកកំពុងស្ថិតនៅលើមាត់ជ្រោះប្រឈមនឹងការបាត់បង់អាយុជីវិតដែលមិនអាចប៉ាន់ស្មានបាន។

មកដល់ ពេលនេះថ្វីត្បិតតែពិភពលោកមានវ៉ាក់សាំងចាក់ការពារជាបណ្តើរៗហើយក្តី ក៏ជំងឺដ៏កាចសាហាវ នេះនៅមិនទាន់ផុតរលត់ពីផែនដីរបស់យើងនៅឡើយទេ ហើយប្រទេសមួយចំនួនកំពុងបន្តឆ្លងរលកទីបីថែមទៀតដែលកាន់តែសាហាវជាងមុន។

សម្រាប់ព្រះរាជាណាចក្រកម្ពុជា រលកទី៣នៃការឆ្លងរាលដាលជំងឺកូវីដ-១៩ក្នុងព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ បាននិងកំពុងគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់សេចក្តីសុខសាន្ត សុខភាពសាធារណៈ និងបានឆក់យកអាយុជីវិតប្រជាជនកម្ពុជា និងជនបរទេសដែលស្នាក់នៅក្នុងប្រទេសកម្ពុជា អស់ជាច្រើននាក់ផងដែរ។

សម្តេចហ៊ុន សែន នាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា បានលើកឡើងពីតួនាទីដ៏សំខាន់របស់ប្រព័ន្ធផ្សព្វផ្សាយ ពិសេសអ្នកសារព័ត៌មាន បានខិតខំស្វែងរកព័ត៌មានផ្សព្វផ្សាយជូនសាធារណជនបានរហ័សទាន់សភាពការណ៍។

លោកបានមានប្រសាសន៍ថា៖«អ្នកសារព័ត៌មានក៏បានចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងនៃការឆ្លងរាលដាលជាសកលនៃជំងឺកូវីដ-១៩ និងប្រឆាំងព័ត៌មានក្លែងក្លាយនៅគ្រប់ដំណាក់កាលយ៉ាងមានប្រសិទ្ធភាព និងទទួលបានជោគជ័យនាពេលកន្លងមក ទោះបីស្ថិតនៅក្នុងកាលៈទេសៈដ៏លំបាកនិងប្រឈមបែបនេះក្តី»។

សម្តេចតេជោហ៊ុន សែន បានថ្លែងឡើងមកនេះក្នុងសារលិខិតនាឱកាសទិវាសេរីភាពសារព័ត៌មានសកលលោក លើកទី២៨ ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២១ ក្រោមប្រធានបទស្តីពី «ផលប្រយោជន៍នៃព័ត៌មានចំពោះសាធារណជន»។

សម្តេចតេជោ បានថ្លែងថា ៖ «ស្ថិតក្នុងកាលៈទេសៈដ៏លំបាកនិងប្រកបដោយគ្រោះថ្នាក់នេះ ខ្ញុំសូមឱ្យអ្នកសារព័ត៌មាន ទាំងអស់បន្តការខិតខំប្រឹងប្រែងក្នុងការផ្តល់ព័ត៌មានពិតទៅកាន់ប្រជាពលរដ្ឋ ជាពិសេសផ្សព្វផ្សាយ ពន្យល់សារអប់រំ និងវិធានការបង្ការជំងឺឆ្លងកូវីដ-១៩ របស់ក្រសួងសុខាភិបាល ៣កុំ ៣ការពារ»។



*ក្រុមអ្នកសារពតិ៍មានកំពុងតែចុះយកពតិ៍មាន។ រូបភាព៖ ភ្នំពេញប៉ុស្តិ៍-ហេង ជីវ័ន*

ថ្នាក់ដឹកនាំដដែលរូបនេះបានបញ្ជាក់ទៀតថា ៖ «ខ្ញុំសូមបញ្ជាក់ជូនថា ការខិតខំរបស់រាជរដ្ឋាភិបាលតែម្នាក់ឯងពិតជាមិនអាចទទួលបាន ជោគជ័យដោយគ្មានការចូលរួមពីស្ថាប័នសារព័ត៌មាន និងប្រជាពលរដ្ឋនោះទេ»។

សម្តេចនាយករដ្ឋមន្ត្រីក៏បានរំលឹកជាថ្មីម្តងទៀតដល់បងប្អូនអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ដែលកំពុងបំពេញភារកិច្ចលើវិស័យព័ត៌មាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ក៏ដូចជានៅទូទាំង សកលលោក ត្រូវយកចិត្តទុកដាក់អនុវត្តន៍ឱ្យបានត្រឹមត្រូវតាមច្បាប់ ក្រមសីលធម៌វិជ្ជាជីវៈជៀសវាង គិតតែប្រយោជន៍ផ្ទាល់ខ្លួនហើយបំពានទៅលើសិទ្ធិបុគ្គលឯកជនដោយផ្សព្វផ្សាយព័ត៌មានមិនពិត ព័ត៌មានក្លែងក្លាយ ញុះញង់ធ្វើឱ្យប៉ះពាល់ដល់កិត្តិយស សេចក្តីថ្លៃថ្នូរ និងកើតមានភាពវឹកវរ ចលាចលនៅក្នុងសង្គម។

**សារព័ត៌មានពិតជាដើរតួនាទីយ៉ាងសំខាន់នៅក្នុងកាលៈទេសៈដ៏លំបាកនេះ**

> អ្នកសារព័ត៌មានក៏បានចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងនៃការឆ្លងរាលដាលជាសកលនៃជំងឺកូវីដ-១៩ និងប្រឆាំងព័ត៌មានក្លែងក្លាយនៅគ្រប់ដំណាក់កាលយ៉ាងមានប្រសិទ្ធភាព និងទទួលបានជោគជ័យនាពេលកន្លងមក ទោះបីស្ថិតនៅក្នុងកាលៈទេសៈដ៏លំបាកនិងប្រឈមបែបនេះក្តី

ឆ្នាំនេះក៏មិនខុសពីឆ្នាំមុនដែរ ទិវាសេរីភាពសារព័ត៌មាន ៣ ឧសភា ប្រព្រឹត្តទៅក្នុងបរិយាកាសដែលពិភពលោកទាំងមូលញាំញីដោយជំងឺរាតត្បាតសាកលកូវីដ-១៩យ៉ាងធ្ងន់ធ្ងរ។

ក្លិបអ្នកកាសែតកម្ពុជា (ក.អ.ក) បានលើកឡើងថា ជំងឺរាតត្បាតសាកលកូវីដ-១៩ ដែលជាសត្រូវឥតស្រមោលរបស់មនុស្សជាតិមួយនេះ មិនត្រឹមតែបំផ្លាញជីវិតមនុស្ស សុខភាពសាធារណៈ និងសេដ្ឋកិច្ចរបស់បណ្តាប្រទេសនានាប៉ុណ្ណោះទេ ប៉ុន្តែវាក៏បានបង្កឧបសគ្គយ៉ាងធំធេងដល់ការងាររបស់អ្នកសារព័ត៌មានផងដែរ។

ទោះជាយ៉ាងណា ក.អ.ក កត់សម្គាល់ឃើញថា ប្រព័ន្ធផ្សព្វផ្សាយនៅតែអាចបំពេញតួនាទី របស់ខ្លួនក្នុងការផ្តល់ព័ត៌មានជូនមហាជនក្នុងគ្រប់កាលៈទេសៈទាំងអស់។ អ្នកសារព័ត៌មានបានខិតខំ ពុះពារគ្រប់ឧបសគ្គ និងរិះរកគ្រប់មធ្យោបាយដើម្បីបំពេញការងាររបស់ខ្លួនទោះជាក្នុងស្ថានភាពបិទខ្ទប់ក៏ដោយ។

សារព័ត៌មានមិនត្រឹមតែជាអ្នកនាំសារពីថ្នាក់ដឹកនាំប្រាប់ដល់មហាជន និងពីមហាជនប្រាប់ដល់ថ្នាក់ ដឹកនាំបានយ៉ាងលឿនរហ័សប៉ុណ្ណោះទេ ប៉ុន្តែសារព័ត៌មានក៏បានដើរតួនាទីជាអ្នកផ្សព្វផ្សាយសារអប់រំនានាដល់ មហាជនក្នុងការបង្ការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ផងដែរ។

ជាមួយគ្នានេះដែរ សហភាពសហព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ស.ស.ស.ក) ក៏បាន

# ន់ ក្នុងការផ្សព្វផ្សាយជូនសាធារណជន
# ាកនិងប្រឈមក្នុងសម័យកូវីដ-១៩ក្តី







លើកទឹកចិត្តដល់អ្នកសារព័ត៌មាននិងអ្នកប្រើប្រាស់បណ្តាញសង្គម ចូលរួមចំណែកជាមួយរាជរដ្ឋាភិបាល ក្រសួងសុខាភិបាល និងសមត្ថកិច្ចជំនាញពាក់ព័ន្ធតាមគ្រប់មធ្យោបាយ ផ្សព្វផ្សាយនូវវិធានការចាំបាច់នានា បម្រើដល់ការយល់ដឹងរបស់សាធារណៈជនអំពីសុវត្ថិភាពសុខភាព និងសេវាចាំបាច់នានា ដែលអាចជួយឲ្យប្រជាជនគ្រប់ទីកន្លែងបានចៀសផុតពីគ្រោះថ្នាក់ដោយសារជំងឺកូវីដ-១៩ និងហានីភ័យដទៃទៀត។

**ការប្រឈម និងងាយរងគ្រោះរបស់អ្នកសារព័ត៌មានក្នុងអំឡុងពេលកូវីដ-១៩**

ប្រព័ន្ធផ្សព្វផ្សាយ និងអ្នកសារព័ត៌មានឯករាជ្យនៅតែបន្តប្រឈមនឹងឧបសគ្គជាច្រើនក្នុងការបំពេញ ការងារដោយស្របច្បាប់របស់ខ្លួនដោយសេរី និងដោយគ្មានការដាក់កំហិតសិទ្ធិរបស់ខ្លួនឯងជាដើម។

យោងតាមសេចក្តីថ្លែងការណ៍រួមរបស់អង្គការសមាគមជាច្រើនបានសម្តែងនូវការបារម្ភផងដែរនៅក្នុងបរិបទនៃការរាតត្បាតជំងឺកូវីដ-១៩ អាជ្ញាធរបានរឹតបន្តឹងនិងមិនអត់ឱនចំពោះសំឡេងរិះគន់ ហើយអ្នកសារព័ត៌មានកាន់តែងាយរងគ្រោះពីការយាយី និងការចោទប្រកាន់តាមផ្លូវតុលាការ ចំពោះសកម្មភាពរាយការណ៍ព័ត៌មានរបស់ខ្លួនទៅលើប្រធានបទពាក់ព័ន្ធនឹងជំងឺរាតត្បាត។

ប្រភពដដែលបានបន្តថា រវាងខែមករា ដល់ខែមេសា ឆ្នាំ២០២១ អ្នកកាសែតចំនួនបីនាក់ត្រូវបានឃាត់ខ្លួន និងប្រព័ន្ធផ្សព្វផ្សាយចំនួន៦ ត្រូវបានក្រសួងព័ត៌មានដកអាជ្ញាប័ណ្ណ ដោយសារតែសកម្មភាពរាយការណ៍ព័ត៌មានទាក់ទងនឹងជំងឺកូវីដ-១៩ ។ ទាំងនេះបានបង្កឱ្យមានផលប៉ះពាល់មិនល្អចំពោះអ្នករាយការណ៍ព័ត៌មានឯករាជ្យបង្កើននូវការចាប់ពិរុទ្ធខ្លួនឯង និងរារាំងដល់ការទទួលបានព័ត៌មានសំខាន់ៗរបស់ពលរដ្ឋផងដែរ។

សេចក្តីថ្លែងការណ៍នេះបានលើកឡើងថា៖ «នៅក្នុងបរិបទនេះ យើងខ្ញុំសូមក្រើនរម្លឹកថា ការធ្វើការរួមគ្នារវាងប្រព័ន្ធផ្សព្វផ្សាយនិងអាជ្ញាធរ អាចនាំឱ្យមានការផ្សព្វផ្សាយព័ត៌មានកាន់តែទូលំទូលាយទាក់ទងនឹងជំងឺកូវីដ-១៩ ដល់សាធារណជននៅក្នុងប្រទេសកម្ពុជា។ ដូច្នេះ យើងខ្ញុំសូមអំពាវនាវឱ្យរដ្ឋាភិបាលទទួលស្គាល់ពីតួនាទីដ៏សំខាន់របស់អ្នកសារព័ត៌មានក្នុងពេលមានវិបត្តិសុខភាពជាសកលនេះ និងត្រូវធានាថាអ្នកសារព័ត៌មានអាចអនុវត្តន៍ការងាររបស់ខ្លួនដោយគ្មានការភ័យខ្លាច»។

ទន្ទឹមនឹងនេះដែរ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានអំពាវនាវឱ្យអ្នកសារព័ត៌មានទាំងអស់បន្តចូលរួមប្រយុទ្ធប្រឆាំងទៅនឹងព័ត៌មានក្លែងក្លាយដោយ ធ្វើការផ្សព្វផ្សាយព័ត៌មានពិតដើម្បីបន្សាបព័ត៌មានក្លែងក្លាយដែលបង្កឡើងដោយជនអគតិ ដែលតែងតែប្រឆាំងនឹងការរស់ឡើងវិញរបស់ប្រជាជនកម្ពុជា និងជនទុច្ចរិតដែលស្វែងរកផលប្រយោជន៍ ផ្ទាល់ខ្លួនជ្រកក្រោមស្លាកសារព័ត៌មានធ្វើសកម្មភាពខុសច្បាប់ធ្វើឱ្យប៉ះពាល់ដល់កិត្តិយស សេចក្តី ថ្ងៃថ្នូរ កិត្យានុភាពរបស់ស្ថាប័នសារព័ត៌មាន និងអ្នកសារព័ត៌មានអាជីព ដែលមិនអាចអត់ឱនបាន៕

# សមាគម អង្គការសង្គមស៊ីវិលការទាមទាររាជរដ្ឋាភិបាលកម្ពុជាឲ្យ បិទការផ្សព្វផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹងគ្រប់រូបភាពជាអចិន្ត្រៃយ៍

*អត្ថបទ៖ អមរិន្ទ ដានុត*




សមាគម អង្គការសង្គមស៊ីវិលចំនួន៣៨ ស្ថាប័ន ដែលធ្វើការលើវិស័យគ្រឿងស្រវឹង សុខភាព យុវជន សិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ អភិបាលកិច្ចល្អ ធនធានធម្មជាតិ ស្វាគមន៍ចំពោះចំណាត់ការរបស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសក្រសួងព័ត៌មានដែលបានផ្អាកការផ្សព្វផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹងតាមប្រព័ន្ធផ្សព្វផ្សាយទាំងអស់។

ការផ្អាកផ្សព្វផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹង តាមទូរទស្សន៍ វិទ្យុគ្រប់ប្រព័ន្ធ និង ប្រព័ន្ធផ្សព្វផ្សាយតាមអនឡាញទាំងអស់ រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១កន្លងមកនេះ រួមទាំងហាមឃាត់ការលក់ដូរ និងពិសាគ្រឿងស្រវឹងគ្រប់ប្រភេទនៅក្នុងប្រទេស អំឡុងពេលនៃការរឹតបន្តឹងវិធានការរដ្ឋបាលរបស់អាជ្ញាធរស្រប ជាមួយវិធានការសុខាភិបាលដើម្បីបង្ការ និងទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ។

សមាគមអង្គការសង្គមស៊ីវិលទាំងនេះ បានចេញសេចក្តីថ្លែងការណ៍រួមមួយ ដែលRVAKhmer ទទួលបានកាលពីថ្ងៃទី០៤ ខែឧសភា បានលើកឡើងថា បច្ចុប្បន្នជំងឺកូវីដ១៩ នៅ ប្រទេសកម្ពុជា បង្កជាក្តីព្រួយបារម្ភយ៉ាងខ្លាំង ព្រោះជំងឺនេះកំពុងតែរីករាលដាលនិងគំរាមកំហែងដល់អាយុជីវិត ប្រជាពលរដ្ឋខ្មែរ ដោយមានអត្រាអ្នកឆ្លងប្រចាំថ្ងៃកាន់តែមានចំនួនកើនឡើងខ្ពស់ ជាក់ស្តែងនៅថ្ងៃទីថ្ងៃទី២ ខែឧសភា ឆ្នាំ២០២១កន្លងមកនេះមានអ្នកឆ្លងកូវីដ១៩រហូតដល់ ៨៤១នាក់ ហើយរហូតមកដល់ពេលនេះអ្នកស្លាប់ដោយសារ ជំងឺកូវីដ-១៩សរុបជាង១០០នាក់។

សេចក្តីថ្លែងការណ៍រួមបានឱ្យដឹងទៀតថា ការប្រើប្រាស់គ្រឿងស្រវឹងជាហានិភ័យខ្ពស់ក្នុងការឆ្លងជំងឺកូវីដ-១៩ ព្រមទាំងបង្កផលប៉ះពាល់ អវិជ្ជមានយ៉ាងច្រើនដល់សុខភាពនិងសុខុមាលភាពសង្គម ដូចជាគ្រោះថ្នាក់ចរាចរណ៍ អំពើហិង្សា និងជាបន្ទុកជំងឺជាង ២០០មុខ នេះបើតាមការបញ្ជាក់ដោយរបាយការណ៍របស់អង្គការសុខភាពពិភពលោកឆ្នាំ២០១២ ។

ប្រភពដដែលបានលើកឡើងថា ៖ «ហេតុនេះសមាគម អង្គការសង្គមស៊ីវិលស្នើរាជរដ្ឋាភិបាលកម្ពុជា បិទការផ្សព្វផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹងតាមស្ថានីយ៍ទូរទស្សន៍ ស្ថានីយ៍វិទ្យុគ្រប់ប្រព័ន្ធ និងប្រព័ន្ធផ្សព្វផ្សាយតាមអនឡាញ ព្រមទាំងការផ្សព្វផ្សាយជាផ្ទាំងប៉ាណូធំៗតាមដងផ្លូវទាំងអស់ ជាអចិន្ត្រៃយ៍ ដើម្បីលើកស្ទួយសុខភាព និងសុខុមាលភាពសង្គម ព្រមទាំងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ»។

ជាមួយគ្នានេះដែរ អង្គការសង្គមស៊ីវិលក៏សូមលើកទឹកចិត្តផងដែរដល់រាជរដ្ឋាភិបាលកម្ពុជាឲ្យបន្តរឹតត្បិតទៅលើការលក់ដូរ និងប្រើប្រាស់គ្រឿង ស្រវឹងដែលកត្តាបង្កហានិភ័យខ្ពស់ដល់ការឆ្លងមេរោគកូវីដ-១៩ ។

ការបិទការផ្សព្វផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹងជាអចិន្ត្រៃយ៍នឹងជួយកាត់បន្ថយការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ផង និងជួយដល់ប្រជាពលរដ្ឋបន្ទាប់ពីជំងឺកូវីដ-១៩ផុតរលត់ផង ក្នុងការកាត់បន្ថយការប្រើប្រាស់គ្រឿងស្រវឹង ដើម្បីលើកកម្ពស់សុខភាពនិងសុខុមាលភាពសង្គម ក៏ដូចជាសន្សំថវិកា ដោះស្រាយវិបត្តិបំណុល ក៏ដូចជាការកាត់ បន្ថយកំណើននៃភាពក្រីក្រនៅក្នុងសង្គម។

សមាគម អង្គការសង្គមស៊ីវិលទាំងនោះមាន គណៈកម្មាធិការសម្របសម្រួលសកម្មភាពសុខភាព (HACC) , វិទ្យាស្ថានប្រជាធិបតេយ្យកម្ពុជា (CID) , សម្ព័ន្ធភាព សុខភាពនិងការអភិវឌ្ឍន៍ (HEAD), មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព (PDP-Center) , សមាគមសម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC-Cambodia), សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC), អង្គការ គាំទ្របច្ចេកវិទ្យានៅជនបទក្នុងប្រទេសកម្ពុជា (RCTSO), អង្គការកម្មវិធីអភិវឌ្ឍន៍យុវជន (YRDP), មជ្ឈមមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL) និងស្ថាប័នជាច្រើនផ្សេងទៀត៕

# អង្គការសង្គមស៊ីវិលចំនួន៤៥ស្ថាប័នជំរុញរដ្ឋាភិបាលបញ្ឈប់ ការយាយីចំពោះប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងអ្នកសារព័ត៌មាន

*អត្ថបទ៖ អមរិន្ទ ដានុត*



អង្គការសង្គមស៊ីវិលចំនួន៤៥ស្ថាប័ន បានជំរុញឱ្យរាជរដ្ឋាភិបាលកម្ពុជា បញ្ឈប់នូវការយាយីនានាដែលកំពុងបន្តកើតមានចំពោះប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងអ្នកសារព័ត៌មានដែលបានអនុវត្តសិទ្ធិមូលដ្ឋានចំពោះសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន។

នៅក្នុងសេចក្តីថ្លែងការណ៍រួមមួយរបស់អង្គការសង្គមស៊ីវិលទាំងនេះដែលបានចេញកាលពីថ្ងៃទី០៣ ខែមេសា ក្នុងទិវាសេរីភាពសារព័ត៌មានសកល ៣ ឧសភា បានលើកឡើងថា ៖ «យើងខ្ញុំជាអង្គការសង្គមស៊ីវិលមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការបន្តធ្លាក់ចុះនូវបរិយាកាសមិនល្អនៃប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា ហើយយើងខ្ញុំសូមជំរុញឱ្យរាជរដ្ឋាភិបាលកម្ពុជាបញ្ឈប់នូវការយាយីនានាដែលកំពុងបន្តកើតមានចំពោះប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងអ្នកសារព័ត៌មានដែលបានអនុវត្តសិទ្ធិមូលដ្ឋានចំពោះសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន»។

ក្រុមអង្គការសង្គមស៊ីវិលទាំង៤៥ស្ថាប័ននេះ បានជំរុញឱ្យរដ្ឋាភិបាលធ្វើការលុបបំបាត់នូវអំពើនិទណ្ឌភាពប្រឆាំងនឹងអ្នកសារព័ត៌មាន ដែលត្រូវបានវាយប្រហារ និងធ្វើឃាតផងដែរ។

អង្គការសង្គមស៊ីវិលបានឱ្យដឹងថា ៖ «យើងខ្ញុំសូមជំរុញឱ្យរដ្ឋាភិបាលលុបចោលនូវច្បាប់ដែលមានលក្ខណៈគាបសង្កត់ ដែលធ្វើឱ្យប៉ះពាល់ដល់សេរីភាពមូលដ្ឋាន ក៏ដូចជាសេរីភាពសារព័ត៌មាន ហើយត្រូវធានាថារាល់ការតាក់តែងច្បាប់នានាក្នុងពេលខាងមុខនឹងត្រូវបានព្រាងឡើងឱ្យស្របតាមកាតព្វកិច្ចសិទ្ធិមនុស្សរបស់ប្រទេសកម្ពុជា ប្រកបដោយតម្លាភាព និងមានការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល»។

សេរីភាពសារព័ត៌មាននៅតែជាការរំពឹងទុកសម្រាប់ប្រព័ន្ធផ្សព្វផ្សាយ និងអ្នកសារព័ត៌មានឯករាជ្យនៅក្នុងប្រទេសកម្ពុជា ខណៈដែលនិន្នាការនៃការបំបិទសំឡេងប្រព័ន្ធផ្សព្វផ្សាយ និងអ្នកសារព័ត៌មានឯករាជ្យនៅតែបន្តក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ។

យោងតាមសន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោកឆ្នាំ២០២០ ដែលវាយតម្លៃពីការអនុវត្តជាទូទៅនៃសេរីភាពសារព័ត៌មានតាមបណ្តាប្រទេស និងតំបន់នានាជុំវិញសកលលោក បានចាត់ចំណាត់ថ្នាក់ប្រទេសកម្ពុជាថាមិនល្អ ដោយឈរនៅលេខរៀងទី១៤៤ ក្នុងចំណោមប្រទេស១៨០ ។

នៅឆ្នាំ២០២០ យ៉ាងហោចណាស់មានអ្នកសារព័ត៌មាន ២២ នាក់ ត្រូវបានវាយប្រហារ ឬគំរាមកំហែងដោយអំពើហិង្សាអំឡុងពេលបំពេញភារកិច្ច ហើយមានអ្នកសារព័ត៌មានម្នាក់បានទទួលមរណៈភាពដោយគ្រោះថ្នាក់ចរាចរណ៍ ហើយករណីនេះពុំមានការស៊ើបអង្កេតឱ្យបានត្រឹមត្រូវនោះទេ។

អង្គការសង្គមស៊ីវិលទាំងនោះមាន អង្គការក្រុមការងារដោះស្រាយទំនាស់, បណ្តាញអាស៊ីដើម្បីការបោះឆ្នោតដោយសេរី, អង្គការអភិវឌ្ឍន៍សំលេងសហគមន៍, មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា(ម.ស.ម.ក), មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ, សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា), សមាគមបណ្តាញយុវជនកម្ពុជា និងមានអង្គការសង្គមស៊ីវិលជាច្រើនទៀត៕

# អបអរសាទរទិវាសត្វស្លាបទេសន្តរប្រវេសន៍ពិភពលោក ឆ្នាំ២០២១ ក្រោមប្រធានបទ «ច្រៀងហោះហើរ និងសំកាំង - ដូចសត្វស្លាប!»




*អត្ថបទ៖ អមរិន្ទ ដានុត*

ក្រសួងបរិស្ថាននៅថ្ងៃអាទិត្យ ទី០៩ ខែឧសភា នេះបានឱ្យដឹងថា ទិវាសត្វស្លាបទេសន្តរប្រវេសន៍ពិភពលោក តែងតែប្រារព្ធឡើងជារៀងរាល់ឆ្នាំ នៅជុំវិញពិភពលោក ហើយប្រទេសកម្ពុជាបាន ជ្រើសរើសយកថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១ ដើម្បីប្រារព្ធទិវានេះ ក្នុងគោលបំណងអប់រំផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងអំពីការអភិរក្សសត្វស្លាបទេសន្តរប្រវេសន៍ និងទីជម្រករបស់ពួកវា។

> "ការងារអភិរក្សសត្វស្លាបទេសន្តរប្រវេសន៍ គឺទាមទារឱ្យមានការចូលរួម និងសហការពីបណ្តាប្រទេសនានា ដែលស្ថិតនៅផ្លូវហោះហើររបស់ពួកវា"

សត្វស្លាបទេសន្តរប្រវេសន៍ គឺជាប្រភេទសត្វស្លាប ដែលធ្វើការផ្លាស់ទីជារៀងរាល់ឆ្នាំទៅតាមផ្លូវហោះហើររបស់ពួកវា ពីរដងក្នុងមួយឆ្នាំ ពីតំបន់ពងកូន ទៅតំបន់សំចត ឬតំបន់ស្វែងរកចំណី ដែលឆ្លងកាត់ប្រទេសជាច្រើននៅជុំវិញពិភពលោក។

ក្រសួងបរិស្ថានបានបន្តថា ៖«ការងារអភិរក្សសត្វស្លាបទេសន្តរប្រវេសន៍ គឺទាមទារឱ្យមានការចូលរួម និងសហការពីបណ្តាប្រទេសនានា ដែលស្ថិតនៅផ្លូវហោះហើររបស់ពួកវា»។

ផ្លូវហោះហើរសត្វស្លាប គឺជាពាក្យដែលប្រើសម្រាប់បង្ហាញពីតំបន់ភូមិសាស្ត្រមួយដែលសត្វស្លាបជាច្រើនធ្វើការផ្លាស់ទីពីជម្រកពងកូន ទីសំចត និងទីតាំងស្វែករកចំណីក្នុងរដូវកាលជាក់លាក់មួយជាប្រចាំឆ្នាំ។ បច្ចុប្បន្ននៅលើពិភពលោកមានផ្លូវហោះហើរសត្វស្លបចំនួនប្រាំបួន ហើយប្រទេសកម្ពុជាមានទីតាំងស្ថិតនៅក្នុងផ្លូវហោះហើរសត្វស្លាបអាស៊ីខាងកើត-អូស្ត្រាលី និងបានចូលជាសមាជិកកិច្ចសហប្រតិបត្តិការអន្តរជាតិ នៃភាពជាដៃគូរផ្លូវហោះហើរសត្វស្លាបអាស៊ីខាងកើត-អូស្ត្រាលី ចាប់តាំងពីឆ្នាំ២០០៧ ដោយមានក្រសួងបរិស្ថានជាសេនាធិការ។

ក្នុងនាមជាប្រទេសសមាជិក កម្ពុជាបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការសិក្សាស្រាវជ្រាវ អប់រំផ្សព្វផ្សាយ និងអភិរក្សសត្វស្លាបទេសន្តរប្រវេសន៍ និងទីជម្រករបស់ពួកវា ជាក់ស្តែងក្នុងឆ្នាំ២០១៩ តំបន់ការពារទេសភាពអន្លង់ព្រីង ត្រូវបានទទួលស្គាល់ជាតំបន់ នៃបណ្តាញផ្លូវហោះហើរសត្វស្លាបអាស៊ីខាងកើត-អូស្ត្រាលី ដោយលេខាធិការដ្ឋានកិច្ចសហប្រតិបត្តិការអន្តរជាតិ នៃភាពជាដៃគូរផ្លូវហោះហើរសត្វស្លាបអាស៊ីខាងកើត-អូស្ត្រាលី៕

# រដ្ឋមន្ត្រីកសិកម្ម ស្នើអភិបាលខេត្តជាប់ព្រំដែន ទប់ស្កាត់ការនាំចូលសត្វជ្រូក សាច់ជ្រូក និងផលិតផលសាច់ជ្រូកខុសច្បាប់ពីវៀតណាម





*អត្ថបទ៖ ផល សុផានិត*

លោក វេង សាខុន រដ្ឋមន្ត្រីកសិកម្មរុក្ខាប្រមាញ់ និងនេសាទ បានស្នើដល់អភិបាលខេត្តជាប់ព្រំដែនវៀតណាម ជួយទប់ស្កាត់ការនាំចូលសត្វជ្រូក សាច់ជ្រូក និងផលិតផលសាច់ជ្រូកខុសច្បាប់ ពីប្រទេសវៀតណាម ដែលអាចបណ្តាលឱ្យឆ្លងរាលដាលជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF) នៅក្នុងប្រទេសកម្ពុជា។

លោក វេង សាខុន បានបញ្ជាក់ថា បច្ចុប្បន្នជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF) កំពុងបន្តឆ្លងរាលដាលនៅក្នុងពិភពលោក និងបានឆ្លងរាលដាលចូលក្នុងប្រទេសអាស៊ី ក្នុងនោះមានប្រទេសចិន និងអាស៊ីអាគ្នេយ៍ រួមមាន ប្រទេសវៀតណាម មីយ៉ាន់ម៉ា និងប្រទេសកម្ពុជាផងដែរ។

លោកបានសង្កត់ធ្ងន់ថា ៖«ដើម្បីចូលរួមចំណែកក្នុងការទប់ស្កាត់ ការឆ្លងរាលដាលនៃជំងឺនេះ ពីប្រទេសជិតខាងចូលមកកម្ពុជា និងបង្ការការខាតបង់យ៉ាងធ្ងន់ធ្ងរ ដល់អ្នកចិញ្ចឹមជ្រូក ក្រសួងស្នើរដ្ឋបាលខេត្តជាប់ព្រំដែនប្រទេសវៀតណាម ជួយទប់ស្កាត់ការនាំចូលសត្វជ្រូក សាច់ជ្រូក និងផលិតផលសាច់ជ្រូកខុសច្បាប់ ពីប្រទេសវៀតណាម ដែលអាចបណ្តាលឱ្យឆ្លងរាលដាលជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF) នៅក្នុងប្រទេស»។

លោក វេង សាខុន បានបន្តថា ជំងឺនេះបានផ្ទុះនៅក្នុងប្រទេសវៀតណាម លើកដំបូងស្ទើរតែពាសពេញផ្ទៃប្រទេស នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៩ និងបន្តផ្ទុះជារៀងរាល់ឆ្នាំ ហើយនៅថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២១ បានផ្ទុះនៅក្នុងប្រទេសវៀតណាមម្តងទៀត ដែលអាចនឹងបន្តឆ្លងរាលដាល យ៉ាងឆាប់រហ័សដល់បណ្តាខេត្តដែលមានព្រំប្រទល់ជាប់ជាមួយប្រទេសកម្ពុជា។

ខេត្តទាំងនោះមាន ខេត្តដាក់ណុង ជាប់ខេត្តមណ្ឌលគិរី, ខេត្តយ៉ាឡាយ ជាប់ខេត្តរតនគិរី, ខេត្តដុងថាប់ជាប់ខេត្តព្រៃវែង, ខេត្តកៀនយ៉ាងជាប់ខេត្តកំពត, ខេត្តតៃនិញ ជាប់ខេត្តត្បូងឃ្មុំ និងខេត្តស្វាយរៀង, ខេត្តឡុងអាន ជាប់ខេត្តស្វាយរៀង ខេត្តប៊ិញភូ ជាប់ខេត្តក្រចេះ និងខេត្តអានយ៉ាងជាប់ខេត្តតាកែវ និងខេត្តកណ្តាល ដែលជាសញ្ញាហានិភ័យខ្ពស់ នៃការឆ្លងរាលដាល ក្នុងលក្ខណៈទ្រង់ទ្រាយធំ និងធ្ងន់ធ្ងរដល់ព្រះរាជាណាចក្រ

# អភិបាលព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញ នាំយកម៉ាស់ ប្រមាណ ម៉ាស់ ថ្វាយសម្តេចព្រះសង្ឃរាជទាំង

*អត្ថបទ៖ ស៊ីអេសស៊ី*

ភ្នំពេញ ៖ លោក អូលីវីយ៉េ ផ្មិតហាស្លេ អភិបាលព្រះសហគមន៍កាតូលិកកម្ពុជា ភូមិភាគភ្នំពេញ បាននាំយកម៉ាស់ ចំនួនប្រមាណ ១៧ម៉ឺនម៉ាស់ ថ្វាយសម្តេចព្រះសង្ឃរាជទាំងពីរគណ: គឺ សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី កិត្តិឧទ្ទេសបណ្ឌិត ទេព វង្ស សម្តេចព្រះមហាសង្ឃរាជ គណ:មហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា គង់នៅវត្តឧណ្ណាលោម ចំនួន១២ម៉ឺនម៉ាស់ និង សម្តេចព្រះអភិសិរីសុគន្ធមហាសង្ឃរាជាធិបតី កិត្តិឧទ្ទេសបណ្ឌិត បួរ គ្រី សម្តេចព្រះមហាសង្ឃរាជ នៃគណ:ធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា គង់នៅវត្តបុទុមវតី ចំនួន៥ម៉ឺនម៉ាស់ កាលពីរសៀលថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១ ។

លោក អូលីវីយ៉េ អភិបាលព្រះសហគមន៍កាតូលិកកម្ពុជា ភូមិភាគភ្នំពេញ បានថ្លែងថា៖ ព្រះសហគមន៍កាតូលិកកម្ពុជា ភូមិភាគភ្នំពេញ បានទទួលបានម៉ាស់ចំនួន ៤.០០០.០០០ម៉ាស់ (បួនលានម៉ាស់) ពីលោកអគ្គអភិបាល យ៉ូសែប នៃព្រះសហគមន៍កាតូលិកក្រុងហូជីមិញ សម្រាប់ចែកជូនដល់បងប្អូននៅប្រទេសកម្ពុជា ដើម្បីចូលសកម្មភាពការពារ និង ប្រយុទ្ធប្រឆាំងនឹងការរាតត្បាតនៃវីរុសកូវីដ១៩នាពេលបច្ចុប្បន្ននេះ។ ស្របពេលជាមួយគ្នានេះ ព្រះសហគមន៍កាតូលិកកម្ពុជា ភូមិភាគភ្នំពេញ កំពុងតែធ្វើការចែកស្បៀងអាហារជារៀងរាល់ថ្ងៃ ដល់អ្នកទីទាល់ក្រ នៅទីក្រុងភ្នំពេញ និងក្រុងតាខ្មៅ។

លោក អូលីវីយ៉េ ថ្លែងបន្តថា ម៉ាស់ទាំងអស់នេះ បានយកមកចែកជូនដល់ គ្រីស្តបរិស័ទ ឥស្លាមបរិស័ទ និងពុទ្ធបរិស័ទ រួមទាំងតាមស្ថាប័នមួយចំនួនទៀត មានដូចជា បានចែកជូនទៅក្រសួងអប់រំ ក្រសួងធម្មការនិងសាសនា ដល់មន្ទីរតាម

> យើងជាគ្រួសារតែមួយ យើងរួមគ្នាទូទាំងប្រទេស យើងមានសាសនាអ្វីក៏ដោយ ជនជាតិអ្វីក៏ដោយ យើងរស់លើទឹកដីកម្ពុជា ធ្វើដូចម្តេចដើម្បីឈ្នះមេរោគកូវីដ១៩ និងដើម្បីរស់នៅក្នុងសុខដុមរមនា និងសេចក្តីសុខសាន្តសារថ្មីឆាប់ៗនេះ



ខេត្តមួយចំនួន និងតាមព្រះសហគន៍កាតូលិកនៅតាមខេត្ត។ ចំណែកនៅរាជធានីភ្នំពេញ និងក្រុងតាខ្មៅ គឺផ្តល់ជូនចំនួនប្រមាណ៥០សង្កាត់ ក្នុងមួយសង្កាត់ ១០.០០០ (មួយម៉ឺនម៉ាស់)។ ហេតុនេះព្រះសហគមន៍កាតូលិក ចូលរួមជាមួយពុទ្ធសាសនា ពុទ្ធបរិស័ទ ព្រះសង្ឃ ដើម្បីចូលរួមប្រយុទ្ធប្រឆាំង ជំងឺកូវីដ១៩ ដោយភ្ជាប់ជាមួយអនុសាសន៍សម្តេចតេជោ ៣កុំ ៣ការពារ។ លោកបន្តថា លោកមានអំណរនៅពេលនេះដែលបានថ្វាយម៉ាស់ចំពោះ សម្តេចព្រះសង្ឃរាជា ជាឱកាសដើម្បីបង្កើតទំនាក់ទំនង ក្នុងមិត្តភាពជាសាសនាពីរដែលកំពុងបម្រើប្រជារាស្ត្រនៅលើទឹកដីប្រទេសកម្ពុជា ហើយម៉ាសនេះចូលក្នុងផែនការរបស់ក្រសួងសុខាភិបាល ក្នុងប្រយុទ្ធនឹងកូវីដ-១៩ ។



ជាមួយគ្នានេះក្នុងនាមជាអភិបាលព្រះសហគមន៍កាតូលិក លោកបានជំរុញ និងអប់រំគ្រីស្តបរិស័ទឲ្យអនុវត្តជាក់ស្តែង វិធានការណ៍តាមអនុសាសន៍របស់សម្តេច តេជោហ៊ុនសែន ៣កុំ និង៣ការពារ។ លោកថា លោកបានថែមចំណុចបីថែរក្សាទៀត គឺ ទី១ ទទួលខុសត្រូវ៖ ទទួលខុសត្រូវខ្ពស់ ក្នុងតួនាទីរបស់ខ្លួន ជាសិស្ស ជាគ្រូ ជាមាតាបិតា និងយើងជាប្រជារាស្ត្រម្នាក់ យកចិត្តទុកដាក់សុខភាពផ្ទាល់ខ្លួន និងសុខភាពបងប្អូនដែរ។ ទី២ សាមគ្គីភាព គឺឲ្យយើងយកចិត្តទុកដាក់ចែករំលែក ធម៌មេត្តាករុណា សេចក្តីស្រលាញ់ដល់បងប្អូន។ សព្វថ្ងៃព្រះសហគមន៍កាតូលិកធ្វើច្រើនមែនណាស់ ចែកម្ហូបអាហារ និងអំណោយផ្សេងៗ ដល់បងប្អូនរងគ្រោះនិងខ្វះខាត។ ទី៣ គឺអធិដ្ឋាន ឲ្យបងប្អូនភ្ជាប់ជាមួយព្រះ ដើម្បីជួយឲ្យយើងយកចិត្តទុកដាក់ចូលក្នុងរួមជាមួយរាជរដ្ឋាភិបាល ប្រឆាំងកូវីដ-១៩ ។

លោកថា ព្រះសហគមន៍ត្រូវយកចិត្តទុកដាក់

# កម្ពុជា
# រា១៧ម៉ឺន
# ពីរគណៈ





ថែមទៀតលើការសិក្សា ព្រោះថាមេត្តាករុណាមិនត្រឹមតែឲ្យម្ហូប តែសម្រាប់យុវជន និងកុមារជួយគេឲ្យរៀន ONLINE បាន។ យើងមានសិស្សប្រមាណ៣០០០នាក់ ក្នុងសាលាកាតូលិក ពីមត្តេយ្យដល់សាកលវិទ្យាល័យ មាន៩៥% ដែលបានចូលរៀន online ជាមួយកម្មវិធីរបស់យើងបាន។

លោកអភិបាលអូលីវីយ៉េសង្កត់ធ្ងន់ថា ពិតមែនយើងជាគ្រួសារតែមួយ យើងរួមគ្នាទូទាំងប្រទេស យើងមានសាសនាអ្វីក៏ដោយ ជនជាតិអ្វីក៏ដោយ យើងរស់លើទឹកដីកម្ពុជា ធ្វើដូចម្តេចដើម្បីឈ្នះមេរោគកូវីដ១៩ និងដើម្បីរស់នៅក្នុងសុខដុមរមនា និងសេចក្តីសុខសាន្តសារថ្មីឆាប់ៗនេះ។

ចំណែក សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី កិត្តិឧទ្ទេសបណ្ឌិត ទេព វង្ស សម្តេចព្រះមហាសង្ឃរាជគណៈមហានិកាយនៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជា សម្តេចព្រះអភិសិរីសុគន្ធ មហាសង្ឃរាជាធិបតី កិត្តិឧទ្ទេសបណ្ឌិត បួរ គ្រី សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជាបានសម្តែងព្រះទ័យថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះលោកអូលីវីយ៉េ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ដែលបាននាំនូវព្រះដង្វាយជាម៉ាស់ដែលស្ថិតក្នុងបរិបទ កូវីដ-១៩ បានកំពុងតែរាលដាល នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក៏ដូចសាកលលោកទាំងមូល ដើម្បីចាត់ចែង ប្រគេនចំពោះព្រះសង្ឃ តាជី-យាយជី និងពុទ្ធបរិស័ទតាមបណ្តារាជធានី-ខេត្ត សម្រាប់ប្រើប្រាស់ការពារ និងគោរពអនុវត្តតាមអនុសាសន៍ ដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែននាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា «៣ កុំ ៣ ការពារ»។

ការប្រារព្ធពិធីថ្វាយម៉ាស់បានបញ្ចប់ប្រកបដោយភាពស្និទ្ធស្នាល សាមគ្គីភាព និងភាតរភាពបំផុត៕




## លោកអភិបាលអូលីវីយ៉េ ផ្មិតហាស្លេ បានជូនម៉ាសដល់សាលារាជធានីភ្នំពេញ

ម៉ាសបន្ថែមចំនួន ៧៥០០០ ត្រូវបានលោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ អូលីវីយ៉េ ផ្មិតហាស្លេ បានប្រគល់ជូនសាលារាជធានីភ្នំពេញ ដែលទទួលដោយ លោកហួត ហៃ អភិបាលរងរាជធានីភ្នំពេញនាព្រឹកថ្ងៃទី២៦ ខែឧសភា។

លោកអភិបាលមានប្រសាសន៍បញ្ជាក់ថា៖ «កិច្ចការទាំងនេះជាសញ្ញាបង្ហាញ ពីការសហការគ្នា និងយកចិត្តទុកដាក់ ចូលរួមគោរពវិធានតាមអនុសាសន៍របស់សម្តេចតេជោហ៊ុន សែន គឺ៣កុំ ៣ការពារ ដើម្បីយើងអាចយកឈ្នះមេរោគឆ្លងកូវីដ១៩ក្នុងពេលឆាប់ៗនេះ»។

*រូបភាព៖ ព្រះសហគមន៍កាតូលិក*

# លោកអភិបាលប្រ៊ុយណូ កូសម៍ និងសហការី ផ្តល់ទឹក និងភេសជ្ជៈដល់កងកម្លាំងសមត្ថកិច្ចនៅក្រុងកំពង់ចាម

*អត្ថបទ ៖ ព្រះសហគមន៍កាតូលិក*

នៅរសៀលថ្ងៃទី២៥ ខែមេសា កន្លងមកនេះ លោកអភិបាលប្រ៊ុយណូ កូសម៍ និងសហការី នៃភូមិភាគកំពង់ចាម បាននាំយកនូវទឹកបរិសុទ្ធ និងភេសជ្ជៈមួយចំនួនដល់កងកម្លាំងមានសមត្ថកិច្ច និង មន្ត្រីនគរបាល ដែលមាននៅទីតាំង នៅទីស្នាក់ការនៃអធិការដ្ឋាននគរបាលក្រុងកំពង់ចាម ដើម្បីជាការលើកទឹកចិត្ត។

លោក ហេង រ៉ាវី ប្រធានផ្នែកបុគ្គលិកនៃភូមិភាគកំពង់ចាមបានឲ្យដឹងថា ភូមិសាស្ត្រនានានៅខេត្តកំពង់ចាមត្រូវបានបិទ ដើម្បីការពារនៃរីករាលដាលនៃជំងឺកូវីដ១៩ ហើយមន្ត្រីនគរបាល និងកងកម្លាំងសមត្ថកិច្ច ជាអ្នកដែលត្រូវបញ្ចេញកម្លាំងចែកវេនគ្នាយាម តាមច្រកនីមួយៗផងដែរ។

លោកថា ៖ «ដើម្បីលើកទឹកចិត្តដល់ពួកគាត់ក្នុងការបំពេញការងារ២៤ម៉ោងលើ២៤ម៉ោង លោក អភិបាល លោកបូជាចារ្យ និង សហការីនៃភូមិកំពង់ចាម បានផ្តល់ជូននូវភេសជ្ជៈ និង ទឹកបរិសុទ្ធ ដល់ទីស្នាក់ការដោយផ្ទាល់ នៅអធិការដ្ឋាននគរបាលក្រុងកំពង់ចាមនេះ»។

លោក ហេង រ៉ាវី បានបន្តទៀតថា ព្រះសហគមន៍នៅភូមិភាគកំពង់ចាមតែងតែព្យាយាមជួយប្រជាពលរដ្ឋដែលជួបការលំបាកក្នុងជីវភាពរស់នៅមិនថាតែនៅក្នុងរដូវកាលកូវីដ-១៩នោះទេ។

ភេសជ្ជៈដែលផ្តល់ជូន កងកម្លាំង សមត្ថកិច្ច និងមន្ត្រីនគរបាលនាពេលនោះមាន ទឹកបរិសុទ្ធ ចំនួន១០កេស បាកាស២កេស កូកាកូឡា២កេស និងភេសជ្ជៈគោជល់២កេស។

លោកអភិបាលប្រ៊ុយណូ កូសម៍ លោកបូជាចារ្យ និងសហការីនៃភូមិកំពង់ចាមក៏បានជូនពរដល់កងកម្លាំង និងមន្ត្រីនគរបាលទាំងអស់ទទួលបានជោគជ័យគ្រប់ភារៈកិច្ចការងារផងដែរ៕



## ព្រះសហគមន៍ព្រះកុមារយេស៊ូបឹងទំពន់ ផ្តល់គ្រឿងឧបភោគបរិភោគដល់សាលាសង្កាត់បឹងទំពន់ទី២




*អត្ថបទ ៖ ព្រះសហគមន៍កាតូលិក*

តំណាងគ្រីស្តបរិស័ទព្រះវិហារព្រះកុមារយេស៊ូ បឹងទំពន់បានផ្តល់នូវគ្រឿងឧបភោគបរិភោគដល់សាលាសង្កាត់បឹងទំពុនទី២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃចន្ទ ទី២៤ ខែមេសា ដែលជាការចូលរួមចំណែកជួយដល់អ្នកក្រីក្រដែលកំពុងតែខ្វះខាត និងក្រុមគ្រួសារដែលកំពុងធ្វើចត្តាឡីស័ក។

ការនាំយកគ្រឿងឧបភោគបរិភោគនេះ ដឹកនាំដោយលោកបូជាចារ្យ ដាមីញ៉ាំង ហ្វានី ដែលជាអ្នកទទួលបន្ទុកមណ្ឌលសកម្មភាពភ្នំពេញខាងត្បូង តបតាមការស្នើសុំរបស់អាជ្ញាធរមូលដ្ឋាន ក្នុងពេលនៃការបិទខ្ទប់រាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់នូវការរីករាលដាលជំងឺកូវីដ-១៩ ។

តាមរយៈអ្នកស្រី យុន បុប្ផា ចៅសង្កាត់រងបឹងទំពន់ទី២ បានថ្លែងអំណរគុណជូនចំពោះព្រះសហគមន៍កាតូលិកព្រះកុមារយេស៊ូ បឹងទំពន់ និងក្រុមការងារ ដែលបានឆ្លើយតបតាមការស្នើសុំរបស់សាលាសង្កាត់។

អ្នកស្រី បុប្ផា ក៏បានប្រកាសនូវការរក្សាចំណងមិត្តភាពរវាងព្រះសហគមន៍ជាមួយនឹងអាជ្ញាធរដែនដីដើម្បីជួយដល់ជនក្រីក្រនៅក្នុងតំបន់បឹងទំពុនទៅមុខទៀត។

លោកស្រីបានមានប្រសាសន៍នាពេលនោះថា ៖ «ទឹកចិត្តសប្បុរសធម៌នេះ សូមលោកលោកស្រី ទទួលបាននូវបុណ្យកុសល មានសេចក្តីសុខ សេចក្តីចំរើន ហើយអំណោយទាំងអស់នេះសាលាសង្កាត់បានរៀបចំចាត់ចែងភ្លាមដល់ប្រជាពលរដ្ឋដែលកំពុងខ្វះខាត»។

លោកបូជាចារ្យដាមីញ៉ាំង បានឆ្លើយតបដោយស្នើទៅសាលាសង្កាត់សម្រាប់កិច្ចសហការក្នុងការជួយអ្នកក្រីក្រក្នុងអំឡុងពេលនៃការរីករាលដាលជំងឺឆ្លងសាហាវនេះ។

លោកមានប្រសាសន៍ថា ៖ «ព្រះសហគមន៍កាតូលិកព្រះវិហារព្រះកុមារយេស៊ូបឹងទំពន់រីករាយនឹងសហការជាមួយអាជ្ញាធរ និងផ្តល់ជូននូវកម្លាំង និងមធ្យោបាយក្នុងការដឹកជញ្ជូន ប្រសិនបើអាជ្ញាធរត្រូវការ»។

គ្រឿងឧបភោគបរិភោគដែលព្រះសហគមន៍ព្រះកុមារយេស៊ូបានផ្តល់ជូននាពេលនោះមាន មីខ្លាឃ្មុំចំនួន៥០កេស , ត្រីខចំនួន ៥០យួរ, ទឹកដោះគោស្រស់ ៤កេស និងប្រេងឆាចំនួន ១០០ដប៕

## សមាគមសប្បុរសធម៌ សន្តវិនសេនដឺប៉ូលកម្ពុជា ផ្តល់គ្រឿងឧបភោគបរិភោគដល់គ្រួសារក្រីក្រចំនួន១០គ្រួសារ

*អត្ថបទ ៖ ព្រះសហគមន៍កាតូលិក*

សមាគមសប្បុរសធម៌ សន្តវិនសេនដឺប៉ូលកម្ពុជា នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២១ បាននាំយក នូវគ្រឿងឧបភោគបរិភោគ ជូនដល់គ្រួសារក្រីក្រនិងចាស់ជរាចំនួន១០គ្រួសារ ដែលកំពុងជួបការលំបាកខ្វះស្បៀង ក្នុងអំឡុងពេលនៃការផ្ទុះវីរុសកូវីដ-១៩ នេះ។

លោក ផាន ប៉ូរ៉ា ជាក្រុមប្រឹក្សាជាន់ខ្ពស់របស់សមាគមសប្បុរសធម៌សន្តវិនសេនដឺប៉ូលកម្ពុជា បានប្រាប់ឱ្យដឹងថា គ្រឿងឧបភោគបរិភោគ ដែលសមាគមផ្តល់ជូនគ្រួសារនីមួយៗដែលកំពុងខ្វះខាតអំឡុងពេលកូវីដ១៩ រួមមាន អង្ករ១៥គីឡូ ទឹកត្រី ប្រេងឆា ប៊ីចេង ស្ករ អំបិល និងមី ដែលជាថវិការផ្ទាល់របស់សមាគម។

លោកបន្តថា៖«អ្នកក្រីក្រនិងចាស់ជរាទាំង១០គ្រួសារនេះ ភាគច្រើនពួកគាត់អាយុពី៧០-៨០ ឆ្នាំ ហើយពួកគាត់រំពឹងលើកូនៗរបស់គាត់ ជាអ្នកធ្វើការរោងចក្រ នៅទីក្រុងភ្នំពេញផ្ញើប្រាក់ឲ្យពួកគាត់»។

លោក ផាន ប៉ូរ៉ា បានបន្ថែមថា ស្របពេលកើតមានការផ្ទុះខ្លាំងនូវការរីករាលដាលនៃវីរុសកូវីដ១៩ បានផ្ទុះឡើង កូនៗរបស់ពួកគាត់មិនបានផ្ញើប្រាក់ឲ្យពួកគាត់ទៀតទេ ដែលធ្វើឲ្យពួកគាត់ខ្វះខាតស្បៀងយ៉ាងនេះ។

លោកថា សមាគមបានសហការជាមួយនឹងអាជ្ញាធរភូមិ ដើម្បីប្រគល់ស្បៀងជូនពួកគាត់ ដែលពួកគាត់ទាំង១០គ្រួសារមកពី៥ភូមិផ្សេងៗគ្នា ក្នុងនោះមាន ភូមិកោះចាស់ ភូមិកោះកំពង់ត្រុំ ភូមិកោះប៉ែន ភូមិចុងខ្សាច់ និងភូមិកោះដាច់ ដែលស្ថិតនៅក្នុងស្រុកកំពង់សៀម ខេត្តកំពង់ចាម។

សូមបញ្ជាក់ផងដែរថា នៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២១ ខាងមុខនេះ សមាគមសប្បុរសធម៌សន្តវិនសេនដឺប៉ូលកម្ពុជា ក៏នឹងមានគម្រោងយកស្បៀងជូនគ្រួសារក្រីក្រ១០គ្រួសារថែមទៀត ដែលមានទីតាំងនៅ សង្កាត់សំបួរមាស ក្រុងកំពង់ចាម ខេត្តកំពង់ចាម៕



# គ្រួសារចាស់ជរា ខ្វះខាត ចំនួន១៥គ្រួសារ ក្នុងខេត្តកំពង់ចាម ទទួលបានស្បៀងអាហារ ពីអង្គការគ្រួសារសន្តិភាព និង អភិវឌ្ឍន៍



*អត្ថបទ ៖ ព្រះសហគមន៍កាតូលិក*

លោក ផាន ប៉ូរ៉ា នាយកអង្គការ គ្រួសារសន្តិភាព និងអភិវឌ្ឍន៍ និងក្រុមការងារ រួមជាមួយនឹងអាជ្ញាធរភូមិ ឃុំ ក្រុមប្រឹក្សាឃុំ បានចូលរួមកិច្ចការមនុស្សធម៌ ចែករំលែកម្ហូបអាហារដល់ចាស់ជរាខ្វះខាតចំនួន១៥គ្រួសារ រស់នៅភូមិអណ្តូងច្រុះ ឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម នាព្រឹកថ្ងៃសុក្រ ទី៣០ ខែមេសា នេះ។



អំណោយទាំងនេះ ជាអំណោយរបស់អង្គការគ្រួសារសន្តិភាព និង អភិវឌ្ឍន៍(PFDO) ដើម្បីចែករំលែកសេចក្តីស្រឡាញ់ដល់ចាស់ជរាខ្វះខាត ជាពិសេសសង្គ្រោះដល់អ្នកដែលកំពុងតែប៉ះពាល់ដោយសារការរីករាលដាលនៃវីរុសកូវីដ-១៩នេះ។



លោក ផាន ប៉ូរ៉ា បានថ្លែងប្រាប់ថា ៖«កន្លងមកគោលដៅរបស់អង្គការគឺផ្តោតទៅលើការអប់រំជាស្នូល ប៉ុន្តែអង្គការគ្រួសារសន្តិភាព និងអភិវឌ្ឍន៍ក៏នៅតែពិចារណាទៅលើបញ្ហាខ្វះខាតប្រឈមរបស់គ្រួសារខ្វះខាតផងដែរ»។





លោកបានបន្តថា ជាក់ស្តែងក្នុងពេលបច្ចុប្បន្ននេះដោយសារតែការរីករាលដាលនៃវីរុសកូវីដ-១៩ អង្គការបានដកយកកញ្ចប់ថវិកាបំរុង សម្រាប់ជួយគ្រួសារចាស់ជរាខ្វះខាត គ្មានទីពឹងបានប្រមាណជា៨០គ្រួសារ។

លោកនាយកអង្គការរូបនេះបានឲ្យដឹងបន្ថែមទៀតថា អស់រយៈពេលជាច្រើនឆ្នាំមកនេះ អង្គការលោកបានជួយ និងផ្តល់អាហាររូបករណ៍ដល់សិស្សនិស្សិត មកពីគ្រួសារក្រីក្រខ្វះខាតប្រមាណជា៧៥នាក់ ដើម្បីឲ្យពួកគេបានរៀនសូត្រ រីឯអាហាររូបករណ៍សម្រាប់សិស្សនិស្សិតអាចឈានដល់មហាវិទ្យាល័យ អាស្រ័យលើការវាយតម្លៃទៅលើការសិក្សានិង ស្ថានភាពរបស់សិស្សនិស្សិតផ្ទាល់។

ចាប់ពីឆ្នាំ២០១៥ មកដល់ ឆ្នាំ ២០២១នេះ អង្គការគ្រួសារសន្តិភាព និងអភិវឌ្ឍន៍ បានជួយសាងសង់សាលារៀនជូនរដ្ឋ កំរិតបឋមសិក្សា និងវិទ្យាល័យចំនួន៧ហើយ ក្នុងនោះមានសាលាចំនួន៦នៅខេត្តកំពង់ចាម និង១ទៀតនៅខេត្តមណ្ឌលគិរី។ ក្រៅពីនេះក៏បានផ្តល់បង្គន់អនាម័យចំនួនចន្លោះពី២០ទៅ៣០បង្គន់ និងអណ្តូងទឹក២ ក្នុងមួយឆ្នាំផងដែរ។

លោក ផាន់ ប៉ូរ៉ា បានឲ្យដឹងទៀតថា ៖ «អង្គការយើងបានជួយទំនុកបំរុងលើការខ្វះខាតរបស់ចាស់ជរា៣នាក់ជារៀងរាល់ខែ ចាប់ពីឆ្នាំ២០១៦មក ដោយមិនឲ្យពួកគាត់មានការខ្វះខាតឡើយ»។

គួរបញ្ជាក់ផងដែរថា អង្គការគ្រួសារសន្តិភាព និងអភិវឌ្ឍន៍ ជាសមាជិករបស់អង្គការកាតូលិកកម្ពុជា ហើយបានបង្កើតឡើងនៅឆ្នាំ២០១៥ ។ សម្រាប់គោលដៅរបស់របស់អង្គការនេះ គឺផ្តោតលើមនុស្សធម៌សម្រាប់ការអប់រំជាចម្បង រីឯការជួយលើការខ្វះខាតរបស់គ្រួសារក្រីក្រចាស់ជរាខ្វះខាត អង្គការពិចារណាលើស្ថានភាពជាក់ស្តែងដើម្បីជួយ ដូចជាបញ្ហាកើតមានដោយសារការរីករាលដាលនៃវីរុសកូវីដ-១៩នេះជាដើម៕

# គ្រួសារក្រីក្រចំនួន២គ្រួសារបានទទួលស្បៀងពី ព្រះសហគមន៍សន្តហ្វ្រង់ស័រអាស៊ីស៊ី និងសន្តីក្លារ៉ាកោះរការ

*អត្ថបទ៖ សុខុន*

លោកបូជាចារ្យ ហ្វ្រាន់សេស្ក ឱនសហ្សឺ និងបងស្រីស្រឡាញ់ឈើឆ្កាងនៃព្រះសហគមន៍សន្តហ្វ្រង់ស័រអាស៊ីស៊ី និងសន្តក្លារ៉ាកោះរការ បានចុះសួរសុខទុក្ខគ្រួសារក្រីក្រ និងបានផ្តល់នូវស្បៀងអាហារ រួមនឹងម៉ាសសម្រាប់គ្រួសារក្រីក្រចំនួន២គ្រួសារបន្ថែមទៀតនៅថ្ងៃទី១៤ ឧសភា ២០២១នេះ នៅភូមិ ដំបងដែក ឃុំកោះរការ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។

លោកបូជាចារ្យ និងបងស្រី បាននាំយកនូវស្បៀងដែលមានអង្ករចំនួន២៥គីឡូក្រាម និងម៉ាស១ប្រអប់ផ្តល់ជូនគ្រួសារចំនួន២គ្រួសារនេះ។

កញ្ញា ឈឿន គឹមស្រ៊ី ជាគណៈកម្មការនៃព្រះសហគមន៍កោះរការ បានឲ្យដឹងថា ដោយសារតែបញ្ហាកូវីដ១៩ គ្រួសារក្រីក្រមួយចំនួនបានកំពុងជួបប្រទះនូវការខ្វះខាត ដោយមិនអាចចេញខាងក្រៅរកការងារធ្វើបាន ទើបធ្វើឲ្យពួកគាត់ពិបាកក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។





កញ្ញាថា៖ «ថវិការផ្សេងៗដែលទិញអង្ករចែកជូនគ្រួសារចាស់ជរាក្រីក្រនេះ ជាថវិការផ្ទាល់របស់ព្រះសហគមន៍ ដែលមានបងប្អូនគ្រីស្តបរិស័ទមួយចំនួនផ្តល់ឲ្យព្រះសហគមន៍កោះរការតាមរយៈលោកពុកផ្ទាល់(បូជាចារ្យ ហ្វ្រាន់សេស្ក ឱនសហ្សឺ)»។

គួររំលឹកផងដែលថា កាលពីថ្ងៃទី ១២ ខែឧសភា ឆ្នាំ២០២១ កន្លងទៅនេះ ព្រះសហគមន៍កោះរការក៏បានយកស្បៀងជាអង្ករនិងម៉ាសជូនគ្រួសារក្រីក្រចំនួន២គ្រួសារ ដែលមួយនៅភូមិទួលចាប៉ី និង ភូមិកោះប្រាក់ក្រោម ស្ថិតនៅស្រុកកំពង់សៀម ខេត្តកំពង់ចាម ហើយព្រះសហគមន៍ក៏ព្យាយាមជួយបងប្អូនក្រីក្របន្ថែមទៀតទៅតាមលទ្ធភាពរបស់ព្រះសហគមន៍ដែលជួយទៅបាន៕

# ព្រះសហគមន៍កាតូលិករួមជាមួយអង្គការការីតាសកម្ពុជា ចែកអាហារជូន បងប្អូនអ្នកនេសាទ ខ្មែរឥស្លាម និង ជនជាតិខ្មែរ

*អត្ថបទ ៖ ព្រះសហគមន៍កាតូលិក*

នេះព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ រួមជាមួយអង្គការការីតាសកម្ពុជា សហការណ៍ជាមួយ អាជ្ញាធរមូលដ្ឋានបាននាំយក ចំនួន ៧៥០កញ្ចប់ទៅចែកជូនបងប្អូន អ្នកនេសាទ ជាជនជាតិ ខ្មែរ និង ខ្មែរឥស្លាម ស្ថិតនៅកោះ តាមដងទន្លេ មេគង្គ ក្នុងសង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។





តាមលោកគីម រតនា ប្រធានអង្គការការីតាសកម្ពុជាបានឲ្យដឹងថា អាហារហាឡាល សម្រាប់បងប្អូនខ្មែរឥស្លាម មានចំនួន ៣២០ កញ្ចប់ និងសម្រាប់បងប្អូនខ្មែរ មានចំនួន ៤០០ កញ្ចប់ ដែលបងប្អូនទាំងអស់នោះរស់នៅលើទូកតាមដងទន្លេមេគង្គ ប្រកបមុខរបរជាអ្នកនេសាទត្រី។

លោក គីមរតនា បន្តថាចាប់ពីថ្ងៃទី១៤ខែមេសាមក អង្គការការីតាសបានចែកកញ្ចប់ស្បៀងអាហារដល់បងប្អូនជាង៤០០០គ្រួសារ កញ្ចប់មកហើយចំពោះព្រះសហគមន៍កាតូលិក បានចែកជូនបងបង្អូនជា១០០០ គ្រួសារ មានទាំងអង្ករ សាច់ជ្រូកនិងបន្លែ នៅក្នុងភូមិសាស្ត្រាជធានីភ្នំពេញ និងតាខ្មៅ។

លោកបន្តថា តបតាមការអំពាវនាវរបស់លោកអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ អូលីវីយេ៉ អង្គការកាតូលិក បានរួមគ្នាបំពេញកិច្ចការជាមួយព្រះសហគមន៍ និងយកចិត្តទុកដាក់ចំពោះបងប្អូនដែលនៅជិតខាងយើង។

លោកប្រធានអង្គការការីតាសរូបនេះបន្តថា ចាប់បីថ្ងៃទី១ ខែឧសភា មកដល់ពេលនេះ តាមយុទ្ធសាស្ត្រថ្មីរបស់លោកអភិបាល យើងបានចែកអាហារជូនបងប្អូន ដូចជា បងប្អូនម៉ូតូឌុប អ្នករត់កង់បី អ្នករើសអេដចាយ បងប្អូនអ្នកប្រមូលសម្រាម កម្មករសំណង់ និង បងប្អូននេសាទ ដែលមានខ្វះខាត រហូតមកដល់ពេលនេះ មានចំនួនប្រមាណជាង ២៥០០ កញ្ចប់រួចហើយ។

លោកអូលីវីយេ៉ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញបានដាក់ចេញនូវយុទ្ធសាស្ត្រ ចែកអាហារថ្ងៃត្រង់ជូនបងប្អូនខ្វះខាត មានបាយ ម្ហូប ត្រីខកំប៉ុង មី និងទឹកសុទ្ធ ក្នុងមួយថ្ងៃ ចំនួន ៥០០កញ្ចប់ ពីថ្ងៃទី ១-៨ខែឧសភា៕

# ប្រជាពលរដ្ឋចំនួន ៣គ្រួសារ ទទួលបានស្បៀងអាហារនិងការជួយ ពីក្រុមបងស្រីស្រឡាញ់ឈើ ឆ្កាង និងព្រះសហគមន៍កាតូលិកកោះរកា

*អត្ថបទ៖ សុខុន*

ក្រុមបងស្រីស្រឡាញ់ឈើឆ្កាង និងគណៈកម្មការព្រះសហគមន៍សន្តហ្វ្រង់ស័រអាស៊ីស៊ី និងសន្តក្លារា បានផ្តល់ស្បៀងអាហារ និងជួយជួសជុលផ្ទះជូនដល់ប្រជាពលរដ្ឋចំនួន ៣គ្រួសារផ្សេងគ្នា ដែលមានជីវភាពក្រីក្រខ្វះខាត។

ការផ្តល់ស្បៀងអាហារនេះ បានធ្វើឡើង នាព្រឹកថ្ងៃពុធទី៥ ខែឧសភា ឆ្នាំ២០២១ នេះ នៅក្នុងភូមិកោះរការក្រៅ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។

បើតាមការរៀបរាប់របស់ កញ្ញា ឈឿន គឹមស្រ៊ី ដែលជាសមាជិកគណៈកម្មការព្រះសហគមន៍សន្តហ្វ្រង់ស័រអាស៊ីស៊ី និងសន្តក្លារា បានឲ្យដឹងថា បន្ទាប់ពីព្រះសហគមន៍ មើលឃើញពីស្ថានភាព ខ្វះខាតរបស់គ្រួសារក្រីក្រទាំងនេះរួចមក គណៈកម្មការបានយកស្បៀងអាហារជូនដល់ពួកគាត់ ហើយគណៈកម្មការក៏មានគម្រោងជួយជួសជុលផ្ទះជូនដល់ ពួកគាត់ ផងដែរ។

គណៈកម្មការព្រះសហគមន៍ សន្តហ្វ្រង់ស័រអាស៊ីស៊ី និងសន្តក្លារា ក៏នឹងផ្តល់អាហារូបករណ៍សម្រាប់សិក្សានៅវិទ្យាល័យដល់យុវតីម្នាក់ ដែលរស់នៅជាមួយជីដូនចាស់ជរា មានជីវភាព ក្រីក្រខ្វះខាតផងដែរ។

កញ្ញា គឹមស្រ៊ី បានបញ្ជាក់ថា ៖ «ការចំណាយទិញស្បៀងអាហារ និងជួសជុលផ្ទះ គឺជាថវិការផ្ទាល់ខ្លួនរបស់លោកផាន ប៉ូរ៉ា និងគ្រួសារព្រមទាំងការចូលរួមពីគ្រីស្តបរិស័ទ ព្រះសហគមន៍កោះរការនេះផងដែរ»។

រីឯ ការផ្តល់អាហារូបករណ៍រហូតដល់ចប់វិទ្យាល័យ ដែលនឹងផ្តល់ជូនចៅស្រីម្នាក់ ក្នុងគ្រួសារមួយទៀតផ្សេងទៀត គឺឧបត្ថម្ភដោយសមាគមសប្បុរសធម៌សន្តវិនសេនដឺប៉ូល ដែលមានលោកផាន ប៉ូរ៉ា ជាសមាជិកក្រុមប្រឹក្សាជាន់ខ្ពស់មួយរូបរបស់សមាគម។

កញ្ញា ឈឿន គឹមស្រ៊ី បានបន្តថា ចំពោះការជួសជុលផ្ទះចាស់១ខ្នងដល់គ្រួសារក្រីក្រមួយគ្រួសារទៀត ជាការជួយឧបត្ថម្ភពីសំណាក់លោក ផាន ប៉ូរ៉ា ដោយសារលោកមើលឃើញផ្ទះនេះ មានសភាពចាស់ទ្រុឌទ្រោមខ្លាំងពេក ហើយលោកសម្រេចជួយប្តូរឈើពុកៗចេញនិងដាក់ឈើថ្មីជំនួសវិញ។

ឱកាសនោះដែរ លោក ផាន ប៉ូរ៉ា ជាគ្រីស្តបរិស័ទមួយរូប ដែលតែងតែផ្តល់ជំនួយសម្រាប់គ្រួសារក្រីក្របានឲ្យដឹងថា ជាច្រើនដងច្រើនសារលោកតែងតែបញ្ចេញនូវថវិការផ្ទាល់ខ្លួន ដើម្បីជួយគ្រីស្តបរិស័ទ និងអ្នកក្រីក្រខ្វះខាត។

លោកបានបញ្ជាក់ថា ៖ «នេះដោយសារតែខ្ញុំមានអត្តញ្ញាណ ជាគ្រីស្តបរិស័ទ ហើយខ្ញុំក៏មានបេសកកម្ម ដើម្បីប្រកាសដំណឹងល្អ ដែលវាជាផ្នែកមួយហើយក៏ជាសរសរស្តំមានការអធិដ្ឋានតមអាហារ និងការចែករំលែក»។

លោក ផាន ប៉ូរ៉ា បាន បន្តទៀតថា លោកមិនមែនជួយបងប្អូនក្រីក្រតាមរដូវកាលនោះទេ គឺលោក ជួយបងប្អូនគ្រប់រដូវកាល ហើយលោកតែងតែចែករំលែកជានិច្ចផងដែរ។

មួយវិញទៀត វាទាក់ទងនឹងផ្លូវវិញ្ញាណ កាលណាជួបនិងសួរសុខទុក្ខ បងប្អូនក្រីក្រម្តងគឺស្មើ នឹង ជួបព្រះគ្រីស្តម្តង ហើយជួបបងប្អូនក្រីក្រ២ដងស្មើនឹងជួបព្រះគ្រីស្ត២ដងដែរ។ នេះជាការលើក ឡើង បន្ថែម របស់ លោក ផាន ប៉ូរ៉ា។

លោកថ្លែងថា៖ «ព្រះគ្រីស្តតែងតែចាំឲ្យយើងជួយ ហើយបុគ្គលទាំងនោះហើយដែលជារូបតំណាង របស់ព្រះគ្រីស្ត ដូច្នេះហើយទើបធ្វើឲ្យខ្ញុំមើលឃើញព្រះភ័ក្ត្រព្រះគ្រីស្តគ្រប់សកម្មភាពរបស់ខ្ញុំចំពោះបងប្អូនដែលខ្ញុំបានជួយ»៕

# ៣៥០គ្រួសារនៅជ្រោយអំពិលទទួលគ្រឿងបរិភោគ

*អត្ថបទ ៖ ព្រះសហគមន៍កាតូលិក*

ប្រជាជនក្រីក្រ៣៥០គ្រួសារនៅភូមិជ្រោយអំពិល ទទួលគ្រឿងបរិភោគពីអាជីវករមួយក្រុមដឹកនាំដោយលោក ហ្វាម យ៉ាំងយ៉ុង ដោយសហការជាមួយព្រះសហគមន៍ចំប៉ា ដើម្បីសម្រួលដល់ជីវភាពរស់នៅមួយរយៈខ្លីក្នុងអំឡុងនៃការរីករាលដាលជំងឺកូវីដ-១៩ ។

កិច្ចការមនុស្សធម៌នេះបានធ្វើឡើងនាព្រឹកថ្ងៃទី ១២ ខែឧសភា ឆ្នាំ២០២១ នៅព្រះវិហារសន្តហ្វ្រង់ស្វ័រសាវីយេ៉ (ចំប៉ា) ក្នុងភូមិជ្រោយអំពិល ឃុំក្បាលកោះ ស្រុកកៀនស្វាយ ខេត្តកណ្តាល។





តាមប្រសាសន៍របស់លោកបូជាចារ្យ វីរៈជ័យ ស្រ៊ីប្រាម៉ុង ទទួលខុសត្រូវព្រះសហគមន៍ចំប៉ា នៃមណ្ឌលសកម្មភាពទន្លេមេគង្គ និងជាអ្នកសម្របសម្រួលនៅក្នុងកម្មវិធីចែកអំណោយនេះ បានឱ្យដឹងថា ព្រះសហគមន៍ចំប៉ាមានអំណរសប្បាយដោយ មានសប្បុរសជនមួយក្រុមដែលជាអ្នកធ្វើជំនួញនៅក្រុងភ្នំពេញមកចែកអំណោយដល់ប្រជាជនអ្នកក្រីក្រ និងរងគ្រោះដោយសារជំងឺកូវីដ-១៩ ។

លោកបានបន្តថា ៖ «តាមការសង្កេតរបស់ខ្ញុំចំពោះសង្គមបច្ចុប្បន្ននេះ ខ្ញុំមើលឃើញថា មានមនុស្សជាច្រើនបានប្រមូលគ្នាជាគ្រួសារតែមួយ ដើម្បីជួយដល់មនុស្សដែលរង់ចាំជំនួយ ដោយមិនរង់ចាំតែពីរាជរដ្ឋាភិបាលប៉ុណ្ណោះទេ»។

លោកបញ្ជាក់ថា គេនាំជំនួយដោយមិនប្រកាន់លើសាសនា និងជនជាតិទេ។ នេះជាអំណរសប្បាយមួយដែលព្រះជាម្ចាស់ប្រទានឱ្យ តាមរយៈការចេះជួយគ្នាទៅវិញទៅមក ក្នុងឱកាសមានទុក្ខលំបាក។

អំណោយដែលប្រជាជនទាំង៣៥០គ្រួសារទទួលបានមាន អង្ករ១០គីឡូក្រាម និងមី២០កញ្ចប់ក្នុងមួយគ្រួសារ៕





# ព្រះសហគមន៍កំពតជូនសម្ភារៈមួយចំនួនដល់គ្រួសារក្រីក្រ

*អត្ថបទ៖ ដាលីស*

គ្រួសារក្រីក្រ៣១គ្រួសារដែលកំពុងមានជីវភាពខ្វះខាតនិងរងទុក្ខលំបាក ក្នុងភូមិតារាជ ភូមិអូរ និងភូមិត្រពាំងស្គន ទទួលសម្ភារៈមួយចំនួនពីព្រះសហគមន៍ជុំគីរី នៃមណ្ឌលសកម្មភាពកំពត ដែលរៀបចំដោយគណៈកម្មការសង្គហៈ និងដឹកនាំដោយលោកបូជាចារ្យទទួលខុសត្រូវមណ្ឌលសកម្មភាព តាវ៉ូឡា យ៉ាំងលូកា។

កម្មវិធីនេះធ្វើឡើងនៅថ្ងៃទី ៨ ខែឧសភា ឆ្នាំ២០២១ ក្នុងភូមិអូរ ស្រុកជុំគីរី ខេត្រកំពត ដែលនេះជាសកម្មភាពប្រចាំឆ្នាំរបស់ព្រះសហគមន៍។

លោកបូជាចារ្យ តាវ៉ូឡា យ៉ាំងលូកា បានមានប្រសាសន៍ថា តាមពិតទៅព្រះសហគមន៍ត្រូវចែកជូនពួកគាត់មុនក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរមកម្ល៉េះ។

លោកបន្តថា ដោយសារបញ្ហាកូវីដ-១៩រាតត្បាតខ្លាំង ព្រះសហគមន៍បានយកពេលវេលាដើម្បីប្រមូលជំនួយសម្រាប់អ្នកនៅភ្នំពេញ តាមការអំពាវនាវរបស់លោកអភិបាលព្រះសហគមន៍អូលីវីយេ។ ហេតុនេះហើយទើបព្រះសហគមន៍ត្រូវពន្យារពេលចែកជូនពួកគាត់នៅពេលនេះ។

នៅក្នុងឱកាសនេះ លោក លូកា សង្ឃឹមថាគ្រីស្តបរិស័ទទាំងអស់អាចចូលរួមជាមួយគ្នា ដើម្បីលើកទឹកចិត្តដល់អ្នកដែលខ្វះខាត និងខ្វះភាពកក់ក្តៅទាំងផ្លូវកាយនិងចិត្ត។ លោកបន្តថា សង្ឃឹមថាការចុះសួរសុខទុក្ខនេះ អាចជួយពួកគាត់រកឃើញពន្លឺមួយបន្ថែមទៀតក្នុងព្រះនាមព្រះយេស៊ូ។

ក្រុមគ្រួសារទាំង៣១គ្រួសារនេះមកពីភូមិតារាជ ចំនួន១០គ្រួសារ ភូមិត្រពាំងស្គនចំនួន៩គ្រួសារ និងភូមិអូរចំនួន១២គ្រួសារ។ ក្នុងនោះគ្រួសារនីមួយៗទទួលបានអង្ករចំនួន២០គីឡូក្រាម ត្រីខមួយយួរ ថ្នាំដុសធ្មេញ៣ដប សម្លៀកបំពាក់ នំ និងសម្ភារៈក្មេងលេង រួមទាំងទឹកប្រាក់មួយម៉ឺនរៀលផងដែរ៕



# ស្បៀងជាអង្ករនិងម៉ាសត្រូវបានផ្តល់ជូនគ្រួសារក្រីក្រចំនួន២គ្រួសារ ពីព្រះសហគមន៍សន្តប្រាំងស័រអាស៊ីស៊ី និងសន្តីក្លារ៉ាកោះរការ

*អត្ថបទ៖ សុខុន*

លោកបូជាចារ្យ ហ្វ្រាន់សេស្ក ឌីនសហ្ស៊ី (DINTZNER FRANSESCO DAVID និងបងស្រីស្រឡាញ់ឈើឆ្កាងនៃព្រះសហគមន៍សន្តហ្វ្រង់ស័រអាស៊ីស៊ី និងសន្តីក្លារ៉ាកោះរការ បានចុះសួរសុខទុក្ខគ្រួសារក្រីក្រ និងបានផ្តល់នូវស្បៀងអាហារ រួមនឹងម៉ាសផងដែរ កាលពីថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១ ម្សិលមិញនេះ។

លោកបូជាចារ្យ និងបងស្រី បាននាំយកនូវស្បៀងជាអង្ករចំនួន២៥គីឡូក្រាម និងម៉ាស២ប្រអប់ផ្តល់ជូនគ្រួសារចំនួន២គ្រួសារ ដែលរស់នៅក្នុងភូមិទួលចាប៉ី និងភូមិកោះប្រាក់ក្រោម ក្នុងស្រុកកំពង់សៀម ខេត្តកំពង់ចាម។

កញ្ញា ឈឿន គឹមស្រ៊ី ជាគណៈកម្មការនៃព្រះសហគមន៍កោះរការ បានឲ្យដឹងថា ដោយសារតែបញ្ហាកូវីដ១៩ គ្រួសារក្រីក្រមួយចំនួនបានកំពុងជួបប្រទះនូវការខ្វះខាត ដោយមិនអាចចេញខាងក្រៅរកការងារធ្វើបាន ទើបធ្វើឲ្យពួកគាត់ពិបាកក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។

កញ្ញាបានបន្ថែមថា៖ «ថវិការផ្សេងៗដែលទិញអង្ករចែកជូនគ្រួសារចាស់ជរាក្រីក្រនេះ ជាថវិការផ្ទាល់របស់ព្រះសហគមន៍ ដែលមានបងប្អូនគ្រីស្តបរិស័ទមួយចំនួនផ្តល់ឲ្យព្រះសហគមន៍កោះរការតាមរយៈលោកពុកផ្ទាល់(បូជាចារ្យ ហ្វ្រាន់សេស្ក ឌីនសហ្ស៊ី)»។





កញ្ញា ឈឿន គឹមស្រ៊ី ក៏បានបញ្ជាក់ទៀតថា ព្រះសហគមន៍កោះរការនឹងធ្វើការចែកជូនអង្ករនិងម៉ាសជូន២គ្រួសារផ្សេងទៀតក្នុងសប្តាហ៍នេះ ហើយនឹងគ្រោងចែកជូនគ្រួសារក្រីក្របន្តទៀត បន្ទាប់ពីព្រះសហគមន៍ចុះសួរសុខទុក្ខ និងមើលឃើញពីស្ថានភាពជីវភាពរបស់ពួកគាត់៕





# កម្មករ-កម្មការិនីនៅតំបន់ពណ៌ក្រហមអរគុណព្រះសហគមន៍កាតូលិក






*អត្ថបទ ៖ ព្រះសហគមន៍កាតូលិក*

កម្មករ-កម្មការិនី នៅតំបន់ហានិភ័យខ្ពស់បានសម្តែងចិត្តរីករាយ និងអរគុណដល់ព្រះសហគមន៍កាតូលិកកម្ពុជាភូមិភាគភ្នំពេញ ព្រមទាំងអង្គការការីតាសកម្ពុជា ដែលបានផ្តល់ជំនួយសង្គ្រោះបន្ទាន់ ទាន់ពេលវេលា ក្នុងពេលដែលពួកគាត់រស់នៅក្នុងតំបន់បិទខ្ទប់ ឬជាតំបន់ដែលអាជ្ញាធរបានកំណត់ថាជាតំបន់ពណ៌ក្រហម ដែលមានហានិភ័យខ្ពស់ ក្នុងភូមិទួលពង្រ សង្កាត់ចោមចៅទី១ ខណ្ឌពោធិសែនជ័យ។

អ្នកនាងរិន ភា អាយុ២៥ឆ្នាំ មានស្រុកកំណើតនៅខេត្តព្រៃវែង ជាកម្មការិនីធ្វើការនៅរោងចក្រ ញូវ៉ាយដ៏ សព្វថ្ងៃស្នាក់នៅភូមិទួលពង្រ បាននិយាយរៀបរាប់ថា តំបន់ដែលនាងស្នាក់នៅ គឺអាជ្ញាធរបានបិទខ្ទប់តាំងពីថ្ងៃទី១៨ ខែមេសា មកម្លេះ។ នាងបន្តថា នាងមានស្បៀងខ្លះៗដែលបានទិញមកពីផ្សារមុនថ្ងៃបិទខ្ទប់។ ក្នុងរយៈពេលនេះនាងបានសន្សំសំចៃ មិនហ៊ានញ៉ាំច្រើនទេដោយការបារម្ភខ្លាចអស់។ មួយវិញទៀត ដោយសាររោងចក្រសម្រាក មិនទាន់បើកប្រាក់ខែទៀតនៅឡើយ។

នាងបាននិយាយថា ៖ «ខ្ញុំមិនហ៊ាន ញ៉ាំច្រើនទេ ក្រែងអស់ស្បៀង»។

នាងរំភើប និងសប្បាយចិត្តខ្លាំង ពេលទទួលដំណឹងថា នាងត្រូវទទួលជំនួយឧបត្ថម្ភ ស្បៀងពីព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ និងពីអង្គការការីតាសកម្ពុជា។

ចំណែកកញ្ញា ទី សៅសារី វ័យ២១ឆ្នាំ មានស្រុកកំណើតមកពីខេត្តព្រៃវែង ធ្វើការនៅរោងចក្រញូវ៉ាយដ៍ និងស្នាក់ក្នុងភូមិដូច អ្នកនាង រិនភា ដែរនោះ ក៏បានរៀបរាប់ទាំងក្តីរំភើប និងអួលដើមករ ហើយមានតែពាក្យ អរគុណដល់ទឹកចិត្តសប្បុរសធម៌របស់ព្រះសហគមន៍ កាតូលិក និងអង្គការការីតាស កម្ពុជា ដែលបានផ្តល់ស្បៀងដល់រូបនាង។

ចំណែក កម្មការិនីម្នាក់ទៀត កញ្ញា សូត្រ ស្រីពុធ វ័យ២៦ឆ្នាំ មកពីខេត្តកំពង់ចាម ធ្វើការ និងស្នាក់ក្នុងតំបន់បិទខ្ទប់ទួលពង្រដែរនោះបានបញ្ជាក់ថា ពិតជាពិបាកណាស់ ទាំងចេញ ទាំងចូល ដោយសារសន្តិសុខនៅទីនោះយាមមិនឱ្យចេញ។ ទោះបីត្រូវរកសម្ភារអ្វីក៏ពិបាកដែរ។ នាងសូមអរគុណដល់ព្រះសហគមន៍កាតូលិក និងគណៈកម្មការពលករ ដែលបានជួយជ្រោមជ្រែង និងយកចិត្តទុកដាក់ចំពោះសុខទុក្ខរបស់កម្មករកម្មការិនីដែលស្ថិតក្នុងស្ថានភាពលំបាក។

អាជ្ញាធរបានសម្រេចបិទខ្ទប់តំបន់ ភូមិទួលពង្រ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យក្រោយពីបានរកឃើញករណីវិជ្ជមានកូវីដ-១៩ ជាច្រើនចេញពីភូមិសាស្ត្រនោះ ហើយចាត់ជាតំបន់ក្រហម ដែលត្រូវបិទខ្ទប់យ៉ាងតឹងរឹងបំផុត។

នៅពេល មានការបិទខ្ទប់ភូមិស្រាស្តរាជធានីភ្នំពេញនិងក្រុងតាខ្មៅនៃខេត្តកណ្តាល លោកអភិបាល អូលីវីយេ អភិបាលព្រះសហគមន៍កាតូលិកកម្ពុជាភូមិភាគភ្នំពេញ បានកោះប្រជុំបន្ទាន់ និងបង្កើតគណៈកម្មការចំពោះកិច្ចការសង្គ្រោះបន្ទាន់ ក្នុងការជួយផ្តល់ស្បៀងអាហារដល់បងប្អូនដែលខ្វះខាត និងបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រដើម្បីផ្តល់ជំនួយសង្គ្រោះបន្ទាន់ តាមសេចក្តីត្រូវការរបស់បងប្អូន។

លោកក៏បានជំរុញឲ្យគ្រីស្តបរិស័ទម្នាក់ជាសង្ហៈនៅកន្លែងដែលខ្លួនរស់នៅ។ ជាមួយគ្នាលោកក៏ជំរុញលើកទឹកចិត្តឲ្យអង្គការទាំងអស់បំពេញកិច្ចការនេះបន្ទាន់ផងដែរ។

ឆ្លើយតបចំពោះសេចក្តីអំពាវនាវរបស់លោកអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ កញ្ញា ម៉ៅ ស្រីកែវ សមាជិកគណៈកម្មការពលករនៃព្រះសហគមន៍ភូមិភាគភ្នំពេញ បានរៀបចំបញ្ជីឈ្មោះ បងប្អូនកម្មករមួយចំនួនដែលមានជីវភាពខ្វះខាត ជម្រាបជូនលោកបូជាចារ្យ សួន ហង្សលី ទទួលខុសត្រូវភ្នំពេញថ្មី និងជូនអង្គការការីតាសកម្ពុជា។

កញ្ញា ស្រី កែវ បញ្ជាក់ថា ជាការឆ្លើយតបនៅថ្ងៃទី២៧ ខែមេសា ព្រះសហគមន៍កាតូលិក និងអង្គការការីតាសកម្ពុជាបានយកស្បៀងដើម្បីចែកជូនកម្មករដែលស្ថិតនៅតំបន់បិទខ្ទប់ចំនួន១០០គ្រួសារ។

ស្បៀងទាំងនោះរួមចំណែកឧបត្ថម្ភពីអង្គការការីតាសបានឧបត្ថម្ភ៥០គ្រួសារ និងព្រះសហគមន៍ភូមិភាគភ្នំពេញ ចំនួន៥០គ្រួសារ ដែលមានអង្ករ សាច់ជ្រូក បន្លែ និងដើមអំពៅ៕



# ព្រះវិហារគ្រួសារដ៏វិសុទ្ធអ្នកលឿង មានទីសក្ការសម្រាប់ព្រះនាងម៉ារីនៃហ្វាទីម៉ា

*អត្ថបទ៖ រឿន ស្រីម៉ាច*

រូបសំណាកព្រះនាងម៉ារីនៃហ្វាទីម៉ា បានដាក់តម្កល់នៅមុខព្រះវិហារគ្រួសារដ៏វិសុទ្ធនៅព្រះសហគមន៍អ្នកលឿង និងប្រោសទឹកព្រះពរដោយលោកបូជាចារ្យ ប្រ៊ុយណូ កូសម៍ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម និងលោកបូជាចារ្យ វ៉ូសាំង សេរ៉ាល់ ជាបូជាចារ្យគ្រប់គ្រង់តំបន់អ្នកលឿង។

ក្នុងបរិបទកូវីដ-១៩ ពិធីនេះប្រព្រឹត្តទៅយ៉ាងស្ងៀមស្ងាត់ ដែលមានការចូលរួមពីដូនជីកាតូលិក គណៈកម្មការព្រះសហគមន៍ និងតំណាងគ្រីស្តបរិស័ទមួយចំនួន កាលពីថ្ងៃអាទិត្យ ទី១៦ ខែឧសភា ឆ្នាំ២០២១ ។

ដូនជី ម៉ារីយ៉ា ង្វៀន ធី ទៀត ហឿង បំពេញបេសកម្មនៅព្រះវិហារអ្នកលឿង មានប្រសាសន៍ថា ៖ «គ្រីស្តបរិស័ទ(នៅទីនេះ)ចូលចិត្តអធិដ្ឋានតាមរយៈព្រះនាងម៉ារី ដូចនេះបើមានរូបសំណាកព្រះនាងម៉ារីគឺកាន់តែជួយខាងជំនឿពួកគាត់ប្រសើរឡើង»។

ដូនជីរូបនេះបន្ថែមថា កន្លែងព្រះនាងម៉ារីនេះគឺសម្រាប់មនុស្សទាំងអស់ ទាំងអ្នកជឿនិងអ្នកមិនជឿ ដែលចង់អធិដ្ឋាន សម្រាប់ផ្ទាល់ខ្លួន និងជាក្រុម។ ដូនជីម៉ារីយ៉ា បន្តថា រូងថ្មនេះ ធ្វើឡើងគឺដើម្បីបង្ហាញពីវត្តមានព្រះនាងម៉ារីទៅអ្នកផ្សេងដែលមិនមែនជាគ្រីស្តបរិស័ទឲ្យបានស្គាល់ និង ដើម្បីសុំព្រះនាងម៉ារីជួយថែរក្សាការពារព្រះសហគមន៍និងគ្រីស្តបរិស័ទរួមទាំងប្រជាជននៅតំបន់អ្នកលឿង ក៏ដូចជាប្រទេសកម្ពុជាទាំងមូល។

រូបសំណាកព្រះនាងម៉ារីនេះ ធ្វើពីថ្ម និងយកតាមរចនាបថព្រះនាងម៉ារីបង្ហាញខ្លួននៅហ្វាទីម៉ា មានទំងន់ជាង៨០០គីឡូក្រាម ដែលមានគ្រងឈុតពណ៌ស លម្អរដោយមកុដធ្វើអំពីស្ពាន់លាយប្រាក់ ដៃប្រណមអមដោយខ្សែផ្គាំ បានតម្កល់នៅរូងថ្មទំហំបណ្តោយ១៥ម៉ែត្រនិងកម្ពស់៧ម៉ែត្រ នៅខាងមុខព្រះវិហារគ្រួសារដ៏វិសុទ្ធអ្នកលឿង ដែលមានទីតាំងស្ថិតនៅក្នុងភូមិ៦ឃុំព្រែកខ្សាយ(ខ) ស្រុកពាមរ ខេត្តព្រៃវែង។



រូបសំណាក់ព្រះនាងម៉ារី និងរូងថ្មនេះ អាចបញ្ចប់បានដោយជោគជ័យគឺក្រោមការជួយជ្រោមជ្រែង និង ការចូលរួមវិភាគទានរបស់បងប្អូនគ្រីស្តបរិស័ទចំណុះព្រះវិហារផ្ទាល់ និងមួយចំណែកទៀតជាថវិកាផ្ទាល់ខ្លួនពីលោកអភិបាលភូមិភាគកំពង់ចាម លោកបូជាចារ្យ វ៉ូសាំង សេរ៉ាល់ និងបងស្រី២នាក់នៅតំបន់អ្នកលឿង សរុបទឹកប្រាក់សម្រាប់ការសាងសង់គឺប្រមាណជា ២០,៥០០ដុល្លារអាមេរិក៕

# ព្រះសហគមន៍កាតូលិកបាត់ដំបង បានចែកស្បៀង ជូនប្រជាពលរដ្ឋជួបការលំបាកក្នុងជីវភាព

*អត្ថបទ៖ សេង ស្រីមួយ*

ព្រះសហគមន៍កាតូលិកបាត់ដំបង បានចែកស្បៀងជូនដល់បងប្អូនគ្រីស្តបរិស័ទ ពុទ្ធបរិស័ទ និងអ៊ីស្លាមបរិស័ទ ដែលរស់នៅជុំវិញព្រះសហគមន៍ និងកំពុងជួបនូវបញ្ហាខ្វះខាត ដោយការរីករាលដាលនៃវីរុសកូវីដ-១៩ កាលពីចុងខែមេសា កន្លងមកនេះ។








ព្រះសហគមន៍កាតូលិកបាត់ដំបង រួមជាមួយសប្បុរសជនក្រៅប្រទេស បានរៀបចំនូវស្បៀងក៏ដូចជាគ្រឿងឧបភោគបរិភោគមានដូចជា អង្ករ ត្រីខកំប៉ុង ទឹកត្រី ទឹកស៊ីអ៊ីវ និងស្ករស ដើម្បីជួយសម្រាលបន្ទុកដល់បងប្អូនដែលកំពុងជួបនូវការខ្វះខាតនេះ។

លោកបូជាចារ្យ ម៉ានុច បានលើកឡើងថា អំណោយជាស្បៀងនេះ ព្រះសហគមន៍បានរៀបចំសម្រាប់ជួយដល់បងប្អូន ជាសេចក្តីស្រលាញ់ ដែលមកពីព្រះជាម្ចាស់ តាមរយៈព្រះសហគមន៍។

លោកមានប្រសាសន៍ថា ៖ «ដូច្នេះសូមបងប្អូនជួយអធិដ្ឋានសម្រាប់ព្រះសហគមន៍ និងប្រទេសកម្ពុជាចៀសចេញពីវីរុសកូវីដ-១៩ និងសូមឱ្យបងប្អូនចូលរួមថែរក្សាសុខភាពផងដែរ»។ ជាមួយគ្នានេះដែរ តំណាងគណៈកម្មការសង្គហៈ អ្នកស្រី ណ លីណា បានប្រាប់ឲ្យដឹងថា អំណោយដែលព្រះសហគមន៍កាតូលិកបាត់ដំបងផ្តល់ជូនបងប្អូន គឺក្នុងគោលបំណងជួយបងប្អូនដែលកំពុងពិបាកក្នុងការផ្គត់ផ្គង់ប្រចាំថ្ងៃ ដែលព្រះសហគមន៍សង្កេតឃើញថា ស្ថានភាពបច្ចុប្បន្ននេះបងប្អូនកំពុងជួបនូវបញ្ហាយ៉ាងធ្ងន់ធ្ងរ ដោយជំងឺកូវីដ-១៩ ។

អ្នកស្រី បានថ្លែងថា ៖ «មានបងប្អូនខ្លះត្រូវបង្ខំចិត្តទៅធ្វើការនៅខាងក្រៅ ទាំងភ័យខ្លាច និងព្រួយបារម្ភពីសុខភាព ដើម្បីរកចវិការសម្រួលបន្ទុកក្នុងគ្រួសារ។ សូមបងប្អូនសប្បុរសជនទាំងអស់ចូលរួមជាមួយព្រះសហគមន៍ក្នុងការជួយសម្រួលនូវបញ្ហាដែលកំពុងជួបក្នុងពេលបច្ចុប្បន្ននេះ៕




# ព្រះសហគមន៍ប៊ូស្រា សាងសង់ផ្ទះ ជូន បុរសពោះម៉ាយចំណាស់ម្នាក់

*អត្ថបទ៖ រឿន ស្រីម៉ាច*

គណៈកម្មការយុវជនរបស់ព្រះសហគមន៍កាតូលិកប៊ូស្រា ខេត្តមណ្ឌលគិរី ដឹកនាំដោយលោកហ្វ្រង់ស័រ អេមេល្យដាលបូជាចារ្យទទួលខុសព្រះសហគមន៍ បានរួមគ្នាសង់ផ្ទះជូនបុរសពោះម៉ាយមួយរូបវ័យ៧៥ឆ្នាំ ជាជនជាតិដើមភាគតិច ពូណង រស់នៅភូមិពូទើត ឃុំប៊ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី កាលពីថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០២១កន្លងទៅនេះ។

តាមការឱ្យដឹងពីយុវជន លែត លែម សមាជិកម្នាក់នៃក្រុមយុវជនរបស់ព្រះសហគមន៍ប៊ូស្រា ដែលបានចូលរួម សង់ផ្ទះមួយខ្នងនេះបានឲ្យដឹងថា ដោយសារមើលឃើញ ការលំបាករបស់បុរសចំណាស់ពោះម៉ាយរូបនេះ គាត់គ្មានគ្រួសារ កូន និងរស់នៅម្នាក់ឯង ព្រះសហគមន៍បានសម្រេចជួយសង់ផ្ទះជូនគាត់។ ផ្ទះមួយខ្នងនេះ មានទំហំ៥ម៉ែត្រx៤ម៉ែត្រ ធ្វើពីឈើប្រកស័ង្កសី។

យុវជន លែត លែម បញ្ជាក់ថា៖ «លោកតាមានការខ្វះខាតយ៉ាងខ្លាំង គឺសូម្បីតែម្ហូបអាហារក៏មិនអាចផ្គត់ផ្គង់ខ្លួនឯងបាន។ ការរស់នៅប្រចាំថ្ងៃគឺពឹងអាស្រ័យទៅលើអ្នកជិតខាងផ្តល់អាហារឲ្យខ្លះៗ។ លោកតាជាបុរសពោះម៉ាយប្រពន្ធបានស្លាប់យូរឆ្នាំហើយ និងគ្មានកូនចៅនោះឡើយ។ គាត់ទ្រាំរស់នៅតែម្នាក់ឯងក្នុងខ្ទមកំសត់ ចាស់ទ្រុឌទ្រោមយ៉ាងខ្លាំងសឹងតែរកកន្លែងអង្គុយជ្រកភ្លៀងមិនបាន»។

ព្រះសហគមន៍កាតូលិកប៊ូស្រា ក៏បានជូនគ្រឿងបរិភោគមួយចំនួន ដល់បុរសរូបនេះផងដែរ រួមមាន អង្ករ៥០គីឡូក្រាម ត្រីខគ្រឿងទេស ព្រមទាំងសម្ភារៈមួយចំនួនទៀតដូចជា សាប៊ូ ប្រេងកូឡា កំសៀវទឹក មុង កន្ទេល ភួយ និងខ្នើយ៕




# ព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម ផ្តល់ម៉ាស ចំនួន៥០,០០០ម៉ាស ដល់រដ្ឋបាលខេត្តកំពង់ចាម

*អត្ថបទ៖ រឿន ស្រីម៉ាច*

ព្រះសហគមន៍កាតូលិកកម្ពុជាភូមិភាគកំពង់ចាម បានផ្តល់ម៉ាសចំនួន៥០,០០០ម៉ាស ដល់រដ្ឋបាលខេត្តកំពង់ចាម ដើម្បីប្រយុទ្ធប្រឆាំងនឹងការឆ្លងរីករាលដាលនៃមេរោគកូវីដ១៩។ ការផ្តល់នេះបានធ្វើឡើង នារសៀលថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២១នេះកន្លងទៅ នៅសាលាខេត្តកំពង់ចាម។

ពិធីប្រគល់បានប្រព្រឹត្តទៅក្រោមអធិបតីភាព លោក អ៊ុន ចាន់ដា អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម និងលោក ប្រ៊ុយណូ កូសម៍ អភិបាលព្រះសហគមន៍កាតូលិកកម្ពុជាភូមិភាគកំពង់ចាម។

ក្នុងពិធីនេះ លោកអភិបាល ប្រ៊ុយណូ បានមានប្រសាសន៍ថា ៖ «ព្រះសហគមន៍ភូមិភាគកំពង់ចាម យើងចង់ចូលរួមចំណែកក្នុងកិច្ចការមនុស្សធម៌ក្នុងសង្គម គឺតាមរយៈការចែករំលែកសេចក្តីស្រលាញ់ ទៅមនុស្សគ្រប់គ្នា ជាពិសេសអ្នកដែលសង្គមមិនបានចាប់អារម្មណ៍»។

លោកអភិបាលបានបន្តថា កន្លងមកព្រះសហគមន៍បានបរិច្ចាគធនធានខ្លះៗទៅសាលាខេត្តកំពង់ចាមដើម្បីបញ្ជូនបន្តទៅប្រជាពលរដ្ឋដែលកំពុងខ្វះខាតក្នុងពេលប្រទេសកំពុងរងវិបត្តិជំងឺកូវីដ-១៩ និងម្យ៉ាងទៀត ព្រះសហគមន៍ចង់បង្កើនទំនាក់ទំនងល្អរវាង ព្រះសហគមន៍កាតូលិកកម្ពុជាភូមិភាគកំពង់ចាម និងសង្គមខាងក្រៅ។

សកម្មភាពដែលព្រះសហគមន៍បានផ្តល់ គឺមិនមែនដើម្បីចង់ល្បីឬជាការអួតខ្លួនតាមរយៈអំណោយបន្តិចបន្តួចនេះទេ។

លោកមានប្រសាសន៍ថា ៖ «យើងចង់បង្ហាញថា ព្រះសហគមន៍កម្ពុជាភូមិភាគកំពង់ចាមចង់ចូលរួមចែករំលែក អ្វីដែលខ្លួនមាន ទោះតិចរឺច្រើនក្តី ក្នុងបំណងល្អ ក្នុងសេចក្តីស្រឡាញ់ និងធម៌មេត្តាករុណា ទៅមនុស្សជុំវិញខ្លួន»។

លោកអ៊ុន ចាន់ដា ក៏បានថ្លែងអំណរគុណចំពោះទឹកចិត្តក្នុងការចែករំលែក របស់ព្រះសហគមន៍កាតូលិកកម្ពុជាភូមិភាគកំពង់ចាម ក៏ដូចជាការយកចិត្តទុកដាក់ ជួយគ្នាក្នុងគ្រា ដែលប្រទេសកំពុងតែរងនូវវិបត្តិជំងឺកូវីដ-១៩នេះ។

លោកអភិបាលខេត្តបានថ្លែងថា ៖ «ក្នុងនាមខ្ញុំជាអភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម សូមថ្លែងអំណរគុណចំពោះ លោកប្រ៊ុយណូ កូសម៍ អភិបាលនៃព្រះសហគមន៍កាតូលិកកម្ពុជាភូមិភាគកំពង់ចាមដែលតែងតែយកចិត្តទុកដាក់ និងបានចូលរួមចំណែកក្នុងការចែករំលែក សេចក្តីស្រឡាញ់ ចំពោះបងប្អូនក្រីក្រ ខ្វះខាត ជាពិសេសក្នុងគ្រាជំងឺកូវីដ-១៩នេះ»។



ក្នុងនោះលោក អ៊ុន ចាន់ដា បានប្រគល់នូវលិខិតថ្លែងអំណរគុណព្រះសហគមន៍កាតូលិកម្ពុជា ភូមិភាគកំពង់ចាម របស់រដ្ឋបាលខេត្ត ជូនលោកអភិបាលប្រ៊ុណូ កូសម៍ផងដែរ។

សូមរំឭកថា កាលពីថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១ ព្រះសហគមន៍កាតូលិកកម្ពុជា កម្ពុជាភូមិភាគកំពង់ចាមបានឧបត្ថមថវិកាចំនួន ១,១០០ ដុល្លាអាមេរិក មី៦០កេស និងអង្ករចំនួន១,២០០ គីឡូក្រាម រដ្ឋបាលខេត្តកំពង់ចាមម្តងរួចមក ហើយដើម្បីចូលរួមជួយសម្រួលជីវភាពខ្វះខាត របស់ប្រជាពលរដ្ឋមួយចំនួនក្នុងខេត្តកំពង់ចាម ដោយសារវិបត្តិជម្ងឺ កូវីដ-១៩នេះ៕







**ពិធីបន្តពាក្យសច្ចាវ្យលើកទីពាររបស់បងស្រី តេរេសា ចាន់ រដ្ឋា និង បងស្រី ក្លារ៉ា ពេន ហ៊ីល នៃក្រុមគ្រួសារបងស្រីស្រឡាញ់ឈើឆ្កាង ភូមិភាគកំពង់ចាម។ ពិធីបានប្រារព្ធយ៉ាងស្ងៀមស្ងាត់ដោយសារបញ្ហាជម្ងឺកូវីដ-១៩ នាល្ងាចថ្ងៃចន្ទ ទី ០៣ ខែ ឧសភា ឆ្នាំ ២០២១ នៅផ្ទះល្វាវីស ក្រោមអធិបតីភាព លោកប្រ៊ុយណូ កូសម៍ អភិបាល ព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម។**



លោក ប្រ៊ុយណូ កូសម៍ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ ចាម រួមជាមួយលោកបូជាចារ្យ សៃ សាត និងសហការី បានទៅសួរសុខទុក្ខបងប្អូនក្រីក្រពិការភាពដូចជា៖ ពិការជើងនិង ពិការផ្នែកសតិបញ្ញា ចំនួន ៣គ្រួសារ ស្ថិតនៅក្នុងភូមិកោះប៉ែន ឃុំកោះមិត្ត ស្រុក កំពង់សៀម ខេត្តកំពង់ចាម។ ក្នុងនោះលោកអភិបាលបានប្រទានពរដល់ក្រុមគ្រួសារនីមួយៗរួមនិងចែកជូននូវគ្រឿងឧបភោគបរិភោគមួយចំនួនរួមមានម៉ាស់ និង ទឹកអាល់កុលសម្លាប់មេរោគដើម្បីការពារជម្ងឺកូវីដ-១៩ ផងដែរ នារសៀល ថ្ងៃពុធ ទី១២ ខែ ឧសភា ឆ្នាំ២០២១។









លោកសៃ សាត បូជាចារ្យទទួលខុសត្រូវព្រះសហគមន៍កាតូលិកតំបន់កំពង់ចាមបងស្រីរួមនិងគណៈកម្មការសង្គហៈនៃព្រះវិហារកំពង់ចាមក្រុង បានចុះទៅសួរសុខទុក្ខអ្នកជម្ងឺនិងអ្នកដែលកំពុងខ្វះខាត ចំនួន៣គ្រួសាររស់នៅភូមិ ចំការខ្ពប ឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម នារសៀលថ្ងៃពុធទី១៩ ខែឧសភា ឆ្នាំ២០២១ ។ ក្នុងនោះព្រះសហគមន៍ក៏បាននាំយកនូវស្បៀងអាហារខ្លះៗ ម៉ាស់ និង ទឹក អាល់កុលសម្លាប់មេរោគដើម្បីជួយសម្រួលជីវភាពក្នុងការរស់នៅមួយរយៈ។















# *យើងជាគ្រួសារតែមួយ!*

សកម្មភាពមនុស្សធម៌របស់ព្រះសហគមន៍កាតូលិកកម្ពុជា ក្នុងកិច្ចការសហការគ្នា និងយកចិត្តទុកដាក់ចូលរួមរំលែកទុក្ខ
លំបាករបស់បងប្អូនប្រជាពលរដ្ឋដោយការដាក់ផ្តល់នូវស្បៀងអាហារនិងគ្រឿងបរិភោគនានាក្នុងពេលវេលាដ៏លំបាក។

